# ថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១៩

## កិច្ចប្រជុំពង្រឹងសមត្ថភាព ស្តីពី "យុត្តិធម៌ព្រហ្មទណ្ឌ"

https://www.facebook.com/deputygovernoryousophear/ August 30 at 3:35 PM

ថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំពង្រឹងសមត្ថភាព ស្តីពី "យុត្តិធម៌ព្រហ្មទណ្ឌ" ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ លោកជំទាវ ស៊ិន ណម សមាជិកក្រុមប្រឹក្សាខេត្ត លោកព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្ត និងមានការអញ្ជើញចូលរួមពីលោក លោកស្រី ថ្នាក់ដឹកនាំមន្ទីរ-អង្គភាពជុំវិញខេត្ត កងកំលាំងប្រដាប់អាវុធទាំងបី លោក លោកស្រី អភិបាល អភិបាលរង ក្រុង-ស្រុក និងអង្គការមួយចំនួនផងដែរ សរុបចំនួន ២០០នាក់។

កិច្ចប្រជុំនេះគឺដើម្បីពង្រឹងសមត្ថភាពបន្ថែមទៀត រវាងមន្ត្រីនគរបាលយុត្តិធម៌ ជាមួយអាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូរជាតិ-អន្តរជាតិ ក្នុងការបង្ការទប់ស្កាត់ ការបង្ក្រាបរាល់បទល្មើសពាក់ព័ន្ធនានា ក៏ដូចជាបទល្មើសតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា ការអន្តោគមន៍ និងកិច្ចការពារជនរងគ្រោះ ដោយរំលោភបំពានផ្លូវភេទ ពិសេសស្ត្រី និងកុមារ ដើម្បីកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់អោយបានទាំងស្រុងផងដែរ។

## កម្ពុជានឹងសហការជាមួយប្រទេសចំនួន៤នៅអាស៊ានដើម្បីរៀបចំឲ្យមានការអនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករធ្វើការនៅក្រៅប្រទេស

---

http://kampucheathmey.com/ 30/8/2019 10:13 Pm

ភ្នំពេញ ៖ កម្ពុជានឹងសហការជាមួយប្រទេសចំនួន៤នៅអាស៊ាន ដើម្បីរៀបចំឲ្យមានការអនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករធ្វើការនៅបរទេសឲ្យទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗមុនពេលត្រឡប់មកស្រុកកំណើតវិញ។ លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានមានប្រសាសន៍ថាការអនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករខ្មែរ ថៃ វៀតណាម ឡាវនិងមីយ៉ាន់ម៉ាដែលធ្វើការនៅក្រៅប្រទេសនេះគឺដើម្បីឲ្យពលករប្រទេសនីមួយៗអាចផ្ទេរសមាជិកភាព អតីតភាពការងារនិងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេ សមួ យទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ។ ថ្លែងក្រោយកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាកាលពីថ្ងៃទី២៩សីហានៅទីស្តីការក្រសួង លោកបណ្ឌិត អ៊ិត សំហេងបានបន្តថា «អាហ្នឹងយើងគិតមើលស្រួលតើនៅពេលយើងអត់ទាន់មានអាប្រព័ន្ធហ្នឹងបងប្អូនមិចនឹងអាចតភ្ជាប់របបសោធន៍បានធ្វើឲ្យខាតពេលខាតឆ្នាំអីចឹង បើធ្វើការនៅថៃបង់វិភាគទានទៅហើយពេលចប់កិច្ចសន្យាការងារផ្ទេរឈ្មោះពលករនោះមកយើង ហើយពេលពលករថៃមកធ្វើការនៅកម្ពុជាបង់ឲ្យយើងទៅពេលច្បាប់ការងារយើងបង់ឲ្យទៅថៃវិញទៅអីចឹងពេលគាត់ត្រឡប់ទៅវិញអតីតភាពរបបសោធន៍របស់គាត់អត់បាត់បង់ទេ គឺនៅពេញអីចឹងការគិតគូរនេះគឺដល់ផលប្រយោជន៍របស់បងប្អូនពលករ»។ លោករដ្ឋមន្ត្រីបានឲ្យដឹងទៀតថា ពេលពលករទទួលបានរបបសោធននិវត្តន៍នោះ នឹងជួយឲ្យពួកគេអាចមានលទ្ធភាពដោះស្រាយជីវភាពប្រចាំថ្ងៃពេលត្រឡប់មកស្រុកកំណើតវិញទម្រាំរកការងារធ្វើបានឬបង្កើតមុខរបរថ្មីសម្រាប់ចិញ្ចឹមជីវិត។

លោក រដ្ឋមន្ត្រីបានបន្ថែមទៀតថា ការសហការជាមួយប្រទេសទាំង៥ក្នុងតំបន់អាស៊ានដោយសារប្រទេសទាំងនេះមានការចល័តពលករទៅវិញទៅមកដើម្បីឲ្យពួកគេទទួលបាននូវអត្ថប្រយោជន៍ថែមទៀតក្រៅពីការទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរនិងប្រាក់បៀវត្សរ៍សមរម្យ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា ជាជំហានដំបូងកម្ពុជាបានរៀបចំផែនទីបង្ហាញផ្លូវមួយសម្រាប់អនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករធ្វើការនៅក្រៅប្រទេសរួចហើយៗ គ្រោងនឹង

ដាក់ឲ្យរដ្ឋមន្ត្រីក្រសួងការងារទាំង៥ប្រទេស ចុះហត្ថលេខានៅក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី៥និងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី៣ស្តីពីកិច្ចស ហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសទាំង៥ដែលហៅកាត់ថាស៊ី អិល អឹម ធី វី (CLMTV)នាថ្ងៃទី១៦និង១៧ខែកញ្ញា ឆ្នាំ២០១៩នៅខេត្តសៀមរាបមុននឹងឈានទៅចុះកិច្ចព្រមព្រៀងជាផ្លូវការទៅថ្ងៃអនាគត។ លោករដ្ឋមន្ត្រីបានបន្តទៀតថា កិច្ចប្រជុំនេះប្រព្រឹត្តិទៅក្រោមប្រធានបទ«ការតភ្ជាប់សន្តិសុខសង្គម» ដែលកិច្ចប្រជុំនេះធ្វើឡើងរៀងរាល់២ឆ្នាំម្តង ដែលលើកទី១ធ្វើនៅថៃលើកទី២នៅវៀតណាមនិងលើកទី៣ធ្វើនៅកម្ពុជានៅខេត្តសៀមរាប។ លោក រដ្ឋមន្ត្រីបានបន្ថែមទៀតថា ក្រៅពីនេះក្រសួងក៏បានកំពុងធ្វើការទំនាក់ទំនងជាមួយធនាគារអភិវ ឌ្ឍន៍អាស៊ីដែលមានដៃគូច្រើននិងមានបទពិសោធន៍លើការងារបណ្តុះបណ្តាលជំនាញផ្សេងៗឲ្យជួយប ណ្តុះបណ្តាលជំ នាញបន្ថែមដល់ពលករខ្មែរពេលវិលត្រឡប់មកប្រទេសវិញដើម្បីឲ្យពួកគេឆាប់រកការងារបានធ្វើ។

លោកមឿង តុលា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារនិងសិទ្ធិមនុស្សបានគាំទ្រចំពោះគម្រោងអនុវត្តរបបសោធននិវត្តន៍សម្រាប់ពលករទាំង៥ប្រទេសធ្វើការនៅក្រៅប្រទេសនេះពិសេសពលករខ្មែរ ព្រោះបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ពលករ។ តែយ៉ាងណាក៏ដោយលោកបានស្នើឲ្យក្រសួងការងារគួរតែធ្វើការពិភាក្សាជាមួយបណ្តាប្រទេសដែលទទួលពលករខ្មែរនីមួយៗដាច់ដោយឡែកៗពីគ្នា ដើម្បីអនុវត្តផ្តល់ប្រាក់កញ្ចប់សោធននិវត្តន៍នេះហើយបន្ទាប់មកទៀតឲ្យប្រទេសទាំងនោះត្រូវផ្ទេរឈ្មោះពលករ រួមទាំងអតីតភាពការងារនិងការបង់ភាគទានមកឲ្យបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារវិញដើម្បីឲ្យពលករទទួលបានរបបសោធននិវត្តន៍នៅពេលចប់កិច្ចសន្យាការ ងារត្រឡប់មកស្រុកកំណើតវិញ។

តាមរបាយការណ៍ប្រចាំឆ្នាំ២០១៨របស់ក្រសួងការងារបានឲ្យដឹងថាកម្ពុជាបានបញ្ជូនពលករទៅធ្វើការងារនៅក្រៅប្រទេសប្រមាណ១លាន២សែន៣ម៉ឺននាក់ ក្នុងនោះប្រទេសថៃមាន១លាន១សែននាក់ ម៉ាឡេស៊ីជាង៣ម៉ឺននាក់ សិង្ហបុរីចំនួន៨៣១នាក់ កូរ៉េខាងត្បូងជិត៥ម៉ឺននាក់ ជប៉ុនជាង១ម៉ឺននាក់ ♣តំបន់រដ្ឋបាលពិសេសហុងកុង៥៤នាក់ អារ៉ាប់ប៊ីសាអូឌីត១៦នាក់ដោយបានផ្ញើថវិកាមកក្រុមគ្រួសារប្រមាណជាង ២ ពាន់៣រយលានដុល្លារក្នុង១ឆ្នាំៗដែលជួយលើកស្ទួយដល់ក្រុមគ្រួសារក៏ដូចជាសេដ្ឋកិច្ចជាតិរីកចំរើន៕ សំអឿន

## ចារម្ពណាស់! ទាសនារស្រីស្រស់ក្លាយជាយ៉ាខណា ក្រោយត្រូវនាំយកទៅលក់នៅចិន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៩ ម៉ោង ១៥:០០ ម៉េង ធា

រាជធានីភ្នំពេញ ៖ បើតាមសេចក្តីរាយការណ៍បឋមបានឱ្យដឹងថា យុវជនម្នាក់ជាគូរដណ្តឹងរបស់នារីរងគ្រោះដែលអះអាងថា ត្រូវមេខ្យល់នាំយកទៅលក់នៅប្រទេសចិន ហើយមានការព្រួយបារម្ភជាខ្លាំងពីអនាគតប្រពន្ធរបស់ខ្លួននិងបានបន្តទៅដាក់ពាក្យបណ្តឹងជាបន្តបន្ទាប់ទទួចសុំឱ្យសមត្ថកិច្ចក៏ដូចជាស្ថានទូតចិន ជួយអន្តរាគមន៍ធ្វើយ៉ាងណាឱ្យគូដណ្តឹងរបស់ខ្លួនបានត្រឡប់មកវិញ។ ហើយនៅពេលថ្មីនេះ យុវជនជាគូដណ្តឹងរូបនេះ ក៏បន្តទៅដាក់ពាក្យបណ្តឹងជាថ្មីម្តងទៀតនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ ។ សេចក្តីរាយការណ៍បន្តថា យុវជនរូបនោះឈ្មោះ អ៊ុក សុជាតិ អាយុ៣៣ឆ្នាំ រស់នៅសង្កាត់គីឡូម៉ែត្រលេខ៦ ជាអតីតពលករកូរ៉េ និងកំពុងរៀនភាសារជប៉ុនត្រៀមទៅធ្វើពលករប្រទេសជប៉ុននៅពេលខាងមុខនេះ ។ ចំណែកគូរដណ្តឹងឈ្មោះ ញ៉ សុខច័ន្ទ ហៅតក់ អាយុ២៥ឆ្នាំ រស់នៅភូមិភូមិស្ទឹងស្លួត ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង។ រីឯស្រ្តីជាមេខ្យល់ដែលរងការចោទប្រកាន់នោះឈ្មោះ ថោង ស្រីរ័ត្ន អាយុជាង២០ឆ្នាំ មានលំនៅភូមិតាំងស្រី ឃុំមេព្រីង ស្រុកបាជាយ ខេត្តកំពង់ចាម។

គួរបញ្ជាក់ថា កាលពីម៉ោង១០និង៣០នាទីព្រឹក ថ្ងៃទី២៤ សីហា យុវជនជាគូរដណ្តឹងក៏បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍រដ្ឋបាលគីឡូម៉ែត្រលេខ៦ ដើម្បីឱ្យសមត្ថកិច្ចអន្តរគមន៍ ដោយសង្ស័យថា គូរដណ្តឹងរបស់ខ្លួនត្រូវមេខ្យល់នាំយកទៅលក់នៅប្រទេសចិន ព្រមទាំង ទទួចសុំឱ្យសមត្ថកិច្ច ហៅបងស្រីរបស់មេខ្យល់មកសាកសួរ ។ ការដាក់ពាក្យបណ្តឹង បន្ទាប់ពីនារីជាគូដណ្តឹងបានទាក់ទងតាមហ្វេសប៊ុកថា ខ្លួនត្រូវគេនាំយកទៅប្រទេសចិន ហើយ កំពុងតែ

តែលអត់ផ្ទះសំណាក់ នៅព្រំប្រទល់ក្នុងប្រទេសវៀតណាម និងចិន ព្រោះនារីជាគូរដណ្តឹងចាក់ចេញពីប្រទេសទៅជាមួយនារីដែលគេសង្ស័យថា ជាមេខ្យល់ដោយពុំបានប្រាប់ឪពុកម្តាយ និងគូរដណ្តឹងឱ្យបានដឹងឡើយ។ បើតាមបុរសជាគូរដណ្តឹងបានឱ្យដឹងថា ខ្លួនបានស្គាល់នាងសុខច័ន្ទ តាមរយៈការលេងហ្វេសប៊ុក ហើយស្រលាញ់គ្នារយៈពេលប្រមាណ៣ឆ្នាំ ខណៈពេលដែលខ្លួនជាពលករនៅប្រទេសកូរ៉េ ។ បន្ទាប់ពីស្រលាញ់គ្នាយ៉ាងល្អកល្អិននោះ ពេលមកពីកូរ៉េវិញខ្លួនក៏ចូលដណ្តឹងនាងកាលពី១ឆ្នាំមុខ ដើម្បីយកធ្វើជាគូរអនាគត ។ លុះក្រោយមកពួកគេក៏សម្រេចចិត្តប្រឡងចូលរៀនភាសាជប៉ុនជាប់ទាំ២នាក់ ដើម្បីទៅធ្វើពលករនៅប្រទេសជប៉ុន តែខ្លួនគឺរៀនចប់មុន ហើយត្រៀមទៅធ្វើពលករជប៉ុននៅខែ១២ ឆ្នាំនេះ ចំណែកនាងសុខច័ន្ទ គឺទៅជប៉ុននៅវគ្គបន្ទាប់។ បុរសជាគូរដណ្តឹងបានឱ្យដឹងទៀតថា ស្រាប់តែនៅម៉ោងប្រមាណ២យប់រំលងអធ្រាត្រចូលថ្ងៃទី២៣ សីហា គូដណ្តឹងខ្លួនបានទូរស័ព្ទមកតាមរយៈហ្វេសប៊ុកប្រាប់ថា ខ្លួនត្រូវឈ្មោះ ថោង ស្រីត្ន័ នាំយកទៅប្រទេសចិន ទៅដល់ព្រំប្រទល់ប្រទេសវៀតណាម-ចិនតាំងពីថ្ងៃ២០ សីហា ។ ពេលទៅដល់មានមេខ្យល់វៀតណាមប្រុសចេះខ្មែរ មិនស្គាល់ឈ្មោះនាំទៅសម្រាកនៅផ្ទះសំណាក់ ហើយមានវៀតណាម៤នាក់បាននាំទៅបង្ខាំងក្នុងផ្ទះ ដើម្បីត្រៀមយកទៅប្រទេសចិន។ ហើយការទាក់ទងគ្នានេះ រហូតដល់ម៉ោងប្រមាណជាង១រសៀល ត្រូវគូរដណ្តឹងប្រាប់ថា មានថៅកែជាជនជាតិចិនចេះខ្មែរ៤នាក់មិនស្គាល់ឈ្មោះ បានយករថយន្តមកដឹកចូលប្រទេសចិនហើយ ក្រោយមកស្រាប់តែក៏ទាក់ទងលែងបាន ដោយហ្វេសប៊ុកត្រូវគេ BLOCK ចោល។ តាមបុរសជាគូដណ្តឹងឱ្យដឹងទៀតថា នៅព្រឹកថ្ងៃទី២៥ សីហា ខ្លួនបានទទួលឆាតពីស្ត្រីដែលសង្ស័យជាមេខ្យល់ដោយប្រាប់ថា បើចង់ឱ្យនាងត្រឡប់មកវិញឱ្យផ្ញើលុយទៅឱ្យគេ តែក្រោយមកហ្វេសប៊ុកក៏បាន BLOCK ទៀត។ ក្រោយពីកើតហេតុ បន្ទាប់ពីដាក់ពាក្យបណ្តឹងនគរបាលក៏បានហៅបងស្រីមេខ្យល់រូបនោះមកសាកសួរតែនាងប្រាប់ថា «អត់ដឹងនោះទេ» ។

ដោយក្តីបារម្ភពីសុវត្ថិភាពគូរដណ្តឹង បុរសរូបនោះក៏បានទៅបន្តដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជននៃក្រសួងមហាផ្ទៃនៅថ្ងៃទី២៧ ខែសីហា ។ ហើយនៅក្នុងពាក្យបណ្តឹងនោះ យុវជនឈ្មោះ អ៊ុក សុជាតិ ក៏បានសំណូមពរដល់សមត្ថកិច្ចជួយសង្គ្រោះឈ្មោះញ៉ សុច័ន្ទ ដែលជាគូរដណ្តឹងឱ្យបានត្រឡប់មកប្រទេសកម្ពុជាវិញ្ញោផង។ទន្ទឹមនោះ យុវជនរូបនោះក៏មានការព្រួយបារម្ភពីវាសនាគូរដណ្តឹងរបស់ខ្លួនដែលចាញ់បោកមេខ្យល់នាំលក់ប្រទេសចិន ។ (កែសម្រួលដោយ ៖ បុប្ផា)

## អាជ្ញាធរថៃបញ្ជូនពលករខ្មែរ ៨៥នាក់មកកម្ពុជាវិញ បន្ទាប់ពីចាប់ដាក់គុកជាង ៤ខែ

https://www.rfa.org/khmer/ ដោយ សន ចាន់រដ្ឋា 2019-08-30

អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរចំនួន ៨៥នាក់ត្រឡប់ទៅដល់ស្រុកកំណើតវិញហើយ កាលពីរសៀលថ្ងៃទី២៨ សីហា បន្ទាប់ពីប៉ូលិសថៃចាប់ពួកគេជាប់គុកអស់ជាង ៤ខែរួចមក។ ពលករដែលទើបចេញពីគុក អះអាងថា ពួកគេនឹងខ្ចីប្រាក់ពីធនាគារធ្វើលិខិតឆ្លងដែនវិលត្រឡប់ទៅធ្វើការងារនៅប្រទេសថៃវិញក្នុងពេលឆាប់ៗ។

ពលរដ្ឋនៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដែលទើបសមត្ថកិច្ចថៃដោះលែងឱ្យមានសេរីភាពវិញ អ្នកស្រី ផាត សៅគុណ ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី២៩ សីហាថា អាជ្ញាធរថៃបានបញ្ជូនអ្នកស្រី និងពលករដទៃទៀតតាមរថយន្តទ្រុងរបស់ប៉ូលិសអន្តោប្រវេសន្តថៃចូលមកកម្ពុជាតាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នៅម៉ោង ៦ល្ងាចថ្ងៃទី២៨ សីហា។ អ្នកស្រីបន្ថែមថា ពួកគេសប្បាយចិត្តយ៉ាងខ្លាំងរហូតដល់សម្រាន្តមិនលក់ ដោយសាររំភើបក្រោយពីទទួលដំណឹងបានមួយថ្ងៃមុនពេលសមត្ថកិច្ចថៃដោះលែងឱ្យមានសេរីភាព៖ «ជាប់គុកថ្ងៃដំបូងខ្ញុំភ័យដល់ពេលយូរៗទៅមកជាធម្មតាវិញ តែក្នុងចិត្តដេកភ័យមិនដឹងថ្ងៃណាគេដោះលែងវិញ លឺគេថាជាប់ពី ១ឆ្នាំ ទៅ ៣ឆ្នាំបានដោះលែងវិញ ក៏ភ័យខ្ញុំយំរាល់ថ្ងៃចង់មកផ្ទះចេះតែតេមកប្រាប់ពុក។ ភ័យខ្លាចមិនបានចេញណាមួយជំពាក់លុយ

ធនាគារផង។ មួយយប់នឹងគេប្រាប់ខ្ញុំពីល្ងាចមកខ្ញុំដេកអត់លក់ទេ រហូតដល់ព្រឹករហូតដល់គេបញ្ជូនមក រហូតអត់មានអ្នកណាដេកទេ អង្គុយចាំគេបញ្ជូនមកខ្មែរវិញ»។

អ្នកស្រីបន្តថា ពួកគាត់ឆ្លងដែនទៅប្រទេសថៃតាមរថយន្តដឹកទំនិញរបស់ជនជាតិថៃ ដោយមានបាំងសំពត់កៅស៊ូបិទជិត។ អ្នកស្រីបន្ថែមថា ពួកគេអង្គុយប្រជ្រៀតគ្នាយ៉ាងណែនជាង ៥០នាក់ក្នុងមួយគ្រឿង ចេញពីដំណើរព្រំដែនខេត្តបន្ទាយមានជ័យ ឆ្ពោះទៅទីក្រុងបាងកក កាលពីថ្ងៃទី២៥ មេសាកន្លងទៅ ដើម្បីទៅស្វែងរកការងារធ្វើយកប្រាក់ដោះស្រាយជីវភាពគ្រួសារ។ អ្នកស្រីបញ្ជាក់ថា ពួកគេត្រូវបានប៉ូលិសថៃចាប់ខ្លួននៅជាយទីក្រុងបាងកក ក្រោយពីធ្វើដំណើរអស់ប្រហែល ៦ម៉ោង។អ្នកស្រីឱ្យដឹងថា ក្នុងចំណោមដែលដោះលែងនោះ គឺចំនួន៦១នាក់ជាប់គុកនៅស្រុកអារញ្ញ ខេត្តស្រះកែវ និង ២៤នាក់ជាប់គុកនៅទីក្រុងបាងកក។

គេហទំព័រក្រសួងការបរទេសកម្ពុជាចុះផ្សាយនៅថ្ងៃទី២៩ សីហា ថា អាជ្ញាធរថៃ បានដោះលែងពលករខ្មែរចំនួន ៨៥នាក់ ដែលចាប់ខ្លួននៅជាយទីក្រុងបាងកក កាលពីថ្ងៃទី២៥ ខែមេសា កន្លងទៅពីបទឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់។ ក្រសួងឱ្យដឹងទៀតថា ការដោះលែងនេះ ធ្វើឡើង ក្រោយពីមានកិច្ចអន្តរាគមន៍ស្នើសុំជាបន្តបន្ទាប់របស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសថៃ និងស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ (Sra Kao)។ ក្រសួងថា អាជ្ញាធរថៃបានបញ្ជាក់ថា ថ្មីៗនេះ ប្រទេសរបស់ខ្លួនបានចេញច្បាប់ថ្មី ទប់ស្កាត់ការជួញដូរមនុស្ស ដែលមានការស៊ើបអង្កេតយ៉ាងតឹងរ៉ឹងដើម្បីតាមចាប់មេខ្យល់ ទើបបណ្តាលឱ្យមានការឃាត់ខ្លួនពលរដ្ឋខ្មែរទាំង ៨៥នាក់ដាក់ពន្ធនាគារអស់ជាច្រើនខែបែបនេះ។ ក្រសួងឱ្យដឹងថា ពលរដ្ឋខ្មែរទាំង៨៥នាក់ បានមកដល់កម្ពុជាវិញអស់ហើយនៅរសៀលថ្ងៃទី២៨ ខែសីហា ។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ប្រចាំខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា ថ្លែងថា ការដោះលែងនេះដោយសារតែសាច់ញាតិប្តឹងមកអង្គការសង្គមស៊ីវិលនៅខេត្តបន្ទាយមានជ័យ និងមានផ្សាយតាមព័ត៌មានកន្លងមក ទើបមានការអន្តរាគមន៍ពីអាជ្ញាធរកម្ពុជា ហើយប្រសិនបើសាច់ញាតិមិនបានប្តឹងឱ្យជួយពលករទាំងនោះទេ ពួកគេនៅតែបន្តជាប់ឃុំក្នុងគុក មិនដឹងថ្ងៃណាមានសេរីភាពនោះឡើយ។ មន្ត្រីសង្គមស៊ីវិលរូបនេះ លើកឡើងថា ដើម្បីកុំពលករជាប់ពន្ធនាគារជាច្រើនខែបែបនេះទៀត គឺអាជ្ញាធរពាក់ព័ន្ធគួរតែដោះស្រាយជាមួយភាគីថៃឱ្យបានជាក់លាក់ ដើម្បីឱ្យថៃចាប់បញ្ជូនពលករត្រឡប់មកស្រុកកំណើតវិញឱ្យបានឆាប់ ប្រសិនបើពួកគេចាញ់បោកមេខ្យល់ឆ្លងដែនទៅធ្វើការនៅប្រទេសថៃខុសច្បាប់៖ «ព្រោះវាម៉េចកន្លងមក បើគាត់មិនស្រែកមិនអីទេ គឺគ្មានអ្នកណាយកចិត្តទុកដាក់ទេ គឺតែប៉ុណ្ណឹង បើបានស្រែកបានអីខ្លះទៅ មានការនឹកឃើញយកចិត្តទុកដាក់ទៅ រត់ការដោះលែងអីទៅកន្លងមកយើងឃើញអីចឹង រហូតដល់នៅកម្ពុជាយើងរហូតដល់មានការឃុំខ្លួនលើសឃុំអី ហើយត្រូវបានពួកគាត់ស្រែអីចឹងក៏បានការដោះលែងទៅ»។

ក្រោយពីសមត្ថកិច្ចថៃដឹកពលករទាំង៨៥នាក់មកព្រំដែនកម្ពុជាហើយ គឺអាជ្ញាធរកម្ពុជា និងអង្គការសង្គមស៊ីវិលធ្វើការងារផ្នែកលើកកម្ពស់ពលករប្រចាំនៅក្រុងប៉ោយប៉ែត បានអប់រំដល់ពួកគេប្រមាណ ១ម៉ោង ទើបអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ នៅរសៀលថ្ងៃទី២៨ សីហា។

អ្នកស្រី ផាត សៅគុណ អះអាងថា ក្រោយពីការដោះលែងមានសេរីភាពហើយ ពួកគេគ្រោងទៅខ្ចីប្រាក់ពីធនាគារ ដើម្បីធ្វើលិខិតឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃជាថ្មីទៀត ក្នុងពេលឆាប់ៗ ពីព្រោះនៅស្រុកកំណើតគ្មានការងារធ្វើ រកប្រាក់ចំណូលដោះស្រាយជីវភាពនោះឡើយ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៤នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI August 30 at 6:24 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៤នាក់ នាវេលាម៉ោង ១៧និង៥០នាទី ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរពីភាគីថៃ ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration-GDI August 30 at 4:09 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៩

## រាជរដ្ឋាភិបាលកម្ពុជា អរគុណម៉ាឡេស៊ី ដែលផ្តល់ការងារដល់ពលករខ្មែរចំណាកស្រុក

http://www.freshnewsasia.com/ 2019-09-03

**(ភ្នំពេញ)៖** រាជរដ្ឋាភិបាលកម្ពុជា បានសម្តែងនូវអំណរគុណចំពោះរដ្ឋាភិបាលម៉ាឡេស៊ី ដែលផ្តល់ឱកាសការងារជូនដល់ពលករចំណាកស្រុករបស់កម្ពុជា។ នេះបើតាមសេចក្តីថ្លែងការណ៍រួម ដែលផ្សព្វផ្សាយក្រសួងការបរទេស អំពីលទ្ធផលនៃដំណើរទស្សនកិច្ចរបស់ នាយករដ្ឋមន្ត្រីម៉ាឡេស៊ី មកកាន់ប្រទេសកម្ពុជា។ ក្នុងដំណើរទស្សនកិច្ចផ្លូវការនេះ លោក មហាធា មហាម៉ាត់ (Mahathir Mohamad) នាយករដ្ឋមន្ត្រីម៉ាឡេស៊ី បានជួបពិភាក្សាទ្វេភាគីជាមួយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅវិមានសន្តិភាព នាព្រឹកថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩។

សេចក្តីថ្លែងការណ៍រួម បានបញ្ជាក់ថា៖ **«ថ្នាក់ដឹកនាំទាំងពីរលើកទឹកចិត្តស្ថាប័នពាក់ព័ន្ធ នៃប្រទេសទាំងពីរ ដើម្បីបន្តពង្រឹងក្របខណ្ឌដែលបានព្រមព្រៀងគ្នាក្នុងវិស័យការងារ និងជំរុញបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលកាន់តែជិតស្និទ្ធរវាងស្ថាប័នពាក់ព័ន្ធ ដើម្បីការពារសិទ្ធិ និងដោះស្រាយបញ្ហាសុខុមាលភាពពលករ ចំណាកស្រុករបស់កម្ពុជានៅម៉ាឡេស៊ី»**។

រាជរដ្ឋាភិបាលកម្ពុជា-ម៉ាឡេស៊ី បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាថ្មីឡើងវិញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបញ្ជូនពលរដ្ឋខ្មែរទៅធ្វើការងារនៅប្រទេសម៉ាឡេស៊ី បន្ទាប់ពីបានផ្អាកអស់រយៈពេលជាច្រើន ដើម្បីសិក្សាកែលម្អឡើងវិញ៕

## កម្លាំងសមត្ថកិច្ចខេត្តស្រះកែវ ឃាត់ខ្លួនក្រុម មេខ្យល់កេសុីនាំពលករខុសច្បាប់ចេញទៅ ខ្មែរ

https://www.facebook.com/ ពលករខ្មែរ-News Pheak Tra Live 02-09-2019

យោងតាមប្រភពពីសមត្ថកិច្ចថៃប្រចាំស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ កាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០១៩ នេះអោយដឹងថា កម្លាំងសមត្ថកិច្ចថៃបានធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរ ចំនួន១៨នាក់ ត្រង់ចំណុចបរិវេណបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្បែរផ្សាររោងគ្រឿយកទៅធ្វើការសាកសួរ។ ក្រោយពីធ្វើការសាកសួរសមត្ថកិច្ចថៃ បានរកឃើញពលរដ្ឋខ្មែរគ្មានឯកសារឆ្លងដែនចំនួន១៥នាក់។

តាមចម្លើយសារភាពរបស់ស្ត្រីឈ្មោះ សម អាយុ៤០ឆ្នាំ មានលិខិតឆ្លងដែន បានប្រាប់សមត្ថកិច្ចថៃថា ពួកគាត់នឹងពលរដ្ឋខ្មែរទាំងអស់ធ្វើការនៅក្នុងរោងចក្រផលិតខ្សែភ្លើងមួយកន្លែងនៅក្នុង ខេត្តឆាក់ឈើងសៅ ប្រទេសថៃ នៅថ្ងៃនេះ ពួកគាត់បាននាំកូននិងអ្នកដ៏ទៃទៀតធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតវិញ តាមរយៈច្រកព្រំដែនផ្សាររោងគ្លឿ ដោយមានមេខ្យល់ខ្មែរ២នាក់ ម្នាក់ឈ្មោះ តេក ខត អាយុ៣០ឆ្នាំ ទំនាក់ទំនងជាអ្នកនាំចេញទៅខាងប្រទេសកម្ពុជា ដោយយកថ្លៃនាំចេញម្នាក់ៗ ៥០០បាត។ ពួកគាត់បានយល់ព្រម ដំបូងត្រូវបង់ប្រាក់ម្នាក់២០០បាតសិន នៅពេលឆ្លងដល់ខ្មែរ ពួកគាត់បង់ម្នាក់៣០០បាតបន្ថែមទៀត ដោយមិនចាំបាច់តម្រង់ជួរឬមានឯកសារអ្វីទាំងអស់ ។ តាមការស្រាវជ្រាវរបស់សមត្ថកិច្ចថៃ បានឲ្យដឹងថា ក្រុមមេខ្យល់នេះតែងនាំមនុស្សខុសច្បាប់ចេញទៅខាងខ្មែរជាញឹកញាប់ ដោយមានបក្សពួកធ្វើការជាប្រព័ន្ធ ទាំងនាក់នាំចេញ និងអ្នកចាំចាក់សោទ្វារបងដែកក្បែរផ្លូវរថភ្លើងបើកអោយមនុស្សចេញទៅខ្មែរ ដោយទទួលសំណូកពីក្រុមមេខ្យល់ម្នាក់២០០បាត -៣០០បាត ។

បច្ចុប្បន្នពលរដ្ឋខ្មែរទាំង១៥នាក់ ត្រូវសមត្ថកិច្ចថៃបញ្ជូនទៅធ្វើប្រវត្តិរូបនៅអធិការដ្ឋានអន្តោប្រវេសន៍ ស្រុកអារញ្ញ រួចបញ្ជូនអោយវិលត្រឡប់ទៅស្រុកកំណើតវិញ។ រីឯស្ត្រីឈ្មោះ សម អាយុ៤០ឆ្នាំ ត្រូវសមត្ថកិច្ចថៃ ដោះលែងវិញ ព្រោះមានលិខិតឆ្លងដែនត្រឹមត្រូវ ចំណែកបក្សពួកមេខ្យល់ត្រូវសមត្ថកិច្ចថៃ ធ្វើការចោទប្រកាន់ពីបទធ្វើការដោយគ្មានប័ណ្ណអនុញ្ញាត និងលួចឆ្លងដែនដោយគ្មានច្បាប់អនុញ្ញាត។

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 02-09-2019

នាថ្ងៃចន្ទ ៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ ឱ្យទទួលបាននៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើររបស់បងប្អូនពលករ និងចំនួនថ្ងៃដែលបងប្អូនពលករត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជក/ថៅកែ។ ឆ្លៀតឱកាសនេះផងដែរ ឯកឧត្តមឯកអគ្គរាជទូត ក៏បានជួបសំណេះសំណាល និងផ្តាំផ្ញើការសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដល់បងប្អូនពលករទាំងអស់ ក៏ដូចជាការណែនាំអំពីសេវានៅស្ថានទូត អំពីច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃផងដែរ។

## ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៩

## លោក មហាធៀ សន្យាមើលថែការពារពលករកម្ពុជាដែលធ្វើការនៅម៉ាឡេស៊ី

https://cambonomist.com/ 04-09-2019 ដោយ ជ័យ ជំនះ

នាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក មហាធៀ មហាម៉ាត់ នៅថ្ងៃអង្គារ ទី៣ ខែកញ្ញា បានសន្យាថា អាជ្ញាធរប្រទេសរបស់លោកនឹងមើលថែរក្សាការពារជនជាតិកម្ពុជា ដែលកំពុងធ្វើការនៅទីនោះឲ្យបានល្អ តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន។ នាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក មហាធៀ មហាម៉ាត់ អញ្ជើញមកទស្សនកិច្ច ៣ថ្ងៃនៅកម្ពុជា ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ កញ្ញា ២០១៩។

លោក មហាធៀ ដែលមានអាយុ ៩៤ឆ្នាំនោះ មកបំពេញទស្សនកិច្ចផ្លូវការ៣ថ្ងៃ នៅកម្ពុជា ដែលបានចាប់ផ្តើមតាំងពីថ្ងៃចន្ទ ទី២ ខែកញ្ញាមក។ ថ្លែងបន្ទាប់ពីធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងអនុស្សរណៈយោគយល់គ្នាជាមួយសម្តេច ហ៊ុន សែន នៅវិមានសន្តិភាពរួចមក, លោក មហាធៀ បានអះអាងថា ម៉ាឡេស៊ីនឹងការពារ និងយកចិត្តទុកដាក់លើកម្មករកម្ពុជា។ លោក មហាធៀ បានមានប្រសាសន៍ដូច្នេះថា ៖ «យើងមានប្រជាជន

កម្ពុជាមួយចំនួនកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ី ហើយយើងមើលថែរក្សាសុខុមាលភាពរបស់ពួកគាត់ ដូច្នេះពួកគាត់នឹងទទួលបានអត្ថប្រយោជន៍ពេញលេញពីការងារដែលពួកគាត់ធ្វើនៅប្រទេសម៉ាឡេស៊ី។» លោក មហាធៀ បានបន្តថា «ទាក់ទងនឹងពលករកម្ពុជា យើងសង្ឃឹមថា នឹងអាចមើលថែរក្សាសុខុមាលភាពរបស់ពួកគាត់ ខណៈដែលពួកគាត់កំពុងស្ថិតនៅប្រទេសម៉ាឡេស៊ី។

នៅថ្ងៃអង្គារ ទី៣ ខែកញ្ញា មន្ត្រីកម្ពុជានិងម៉ាឡេស៊ី ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលុបបំបាត់ពន្ធទ្វេដងពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលនិងការទប់ស្កាត់ការគេចពន្ធ ផងដែរ។ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ ក៏ត្រូវបានចុះហត្ថលេខារវាងក្រសួងទេសចរណ៍កម្ពុជានិងក្រសួងការបរទេសម៉ាឡេស៊ីផងដែរ។ បន្ទាប់ពីពិធីចុះហត្ថលេខាហើយ លោក មហាធៀ ក៏បានសន្យាថា នឹងកាត់បន្ថយឱនភាពពាណិជ្ជកម្មជាមួយកម្ពុជាផងដែរ ដោយមានគោលបំណងពិនិត្យមើលលទ្ធភាពនៃការនាំចូលអង្ករនិងផ្លែឈើឱ្យបានច្រើនបន្ថែមទៀត ចូលទីផ្សារម៉ាឡេស៊ី។

សម្តេច ហ៊ុន សែន បាននិយាយថា ពាណិជ្ជកម្មទ្វេភាគីជាមួយម៉ាឡេស៊ី មានចំនួនទឹកប្រាក់ប្រមាណជា ៥០០លានដុល្លារ ក្នុងឆ្នាំ២០១៨ ហើយក្នុងរយៈពេល ៦ខែដំបូងនៃឆ្នាំនេះ ទំហំពាណិជ្ជកម្មបានកើនឡើងដល់ ជាង ៤០០លានដុល្លារ៕

## កម្ពុជា-ម៉ាឡេស៊ី សម្រេចរួមគ្នាថា ត្រូវពង្រឹងវិស័យសន្តិសុខ

https://thmeythmey.com/ 03, Sep 2019 , 8:19 pm ដោយ: ថ្មីៗ

នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន និង នាយករដ្ឋមន្ត្រីម៉ាឡេស៊ី បណ្ឌិត មហាធៀ មហាម៉ាត់ ទទួលស្គាល់ថា គម្រោងគំរាមកំហែងផ្នែកភេរវកម្មនិងភាពជ្រុលនិយមនៅទូទាំងពិភពលោក មានការកើនឡើង។ បញ្ហាភេរវកម្មនេះ គឺជាចំណុចមួយ ដែលមានសរសេរក្នុងសេចក្តីថ្លែងការណ៍រួម ក្រោយពីនាយករដ្ឋមន្ត្រីទាំងពីរ បានជួបគ្នា នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩។

បើតាមសេចក្តីថ្លែងការណ៍ សម្តេច ហ៊ុន សែន និង បណ្ឌិត មហាធៀ យល់ស្របជាមួយគ្នាថា «ការសម្របសម្រួលលើវិស័យសន្តិសុខ ចាំបាច់ត្រូវបង្កើនឲ្យកាន់តែប្រសើររវាងប្រទេសទាំងពីរ»។ សេចក្តីថ្លែងការណ៍ សរសេរដូច្នេះថាៈ«ថ្នាក់ដឹកនាំទាំងពីរ បានបញ្ជាក់អំពីសារសំខាន់ នៃកិច្ចសហប្រតិបត្តិការសន្តិសុខរវាងប្រទេសទាំងពីរ ជាពិសេសដើម្បីរក្សាសន្តិភាព ស្ថិរភាព និងដើម្បីទប់ស្កាត់បញ្ហាប្រឈមអសន្តិសុខ និងការគំរាមកំហែងក្នុងតំបន់» ។

ក្រៅពីការពង្រឹងសន្តិសុខ សេចក្តីថ្លែការណ៍ ក៏បានសរសេរដែរថា ប្រទេសទាំងពីរ បន្តពង្រឹងលើវិស័យផ្សេងៗទៀត ដូចជា ធុរកិច្ច ទេសចរណ៍ និង ការចំណាកស្រុក ជាដើម។ ដំណើរទស្សនិច្ចរបស់ បណ្ឌិត មហាធៀ នឹងត្រូវបញ្ចប់នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៩៕

## ក្រោយជំនួបៈសង្គមស៊ីវិលទទួលស្គាល់របាយការណ៍ស្តីពីមីក្រូហិរញ្ញវត្ថុ មិនឆ្លុះបញ្ចាំងពីស្ថានភាពទូទៅ

http://bayontv.com.kh/ 04/09/2019

ភ្នំពេញ ៖ នៅថ្ងៃទី៤ ខែមិថុនានេះ រដ្ឋាភិបាលកម្ពុជាតំណាងដោយអង្គភាពអ្នកនាំពាក្យ បានកោះហៅអង្គការលីកាដូ និងសមាគមជាងត្នោតមកជួបពិភាក្សាគ្នាក្រោយការចេញរបាយការណ៍ស្តីពីការប៉ះពាល់ជីវភាពពលរដ្ឋក្រោយកម្ចីឥណទានពីវិស័យមីក្រូហិរញ្ញវត្ថុ។ ក្រោយជំនួបអង្គការទាំងពីរទទួលស្គាល់ថាការស្រាវជ្រាវមិនគ្រប់ជ្រុងជ្រោយ និងជាការរកឃើញផ្នែកតូចមួយប៉ុណ្ណោះ។

អង្គការលីកាដូ និងសមាគមជាងត្នោតបានទទួលស្គាល់ពីភាពមិនគ្រប់ជ្រុងជ្រោយ នៃរបាយការណ៍របស់ខ្លួនស្តីពីផលប៉ះពាល់លើប្រជាពលរដ្ឋដោយសារតែកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានផ្សព្វផ្សាយកាលពីពេលថ្មីៗកន្លងទៅនេះ។ ការទទួលស្គាល់នេះគឺធ្វើឡើងក្រោយជំនួបរវាងអង្គភាពអ្នកនាំពាក្យរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គ

ការទាំងពីរដើម្បីស្វែងយល់ពីការពិតនៃការផ្សព្វផ្សាយរបាយការណ៍នេះ។ លោកអំ សំអាត អ្នកនាំពាក្យអង្គការលីកាដូ បានប្រាប់អ្នកសារព័ត៌មានថា របាយការណ៍របស់ខ្លួនបានសម្ភាសន៍មនុស្សតែ២៨នាក់ប៉ុណ្ណោះ ដែលរងផលប៉ះពាល់ដោយផ្ទាល់ក្នុងខ្ចីប៉ុលពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ប៉ុន្តែលោកថា របាយការណ៍នេះក៏ជាការពញ្ញាក់ដល់រដ្ឋាភិបាលពីផលប៉ះពាល់លើក្រុមគ្រួសារទាំង២៨តែប៉ុណ្ណោះ។

សូមរំលឹកថា អង្គការទាំងពីរខាងលើកាលពីដើមខែសីហា អង្គការការពារសិទ្ធិមនុស្សលីកាដូ និងសមាគមជាងត្នោត បានអះអាងថា ប្រជាពលរដ្ឋកម្ពុជាជាង ២លាននាក់បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ហើយប៉ុន្មានឆ្នាំចុងក្រោយនេះ កម្រិតនៃបំណុលរបស់ប្រជាពលរដ្ឋបានកើនឡើងកាន់តែខ្លាំងឡើងៗ ដែលនេះបណ្ដាលឱ្យអាចកើតមានការរំលោភបំពានសិទ្ធិមនុស្សជាច្រើន រួមមានការបង្ខំឱ្យលក់ដី ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ការធ្វើចំណាកស្រុកដោយសារបំណុល និងការបញ្ចាំខ្លួនដើម្បីដោះបំណុល។

ទន្ទឹមនឹងនេះ អង្គភាពអ្នកនាំពាក្យ បានអះអាងថា ការលើកឡើងពីហេតុផល នៃសំណាក់២៨ករណីតែប៉ុណ្ណោះ ដែលមានចរិតអត្តនោម័តិដែលមិនស្ថិតក្នុងតម្លៃសាកល និងមិនឆ្លុះបញ្ចាំងជារួមអំពីប្រតិបត្តិការផ្ដល់ទទួលប្រាក់កម្ចីឥណទាននិងស្ថានភាពទូទៅនៃបំណុលវណ្ណៈនោះទេ។ ទន្ទឹមនឹងនេះ អង្គភាពអ្នកនាំពាក្យ បានអំពាវនាវដល់រាល់បុគ្គល និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណា ក្នុងកិច្ចបញ្ចេញរបាយការណ៍ ឬព័ត៌មានជាសាធារណៈ ត្រូវគោរពនូវសិទ្ធិទទួលបានព័ត៌មានសុចរិតរបស់សាធារណជន ដែលមានមូលដ្ឋានពិត វិជ្ជាជីវៈ បែបវិទ្យាសាស្ត្រ និងតម្លៃបរិយាយដទៃទៀត ដើម្បីជាផលប្រយោជន៍ក្នុងការចូលរួមជាដៃគូ ក្នុងកិច្ចការពារកសាង មាតុភូមិ និងវប្បធម៌ដ៏បវររបស់ជាតិយើង៕ អត្ថបទ៖ គួន សំបូរ

## កម្ពុជា-អារ៉ាប៊ីសាអូឌីត នៅតែបន្តគិតគូរលើការបណ្ដុះបណ្ដាល និងបញ្ជូនពលករ

http://bayontv.com.kh/ 05/09/2019

ភ្នំពេញ ៖ ផ្អែកតាមកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារួមគ្នាកាលពី ឆ្នាំ២០១៦ គ្រាដែលរដ្ឋមន្ត្រីក្រសួងការងារបំពេញទស្សនកិច្ច នៅប្រទេសអារ៉ាប៊ីសាអូឌីត លើការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបម្រើការងារនៅទីនោះមក នៅព្រឹកថ្ងៃទី៥ កញ្ញា ឆ្នាំ២០១៩នេះ ក៏មានជំនួបពិភាក្សាលើបញ្ហានេះ ដើម្បីបន្តរៀបចំបណ្ដុះបណ្ដាល និងការបញ្ជូននេះ។

ប្រាប់ក្រុមអ្នកសារព័ត៌មានក្រោយជំនួបការងារជាមួយ ឯកឧត្តម សាអ៊ូឌ ហ្វៃសល មហាម៉ាត់ អាល់ស៊ូវ៉េឡិម (Saud F.M.AL Suwelim) ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតប្រចាំកម្ពុជា ដែលមាននិវេសនដ្ឋាន នៅវៀតណាម នៅទីស្ដីការក្រសួង ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា ក្រោយពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរួចមក ភាគីទាំងពីរ បានអនុវត្តន៍លើផ្នែកបច្ចេកទេស ដោយសម្របសម្រួល និងបំពេញបែបបទនីតិវិធី សម្រាប់ការបណ្ដុះបណ្ដាលលើការបញ្ជូន ដែលរហូតមកដល់ពេលនេះ យើងមានទីភ្នាក់ងារស្របច្បាប់ចំនួន៤០ ដោយសហការការងារជាមួយគ្នាបានយ៉ាងល្អ។ យ៉ាងណាក៏ដោយ ពលករកម្ពុជា បម្រើការងារនៅទីនោះ មានចំនួនតិចតួចនៅឡើយ ខណៈដែលពលករបរទេសកំពុងបម្រើការងារនៅអារ៉ាប៊ីសាអូឌីត មានរហូតដល់ជិត ១៥លាននាក់។ ក្នុងជំនួបនោះដែរ ឯកឧត្តមរដ្ឋមន្ត្រីការងារ បានជម្រាបជូនឯកអគ្គរាជទូត អំពីលទ្ធភាពនៃការទាក់ទាញទីផ្សារការងារ គឺផ្ដោតលើបញ្ហាប្រាក់ឈ្នួលដែលកន្លងមកប្រទេសមួយចំនួនបានទទួលពលករពីកម្ពុជាទៅបម្រើការងារក្នុងតម្លៃដ៏សមរម្យមួយ ដូចជាប្រទេសកូរ៉េ និងជប៉ុនជាដើម។

សូមបញ្ជាក់ផងដែរថា ទីផ្សារការងារសំខាន់ៗនៅប្រទេស អារ៉ាប៊ីសាអូឌីត មានដូចជា ឧស្សាហកម្ម សំណង់ និងការងារតាមផ្ទះដែលមានប្រាក់ឈ្នួលចន្លោះពី ៣០០ ដល់ ៥០០ដុល្លារ៕

## ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសំណេះសំណាលជាមួយបងប្អូនពលករខ្មែរដែលមកទទួលសេវាកម្មនៅស្ថានទូត

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 04-09-2019

ថ្ងៃពុធ ៦កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានសំណេះសំណាលជាមួយបងប្អូនពលករខ្មែរដែលមកទទួលសេវាកម្មនៅស្ថានទូត។ ឆ្លៀតក្នុងឱកាសនេះ ស្ថានទូតបានធ្វើការពន្យល់ណែនាំដល់ពួកគាត់ឱ្យបានយល់ដឹងអំពីច្បាប់ សិទ្ធិនិងអត្ថប្រយោជន៍ផ្សេងៗដែលទទួលបានភាពស្របច្បាប់មកស្នាក់នៅនិងធ្វើការនៅក្នុងប្រទេសថៃ។ ជាមួយគ្នានោះដែរ បងប្អូនពលករខ្មែរពិតជាមានការសប្បាយរីករាយ និងកក់ក្តៅយ៉ាងខ្លាំង ដែលស្ថានទូតក៏ដូចជារាជរដ្ឋាភិបាល ដែលតែងតែយកចិត្តទុកដាក់អំពីសុខទុក្ខរបស់ពួកគាត់។

## ជនរងគ្រោះដោយសារការជួញដូរមនុស្សនៅនីហ្សេរីយ៉ាកសាងជីវិតថ្មីឡើងវិញ

https://khmer.voanews.com/ 04 កញ្ញា 2019

អាប៊ូហ្សា៖ ទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសនីហ្សេរីយ៉ាកំពុងធ្វើមាតុភូមិនិវត្តន៍ និងការតាំងទីលំនៅឡើងវិញចំពោះស្ត្រីដែលរងគ្រោះដោយសារពលកម្មដោយបង្ខំ និងអំពើពេស្យាចារ ក្រោយពីត្រូវបានគេជួញដូរទៅកាន់ទ្វីបអឺរ៉ុប ដោយការសន្យាបោកប្រាស់ថានឹងផ្តល់ការងារប្រាក់ខែល្អឲ្យធ្វើ។ ស្ត្រីនីហ្សេរីយ៉ារាប់ពាន់នាក់ត្រូវបានគេជួញដូរនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ទោះបីជាអ្នកខ្លះមានសំណាងអាចត្រឡប់ទៅកាន់ប្រទេសកំណើតរបស់ខ្លួនវិញក៏ដោយ។ សម្រាប់នាង Beatrice អាយុ ៣៥ ឆ្នាំ វាគឺជាការផ្តល់ឲ្យដ៏ល្អមួយដែលនាងមិនអាចមិនទទួលយកមិនបាន ដែលនោះគឺការធ្វើការនៅឯកសិដ្ឋានដ៏ធំមួយនៅប្រទេសអ៊ីតាលី ដែលពួកអ្នកជួញដូរមនុស្សបានប្រាប់នាងកាលពីឆ្នាំ ២០១៣។ នាងយល់ព្រមទទួលយកការផ្តល់ឲ្យដែលជាអន្ទាក់នេះ ដោយគិតថា នាងអាចជួយឪពុកម្តាយរបស់នាងឲ្យរួចផុតពីភាពក្រីក្របាន ដោយការធ្វើការនៅឯបរទេស។ ប៉ុន្តែផ្ទុយទៅវិញ បន្ទាប់ពីត្រូវបានគេជួញដូរទៅដល់ប្រទេសអ៊ីតាលីក្រោមស្ថានភាពធ្វើដំណើរយ៉ាងលំបាកលំបិនមក នាងត្រូវបានគេបង្ខំឲ្យធ្វើជាស្ត្រីរកស៊ីផ្លូវភេទដើម្បីរកប្រាក់ឲ្យពួកអ្នកដែលជួញដូរនាង។ នាង Beatrice និយាយដូច្នេះថា៖ «មិត្តភ័ក្តិរបស់ខ្ញុំម្នាក់បានណែនាំខ្ញុំដោយនិយាយថា សូមមើលកន្លែងនេះចុះ អ្នកនឹងធ្វើការនៅឯកសិដ្ឋាននៅទីនោះ។ គាត់មិនបានប្រាប់ខ្ញុំថា ខ្ញុំនឹងធ្វើជាស្ត្រីរកស៊ីផ្លូវភេទនោះទេ។ ដូច្នេះ ខ្ញុំបាននិយាយថា ខ្ញុំចង់ធ្វើការនៅឯកសិដ្ឋាននោះ។ នៅទីបំផុត យើងបានធ្វើដំណើរឆ្លងកាត់ប្រទេសលីប៊ី ដោយជិះតាមនាវា។ មនុស្សជាច្រើននាក់បានស្លាប់»។ នាង Beatrice នៅទីនោះរយៈពេល ៤ ឆ្នាំ។ នាងមកពីរដ្ឋ Edo នៅភាគខាងត្បូងប្រទេសនីហ្សេរីយ៉ា។ រដ្ឋនេះត្រូវគេដឹងថាជារដ្ឋដែលមានស្ត្រីជាច្រើនត្រូវបានគេជួញដូរ។

ស្ត្រីជាង ១ ម៉ឺន ១ ពាន់នាក់នៃក្រុមស្ត្រីដែលត្រូវគេជួញដូរនេះ ត្រូវគេប៉ាន់ប្រមាណថា កំពុងធ្វើការជាទាសករផ្លូវភេទនៅក្នុងប្រទេសអ៊ីតាលី។ នាង Beatrice និយាយថា ការឈឺចាប់របស់នាងគឺមិនអាចទ្រាំបាននោះទេ។ នាងបញ្ជាក់ដូច្នេះថា៖ «ប្រសិនបើអ្នករកលុយមិនបានទេ ពួកគេនឹងវាយដំអ្នក ឬក៏ធ្វើបាបតាមវិធីផ្សេងៗ។ ពួកគេនឹងញីម្ទេសស្រស់ៗលើភ្នែករបស់អ្នក។ ពួកគេឲ្យយើងដាក់ម្ទេសនោះចូលក្នុងប្រដាប់ភេទរបស់យើង។ ទោះបីជាអ្នកមករដូវក៏ដោយ ក៏អ្នកត្រូវតែចេញទៅធ្វើជាអ្នករកស៊ីផ្លូវភេទដែរ»។

អង្គការសហប្រជាជាតិបានបញ្ជាក់ថា ស្ត្រីមានចំនួនជាងពាក់កណ្តាលនៃមនុស្សរាប់ពាន់នាក់ ដែលត្រូវបានគេជួញដូរពីទ្វីបអាហ្វ្រិកទៅកាន់ទ្វីបអឺរ៉ុបជារៀងរាល់ឆ្នាំ។ ប៉ុន្តែ បុរសនីហ្សេរីយ៉ាក៏ជាជនរងគ្រោះនៃការជួញដូរមនុស្ស និងពលកម្មដោយបង្ខំផងដែរ។ លោក Chukwuemeka Asiegbu អាយុ ៤៥ ឆ្នាំ បានចំណាយពេល ៦ ឆ្នាំ នៅប្រទេសលីប៊ី និងបានរត់គេចប៉ិះនឹងអស់ជីវិត។ បន្ទាប់ពីលោកបានត្រឡប់ទៅដល់ប្រទេសនីហ្សេរីយ៉ាវិញ លោកបាន

ចាប់ផ្តើមបង្កើតក្រុមតស៊ូមតិមួយដើម្បីសិទ្ធិរបស់ជនរងគ្រោះដោយសារការជួញដូរ។ លោក Chukwuemeka Asiegbu និយាយដូច្នេះថា៖ «អ្នកជួញដូរមនុស្សធ្វើអ្វីដើម្បីបំពេញតម្រូវការខ្លួនឯង។ តើវាមិនប៉ះពាល់ដល់អ្នកដទៃមែនទេ? តាមពិត យើងរកឃើញថា ការជួញដូរមនុស្សគឺប៉ះពាល់ដល់អ្នកដទៃ។ វាជារោគរាតត្បាត។ វាជាមហន្តរាយដោយសារតែអ្នកជួញដូរមនុស្សបំពេញតម្រូវការខ្លួនឯង ទោះបីជាធ្វើឲ្យខូចប្រយោជន៍ដល់ជីវិតរស់នៅរបស់អ្នកដទៃក៏ដោយ»។

ទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសនីហ្សេរីយ៉ា ដែលហៅកាត់ថា NAPTIP ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៣ ដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្សនេះ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ទីភ្នាក់ងារនេះសម្រេចបានកិច្ចការមួយចំនួននៅក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការតាំងទីលំនៅឡើងវិញដល់ជនរងគ្រោះ។ នេះបើតាមការបញ្ជាក់របស់លោក Arinze Orakwe ប្រធានផ្នែកអប់រំសាធារណៈនៃទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសនីហ្សេរីយ៉ា។ លោកបញ្ជាក់ដូច្នេះថា៖ «ការជួញដូរមនុស្សជាអំពើឧក្រិដ្ឋដែលធ្វើឲ្យប្រទេសនីហ្សេរីយ៉ាមានកេរ្តិ៍ឈ្មោះមិនល្អ។ វាជាអំពើឧក្រិដ្ឋដែលពួកយើងគ្មានមោទនភាពជាមួយនោះទេ។ រដ្ឋាភិបាលគិតថា រឿងរ៉ាវនៃការជួញដូរមនុស្សនេះគឺជារឿងសំខាន់ ដែលយើងត្រូវតែរកដំណោះស្រាយចំពោះរឿងនេះ»។ ដោយមានជំនួយពីទីភ្នាក់ងារប្រឆាំងការជួញដូរមនុស្ស ជនរងគ្រោះដូចជានាង Beatrice ជាដើម កំពុងចាប់ផ្តើមជីវិតជាថ្មីឡើងវិញ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ។ ឥឡូវនេះ នាង Beatrice មានហាងលក់ម្ហូបអាហារផ្ទាល់ខ្លួននៅឯស្រុកកំណើតរបស់នាង៕ *ប្រែសម្រួលដោយ គី សុភាជា*

# ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៩

## ក្រសួងយុត្តិធម៌សម្រេចឲ្យបង្កកទ្រព្យសម្បត្តិបទល្មើសគ្រឿងញៀន ព្រៃឈើ ជួញដូរមនុស្ស និងបទល្មើសសំអាតប្រាក់

http://khmer.peoplenews.asia/ ដោយ ៖ SOVANNA ROTH ថ្ងៃទី07 ខែ09 ឆ្នាំ2019 ម៉ោង 3:34 PM

ភ្នំពេញៈ យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រាយការណ៍ជូនសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី៤កញ្ញា កន្លងទៅ បានឲ្យដឹងថា ក្រសួងយុត្តិធម៌ បានសម្រេចយល់ព្រមលើវិធានការពីរចម្បងៗ គឺវិធានការបង្កកទ្រព្យសម្បត្តិ នៃបទល្មើសគ្រឿងញៀនក្នុងក្លឹបកំសាន្ត និងសំណុំរឿងគ្រឿងញៀនធំៗ ព្រមទាំងវិធានការចំពោះបទល្មើសព្រៃឈើ ជួញដូរមនុស្ស និងបទល្មើសសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ក្នុងលិខិតរបស់ លោក អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានរាយការណ៍ជូនសម្តេចក្រឡាហោម ស ខេង ថា កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ លោកបានដឹកនាំកិច្ចប្រជុំពិភាក្សាអំពីនីតិវិធីនៃការចាប់យក ការបង្កក និងការរឹបអូសទ្រព្យសម្បត្តិដែលបានមកពីបទល្មើសព្រៃឈើ គ្រឿងញៀន និងជួញដូមនុស្ស នៅទីស្តីការក្រសួងយុត្តិធម៌ ដែលមានអ្នកចូលរួមមកពីក្រសួងមហាផ្ទៃ អង្គភាពប្រឆាំងអំពើពុករលួយ គណៈកម្មការជាតិប្រឆាំងនឹងការជួញដូរមនុស្ស សាលាឧទ្ធរណ៍ មហាអយ្យការអមសាលាឧទ្ធរណ៍ កងរាជអាវុធហត្ថ អគ្គស្នងការដ្ឋាននគរបាលជាតិអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ជាលទ្ធផល អង្គប្រជុំបានសម្រេចយល់ព្រមលើវិធានការ ០២ចម្បងៗ ៖ វិធានការបង្កកទ្រព្យសម្បត្តិនៃបទល្មើសគ្រឿងញៀនក្នុងខ្លឹបកម្សាន្ត និងសំណុំរឿងគ្រឿងញៀនធំៗ ព្រមទាំងវិធានការចំពោះ បទល្មើសព្រៃឈើ ជួញដូមនុស្សនិងបទល្មើសសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ វិធានការបង្កក ទ្រព្យសម្បត្តិនៃបទល្មើសគ្រឿងញៀន ដែលមានស្រាប់៖ អង្គប្រជុំបានឯកភាពជូនអគ្គស្នងការនគរបាលជាតិ ស្នើសុំទៅព្រះរាជអាជ្ញា ដើម្បីចាត់នីតិវិធីបង្កក

ទ្រព្យសម្បត្តិដែលពាក់ព័ន្ធបទល្មើសគ្រឿងញៀន របស់ក្លឹបកម្សាន្តចំនួន០៦. ដែលស្ថិតក្នុងចំណាត់ការរបស់តុលាការស្រាប់ (រាជធានីភ្នំពេញ ៖ ០៣ទីតាំង ខេត្តសៀមរាប ៖ ០១ទីតាំង ខេត្តព្រះសីហនុ ៖០១ទីតាំង និងខេត្តបន្ទាយមានជ័យ ៖ ០១ទីតាំង)។

អគ្គស្នងការនគរបាលជាតិ និងស្រាវជ្រាវសំណុំរឿងគ្រឿងញៀនធំៗផ្សេងទៀតដែលមានស្រាប់ ដើម្បីបញ្ជូលទៅតុលាការ។ តុលាការ នឹងធ្វើការជាមួយអគ្គស្នងការនគរបាលជាតិ ដើម្បីស្រាវជ្រាវរកទ្រព្យសម្បត្តិដែលពាក់ព័ន្ធ និងដើម្បីចាត់នីតិវិធីបង្កក ដោយអនុលោមតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ចំណែកវិធានការចំពោះបទល្មើសព្រៃឈើ ជួញដូរមនុស្ស និងសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម៖ ចំពោះបទល្មើសព្រៃឈើ ជួញដូរមនុស្ស និង សំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គប្រជុំបានឯកភាពគ្នាដើម្បីចាត់នីតិវិធីក្នុងការបង្កកទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសទាំងនេះ ដោយប្រគល់តួនាទីចម្បងទៅម្ចាស់ករណីដែលជាមន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកស្នើសុំទៅតុលាការដើម្បីចាត់នីតិវិធី ស្របតាមខ្លឹមសារនៃមាត្រា៣០ថ្មី១នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

ដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការអនុវត្ត ក្រសួងយុត្តិធម៌នឹងរៀបចំគោលការណ៍ណែនាំអនុវត្តខ្លឹមសារនៃមាត្រា៣០ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ហាងចិនម៉ាស្សាបង្កប់សេវាផ្លូវភេទ៤កន្លែង ត្រូវបានកម្លាំងកងរាជអាវុធហត្ថឃាត់មនុស្សប្រុស ស្រី ចំនួន២៩នាក់

http://www.rasmeinews.com/ September 9, 2019, 8:43 AM

ដោយៈចាន់តូ/ភ្នំពេញ ៖ នៅវេលាម៉ោង៨ និង៤០នាទីយប់ ថ្ងៃអាទិត្យទី៨ ខែកញ្ញា ឆ្នាំ២០១៩ ក៏មានកម្លាំងកងរាជអាវុធហត្ថរាជធានីភ្នំពេញសហការជាមួយកម្លាំងកងរាជអាវុធហត្ថខណ្ឌពោធិ៍សែនជ័យបាន ចុះបង្ក្រាបហាងម៉ាស្សាចិនចំនួន៤កន្លែងបង្កប់សេវាផ្លូវភេទឃាត់ជនជាតិចិននិងវៀតណាម ប្រុស ស្រី ចំនួន២៩នាក់។ នៅចំណុចហាងម៉ាស្សា៤កន្លែងជិតៗគ្នា ដែលទីតាំងទី១ មានយីហោ កន្លែងសំរាកកាយ ទី២យីហោ អេស៊ាងទីស្បាម៉ាស្សាទី៣ យីហោ សំរាកលំហែរម៉ាស្សា ទី៤មានយីហោម៉ាស្សាផ្ទះក្រហម ទីតាំងទាំង៤ នៅផ្លូវ លេខ១១៣k ភូមិព្រៃទា១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ តាមប្រភពព័ត៌មានពីកន្លែងកើតហេតុបានឲ្យដឹងថា ទីតាំងខាងលើជារបស់ជនជាតិចិនជួលបើកហាង យីហោខាងលើដោយមានបុគ្គលិកនារីៗជាជនជាតិចិននិងវៀតណាមជាច្រើនដោយសង្ស័យទីតាំងខាងលើបង្កបសេវាផ្លូវភេទ។

ក្រោយពីទទួលដំណឹងពីប្រជាពលរដ្ឋកម្លាំងកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានធ្វើការសើបអង្កេតហូតចុះទៅបង្ក្រាប ជាកស្តែងតែម្តង។ ក្នុងប្រតិបត្តិការខាងលើនេះកម្លាំងកងរាជអាវុធហត្ថធ្វើការឃាត់ខ្លួនមនុស្សប្រុសស្រីចំនួន២៩នាក់ ក្នុងនោះនារីចំនួន១៧នាក់ ជនជាតិចិន១៤នាក់ វៀតណាម៣នាក់ និងបុរសជនជាតិចិន១២នាក់ ផងដែរ។ ការចុះបង្ក្រាបទីតាំងខាងលើបញ្ចប់ទៅវិញនៅវេលាម៉ោង១២ និង២០នាទីយប់ រំលងអធ្រាត្រឈានចូលថ្ងៃច័ន្ទទី៩ ខែកញ្ញា ឆ្នាំ២០១៩ដោយជោគជ័យ។ ក្រោយឃាត់ខ្លួនជនសង្ស័យខាងលើកម្លាំងបាននាំខ្លួនទៅទីបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ដើម្បីកសាងសំណុំរឿងចាត់ការតាមច្បាប់។ ដោយឡែកទីតាំងទាំង៤ខាងលើត្រូវបានបិតបណ្តោះអាសន្ន៕B/

## បទល្មើសជំរិតទារប្រាក់ប្រើប្រាស់រូបភាពឬថតវិដេអូអាសអាភាសកំពុងកើតមាននៅកម្ពុជា

http://www.rasmeinews.com/ September 6, 2019, 11:59 AM

*ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ* នាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងមហាផ្ទៃ បានឲ្យដឹងថា បច្ចុប្បន្នសង្កេតឃើញមានករណីថតរូបភាព ឬវីដេអូអាសអាភាសគំរាមទារប្រាក់ (Sex Extortion) ជាច្រើនកំពុងកើតមានឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ជនល្មើសបានប្រើប្រាស់មធ្យោបាយប្រើប្រាស់នារីស្អាតៗ ដើម្បីទាក់ទាញជនរងគ្រោះ ធ្វើការសន្ទនាអនឡាញ ប្រើប្រាស់សកម្មភាពស្រើបស្រាលអូសទាញជនរងគ្រោះប្រព្រឹត្តសកម្មភាពរួមភេទ មុខកុំព្យូទ័រ ឬទូរស័ព្ទដៃ និងធ្វើការថតសកម្មភាពទាំងនោះ គំរាមទារប្រាក់។ នាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងមហាផ្ទៃបានបន្តថា ជនល្មើសបានប្រើប្រាស់ប្រើប្រាស់នារីស្អាតៗ ដើម្បីទាក់ទាញជនរងគ្រោះ ធ្វើការសន្ទនាអនឡាញ ប្រើប្រាស់សកម្មភាពស្រើបស្រាល អូសទាញជនរងគ្រោះប្រព្រឹត្តសកម្មភាពរួមភេទ មុខកុំព្យូទ័រ ឬទូរស័ព្ទដៃ និងធ្វើការថតសកម្មភាពទាំងនោះ គំរាមទារប្រាក់ ដោយបានប្រើមធ្យោបាយមួយចំនួនដូចជាៈ

មធ្យោបាយទី១. ប្រើប្រាស់នារីស្អាតៗ ដើម្បីទាក់ទាញជនរងគ្រោះ ធ្វើការសន្ទនាអនឡាញ ប្រើប្រាស់សកម្មភាពស្រើបស្រាល អូសទាញជនរងគ្រោះប្រព្រឹត្តសកម្មភាពរួមភេទ មុខកុំព្យូទ័រ ឬទូរស័ព្ទដៃ និងធ្វើការថតសកម្មភាពទាំងនោះ គំរាមទារប្រាក់។

មធ្យោបាយទី២. ប្រើប្រាស់គេហទំព័រអាសអាភាស បញ្ចូលកម្មវិធីសន្ទនាអនឡាញ ឬផ្ទាំងបើកវីដេអូ ដែលបញ្ជា Webcam ដើម្បីលួចថតសកម្មភាពជនរងគ្រោះ និងធ្វើការគំរាមទារប្រាក់។

មធ្យោបាយទី៣. ប្រើប្រាស់មធ្យោបាយផ្សេងៗ ក្នុងការចម្លងមេរោគទៅកាន់ម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទដៃ ប្រើប្រាស់ Webcam ថតសកម្មភាពផ្សេងៗ និងធ្វើការគំរាមទារប្រាក់។

នាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងមហាផ្ទៃបានបញ្ជាក់ថា ប្រសិនជួបករណី ដូចជម្រាបជូនខាងលើនេះ គឺ១. អញ្ជើញជួបជាមួយមន្ត្រីជំនាញ ដើម្បីធ្វើការប្រឹក្សា ដាក់ពាក្យបណ្តឹង និងស្វែងរកជនល្មើស។ ២. ការបង់ប្រាក់មិនមែនជាមធ្យោបាយ ព្រោះអ្នកនឹងត្រូវបង់បន្តបន្ទាប់។ ៣. ធ្វើការបិទគណនីបណ្តាញសង្គមបណ្តោះអាសន្ន។ ៤. ប្រើប្រាស់កម្មវិធីកម្ចាត់មេរោគ ស្កេន និងសម្អាតមេរោគក្នុងម៉ាស៊ីនកុំព្យូទ័រ ឬទូរស័ព្ទដៃ។ ៥. ប្រើប្រាស់ Sticker បិទ Webcam នៅពេលមិនប្រើប្រាស់៕*សរន*

## សមត្ថកិច្ចថៃ បានបញ្ជូនពលរដ្ឋកម្ពុជាចំនួន ០៥នាក់ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ General Department of Immigration – GDI 08-09-2019

នៅច្រកទ្វារតំបន់ព្រំដែនអានសេះ ខេត្តព្រះវិហារ នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៣ និង៣០ នាទី សមត្ថកិច្ចថៃ បានបញ្ជូនពលរដ្ឋកម្ពុជាចំនួន ០៥នាក់ ពីបទឆ្លងដែនខុសច្បាប់។ សមត្ថកិច្ចបានឲ្យដឹងថា ជនជាតិខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ ពើ ហោន ភេទប្រុស អាយុ ៥៧ឆ្នាំ, ២-ឈ្មោះ ជិន ធឿន ភេទប្រុស អាយុ ៥៨ឆ្នាំ, ៣-ឈ្មោះ សៀក លៀង ភេទប្រុស អាយុ ៤០ឆ្នាំ, ៤-ឈ្មោះ ហុង រ៉ាចា ភេទប្រុស អាយុ ២៥ឆ្នាំ ហើយអ្នកទាំង០៤ខាងលើ មានទីលំនៅក្នុងឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និង៥-ឈ្មោះ ដេន សុខណា ភេទប្រុស អាយុ ២៧ឆ្នាំ ទីលំនៅភូមិកសាង ឃុំចង្រ្កង ស្រុកចិត្របុរី ខេត្តក្រចេះ ។ ជនជាតិខ្មែរទាំង ០៥នាក់នេះ ត្រូវបានសមត្ថកិច្ចយកទៅអប់រំ រួចឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ ដោយខ្លួនឯងនៅល្ងាចថ្ងៃដដែល៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃ ចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 09-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦ នាក់នេះ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ ០៣នាក់ ស្រី០១នាក់ និងខេត្តសៀមរាប០៣នាក់ ស្រី០១នាក់៕

## នារីប្រេស៊ីលមួយក្រុម ចាញ់បោកការល្បួងថា នឹងក្លាយទៅជាតារា K-Pop ចុងក្រោយបែរជាត្រូវគេចាប់ធ្វើជានារីបម្រើផ្លូវភេទនៅកូរ៉េទៅវិញ

https://www.khmerload.com/ ហុង, Khmerload 10:20 September 07, 2019

កូរ៉េខាងត្បូង៖ នារីជនជាតិប្រេស៊ីលមួយក្រុម ត្រូវចាញ់បោកការល្បួងថា នឹងក្លាយទៅជាតារា K-Pop ពេលមកប្រទេសកូរ៉េខាងត្បូង ប៉ុន្តែចុងក្រោយបែរជាត្រូវគេចាប់ឱ្យធ្វើជានារីបម្រើផ្លូវភេទទៅវិញ។ យោងតាមប្រភព CNN បានឱ្យដឹងថា នារីជនជាតិប្រេស៊ីល ៧នាក់ ក្នុងនោះរួមមាន អ្នកដែលមានវ័យជាង២០ និង៣០ឆ្នាំ ត្រូវបានចាញ់បោកការល្បួងរបស់បុរសម្នាក់នៅលើបណ្តាញសង្គមថាឱ្យពួកគេមកប្រទេសកូរ៉េខាងត្បូង ដោយចេញថ្លៃសំបុត្រយន្តហោះឱ្យពួកគេថែមទៀត ហើយពួកគេនឹងមានឱកាស ក្លាយទៅជាតារាបង្ហាញម៉ូត ឬតារាចម្រៀង K-pop ទៀតផង។

យ៉ាងណាមិញ រឿងគឺមិនល្អដូចជាការគិតនោះទេ។ ជាក់ស្តែង ស្រីៗទាំងនោះត្រូវបានគេចាប់បង្ខំឱ្យធ្វើជានារីបម្រើផ្លូវភេទនៅក្នុងប្រទេសកូរ៉េខាងត្បូងទៅវិញ។ បន្ថែមពីនេះទៀត លិខិតឆ្លងដែនរបស់ពួកគេក៏ត្រូវបានជនខិលខូចដកហូត និងចាប់ឃុំពួកគេនៅក្នុងផ្ទះពីរកន្លែងក្នុងទីក្រុង Ilsan និង Paju ផងដែរ។ ក្រោយមក ពួកគេក៏ត្រូវបានគេចាប់យកទៅលក់ឱ្យផ្ទះបន ដោយម្នាក់ក្នុងតម្លៃ ២លានវ៉ុន (១,៦៧៨ដុល្លារ)។ យ៉ាងណាមិញ ក៏មាននារីរងគ្រោះម្នាក់បានរត់គេចខ្លួនបាន ហើយក៏បានប្តឹងរឿងនេះទៅស្ថានទូតប្រេស៊ីល ក្នុងប្រទេសកូរ៉េខាងត្បូង ហើយក៏ត្រូវបានសមត្ថកិច្ចមកជួយជនរងគ្រោះផ្សេងទៀតទាន់ពេលវេលាផងដែរ។ សមត្ថកិច្ចបានចាប់ខ្លួនជនខិលខូចបានចំនួន៩នាក់ ដែលជាប់ពាក់ព័ន្ធទៅនឹងការជួញដូរផ្លូវភេទនេះ។ បច្ចុប្បន្ន សមត្ថកិច្ចក៏កំពុងតែស៊ើបអង្កេតបន្ថែមទៀតជុំវិញករណីមួយនេះផងដែរ។ សមត្ថកិច្ចបាននិយាយថា៖ «យើងគិតថា រឿងនេះអាចនឹងជាប់ពាក់ព័ន្ធទៅនឹងមនុស្សដទៃទៀត ហើយអាចនឹងមានមនុស្សមានអំណាចនៅលើ ជាអ្នកនៅពីក្រោយខ្នងរឿងនេះក៏ថាបានដែរ។» សមត្ថកិច្ចបន្ថែមទៀតថា នេះគឺជាករណីដ៏កម្រដែលឃើញជនរងគ្រោះមកពីប្រេស៊ីលត្រូវបានចាញ់បោកគេ ក្លាយទៅជាជនរងគ្រោះជួញដូរផ្លូវភេទនៅក្នុងប្រទេសកូរ៉េខាងត្បូង៕

## ស្ត្រីអាមេរិចម្នាក់ ត្រូវចាប់ខ្លួនពីបទជួញដូរទារកនៅប្រទេសហ្វីលីពីន និងប្រឈមជាប់គុកមួយជីវិត

http://www.cen.com.kh/ September 6, 2019

ស្ត្រីជនជាតិអាមេរិចម្នាក់ ត្រូវបានប៉ូលីសចាប់ខ្លួន និងចោទប្រកាន់ពីបទជួញដូរមនុស្សក្នុងប្រទេសហ្វីលីពីន ក្រោយពេលនាងប៉ុនប៉ងលាក់ទារកទើបនឹងកើតក្នុងកាបូបយួរ ដើម្បីចេញពីប្រទេសហ្វីលីពីន។ ជនជាប់ចោទខាងលើមានឈ្មោះថា Jennifer Talbot វ័យ ៤៣ឆ្នាំ។ គាត់ត្រូវបានចាប់ខ្លួននៅព្រលានយន្តហោះអន្តរជាតិ Ninoy Aquino ក្នុងទីក្រុងមានីល កាលពីថ្ងៃពុធកន្លងទៅនេះ។ នាងត្រូវចាប់ខ្លួន ក្រោយពេលប៉ូលីសបានរកឃើញទារកអាយុ ៦ថ្ងៃម្នាក់នៅក្នុងកាបូបយួររបស់នាង ខណៈដែលនាងមានបំណងឡើងយន្តហោះ ទៅកាន់អាមេរិច។

អាជ្ញាធរបានធ្វើការចោទប្រកាន់ថា ស្រ្តីខាងលើមិនបានប្រកាសថាគាត់មានទារកទៅឲ្យខាងមន្ត្រីអន្តោប្រវេសន៍ដឹងនោះទេ។ ចំណែកឪពុកម្តាយរបស់ទារកខាងលើ ក៏ត្រូវបានចាប់ខ្លួន និងរងការចោទប្រកាន់ក្រោមច្បាប់ការពារកុមារ។ ស្រ្តីអាមេរិចនោះអាចប្រឈមនឹងការជាប់ពន្ធនាគារមួយជីវិត ប្រសិនជារកឃើញថាមានកំហុសដូចការចោទប្រកាន់។ នេះបើតាមការបញ្ជាក់របស់ប្រធានការិយាល័យស៊ើបអង្កេតរបស់ហ្វីលីពីន ថ្លែងប្រាប់អ្នកសារព័ត៌មាន។ បន្ទាប់ពីមានការចាប់ខ្លួន ស្រ្តីអាមេរិចរូបនោះ បានបង្ហាញឯកសារដែលនាងអះអាងថា មានការយល់ព្រមឲ្យនាងយកទារកនោះទៅកាន់អាមេរិចបាន។ នេះបើតាមការបញ្ជាក់របស់ការិយាល័យស៊ើបអង្កេត។ ប៉ុន្តែឯកសារដែលបង្ហាញដោយជនជាប់ចោទ មិនមានការចុះហត្ថលេខាដោយម្តាយរបស់ទារកឡើយ៕ ប្រែសម្រួល៖ សុភ័ក្រ ប្រភព៖ BBC

# ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៩

## យុទ្ធនាការទប់ស្កាត់ពលកម្មកុមារក្នុងសិប្បកម្មផលិតឥដ្ឋ បន្តចុះដល់ ៥0 ទីតាំងទៀត ក្នុងខេត្តកំពង់ចាម ត្បូងឃ្មុំ និងក្រចេះ

http://www.cen.com.kh/ September 10, 2019

កំពង់ចាម៖ ក្រសួងការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈ បានថ្ងៃទី៩កញ្ញា បានប្រកាសថា យុទ្ធនាការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នៅតែបន្តអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងបានចុះទៅដល់ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ដើម្បីលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការងារ និងយុទ្ធនាការសហគមន៍ផលិតឥដ្ឋគ្មានពលកម្មកុមារ នៅឆ្នាំ២០២០។ ការយុទ្ធនាការក្នុងខេត្តទាំងបីនេះ គឺបានចុះទៅដល់សិប្បកម្មផលិតឥដ្ឋចំនួន ៥0ទីតាំង គិតចាប់ពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ មក។

លោកវ៉េង ហៀង ប្រធាននាយកដ្ឋានការងារកុមារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំក្រុមការងារចុះយុទ្ធនាការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ដោយបានប្រាប់ពីវឌ្ឍនភាពលទ្ធខណ្ឌការងារល្អៗ មានជាអាទិ៍៖ ការយល់ដឹងអំពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងចំណោមនិយោជក កម្មករនិយោជិត ក្រុមគ្រួសារ និងសហគមន៍នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងឆ្នាំ២០១៦។ គ្រប់សិប្បកម្មផលិតឥដ្ឋទាំងអស់មិនមានប្រើប្រាស់ពលកម្មកុមារនោះទេ និងនិយោជកប្រមាណ ១០ភាគរយ មានសញ្ញាហាមប្រើប្រាស់កុមារអាយុក្រោម១៥ឆ្នាំ។ គ្រប់សិប្បកម្មទាំងអស់បានប្រើប្រាស់ឧសមិនប៉ះពាល់ដល់បរិស្ថាន។ គ្មានការកាត់បំណុល ការដាក់បន្ទុកសេរីភាពកម្មករនិយោជិត ការងារដោយបង្ខំ និងទាសភាពបំណុល ឬអន្ទាក់បំណុលនោះទេ។ ម៉ាស៊ីនផលិតដុំឥដ្ឋនៅមិនទាន់មានលក្ខណៈស្វ័យប្រវត្តិនៅឡើយ។ នាអំឡុងពេលចុះយុទ្ធនាការនេះផងដែរ និយោជក និងសហគមន៍ផលិតឥដ្ឋទាំងអស់ បានប្តេជ្ញាជំរុញឱ្យកុមារទទួលបានការអប់រំ បណ្តុះបណ្តាលជំនាញ និងទប់ស្កាត់គ្រោះថ្នាក់ការងារ ក៏ដូចជាការប្រើប្រាស់ពលកម្មកុមារនៅក្នុងសិប្បកម្មផលិតផលឥដ្ឋ។ លោក វ៉េង ហៀង បានបញ្ជាក់ទៀតថា យុទ្ធនាការនេះនឹងបន្តទៅទូទាំងរាជធានី-ខេត្ត ដែលមានសិប្បកម្មផលិតឥដ្ឋដោយមិនលើកលែង និងគ្មានការយោគយល់ឡើយ៕ ដោយ៖កូឡាប

## កម្ពុជាបានពិន្ទុខ្ពស់ជាងគេ ក្នុងចំណោម១៦ប្រទេស ដែលបញ្ជូនពលករទៅធ្វើការងារនៅប្រទេសកូរ៉េ

http://www.freshnewsasia.com/ 2019-09-09

**(ភ្នំពេញ)៖** ក្នុងចំណោមប្រទេសចំនួន១៦ ដែលបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង កម្ពុជាកំពុងទទួលបានពិន្ទុខ្ពស់ជាងគេ គឺល្អប្រសើរជាងគេ ក្នុងការផ្តល់សេវាស្វែងរកទីផ្សារការងារជូនពលរដ្ឋខ្លួន នៅប្រទេសកូរ៉េខាងត្បូង។

**លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានដឹកនាំគណៈប្រតិភូ ចូលរួមប្រជុំប្រចាំឆ្នាំលើកទី១៥ នៃសន្និសីទ EPS នៅប្រទេសកូរ៉េ ជាមួយនឹង ប្រទេសទាំង១៥ផ្សេងទៀត នាថ្មីៗនេះ បានអះអាងថា លក្ខណៈល្អប្រសើរជាងគេរបស់កម្ពុជា ក្នុងការផ្តល់សេវាទាំងនេះមានដូចជា៖**

**១៖** រយៈពេលធ្លាក់កិច្ចសន្យា រហូតដល់ថ្ងៃចេញដំណើរដល់កូរ៉េ តិចជាងគេ គឺត្រឹម ៤១ថ្ងៃ ក្នុងខណៈពេលរយៈពេលមធ្យមនៃប្រទេសផ្សេងទៀតមានចំនួន ៤៨ថ្ងៃ។

**២៖** អត្រាពលករផ្លាស់ប្តូរថៅកែ ក្នុងរយៈពេល៣ខែដំបូង ក្រោយពេលចូលធ្វើការ ទាបជាងគេ។

**៣៖** អត្រាពលកររស់នៅខុសច្បាប់មានចំនួនតិចជាងមធ្យមភាគ។

**៤៖** មានសេវាចំណាយ គិតចាប់ពីពេលប្រឡងជាប់ រហូតដល់ពេលចេញដំណើរ (១០៥៧$) តិចជាងចំណាយមធ្យមភាគនៃប្រទេសផ្សេងទៀត (១០៩៧$) ជាពិសេស មិនមានការតម្រូវឲ្យពលករ ឬក្រុមគ្រួសារពលករដាក់ប្រាក់តម្កល់ចំនួនពី ៥០០០$ (ប្រាំពាន់ដុល្លារ ដូចនៅវៀតណាម និងទីម័រខាងកើត) ទៅ ៣៦០០០$ (បីម៉ឺនប្រាំមួយពាន់ដុល្លារ ដូចប្រទេសបង់ក្លាដេស) និងមានចំណាត់ការផ្នែកច្បាប់ ដោយហាមឃាត់គ្រួសារពលករមិនឲ្យចេញទៅក្រៅប្រទេស ប្រសិនជាពលកររត់គេច រស់នៅខុសច្បាប់នៅកូរ៉េ។ នេះជាចំណុចដែល HRD Korea ចង់ឲ្យបណ្តាប្រទេសផ្សេងទៀតផ្តោតលើការអប់រំសតិអារម្មណ៍ដល់ពលករប្រសើរជាងការដាក់ប្រាក់តម្កល់ ឬការគំរាមកំហែងផ្នែកច្បាប់ទៅលើសមាជិកក្រុមគ្រួសារដែលមានពលកររត់គេច។

**៥៖** មានប្រព័ន្ធប្រឡងតេស្តសមត្ថភាពភាសាកូរ៉េតាមកុំព្យូទ័រធំជាងគេ។

**៦៖** មានសេវាអមពលកររហូតដល់និយោជកមកទទួលល្អ ដែលជាហេតុធ្វើឲ្យនិយោជកមិនដែលអន់ចិត្តចំពោះការខកខានជើងយន្តហោះ ឬវង្វេងយន្តហោះដូចពលករប្រទេសមួយចំនួន។

**៧៖** មានសេវាថែទាំពលករក្រោយពេលមកដល់កូរ៉េល្អជាងគេ គឺទី១. មានផ្ទះស្នាក់នៅបណ្តោះអាសន្នចំនួន ៧កន្លែងនៅទូទាំងប្រទេសកូរ៉េ, ទី២. មានបង្កើតកម្មវិធីប្រពៃណីច្រើនដើម្បីកាត់បន្ថយការនឹកស្រុកកំណើត និងផ្សព្វផ្សាយប្រពៃណីខ្មែរដល់និយោជកកូរ៉េ និងប្រជាជនកូរ៉េទាំងមូលឲ្យកាន់តែយល់វប្បធម៌ខ្មែរកាត់បន្ថយជម្លោះឬការយល់ច្រឡំ, ទី៣. មានវិធីសាស្ត្រក្នុងការបង្រៀនពលករឲ្យចេះសន្សំថវិកា និងផ្តល់វគ្គសហគ្រិនភាពដល់ពលករ, ទី៤. មានការស្នើសុំទៅ HRD Korea ចុះសួរសុខទុក្ខពលករញឹកជាងប្រទេសដទៃ (ជាមធ្យម1ខែ2ដង)។

**៨៖** មានអត្រាជោគជ័យក្នុងជីវិតខ្ពស់ ក្នុងចំណោមពលករដែលចប់កិច្ចសន្យាការងារ ហើយវិលត្រឡប់ទៅដល់កម្ពុជាវិញ។

ជារៀងរាល់ឆ្នាំ ប្រទេសកូរ៉េខាងត្បូង បានអញ្ជើញតំណាងប្រទេសទាំង១៦ ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េ ប្រជុំវាយតម្លៃ និងផ្តល់ពិន្ទុ ហើយប្រទេសដែលមានពិន្ទុល្អ កូរ៉េនឹងរក្សាចំនួនកូតា ផ្ទុយទៅវិញបើប្រទេសមានពិន្ទុតិច គេនឹងបន្ថយកូតា ក្នុងការទទួលយកពលករពីប្រទេសនោះជាដើម។

លោក ហេង សួរ បានអះអាងថា៖ «ជោគជ័យ និងកិត្តិយសនាថ្ងៃនេះ គឺផ្តើមចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលផង ពីបងប្អូនពលករខ្លួនឯងផង! សូមបងប្អូនពលករនៅកូរ៉េទាំងអស់ទទួលយកនូវការសរសើរពី HRD Korea និងនិយោជកកូរ៉េទាំងអស់គ្នា។ មានលទ្ធភាពផ្តល់ឱកាសការងារដល់បងប្អូនពលករខ្មែរមកធ្វើការនៅកូរ៉េ១នាក់ មានន័យថាដូចជាបានជួយធ្វើឲ្យគ្រួសារចំនួន ១គ្រួសារមានឱកាសផ្លាស់ប្តូរជីវភាពរស់នៅរីកចំរើនបានលឿន»។ លោកបានជូនពរពលករខ្មែរ សហគមន៍ខ្មែរនៅកូរ៉េទាំងអស់ជួបតែសំណាងល្អ ជាពិសេសសូមឲ្យមានសុខភាពល្អ ជួបនិយោជកកាន់តែល្អ និងមានការងារកាន់តែល្អធ្វើ!។ លោកបញ្ជាក់ថា៖ «យើងខ្ញុំនឹងខិតខំផ្តល់សេវាកាន់តែល្អថែមទៀតដល់បងប្អូន!»។

របាយការណ៍ដែលផ្តល់ដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឱ្យដឹងថា គិតត្រឹមខែសីហា ឆ្នាំ២០១៩នេះ កម្ពុជាមានពលករប្រមាណ ៥៤,៣១៩នាក់ កំពុងធ្វើការងារនៅប្រទេសកូរ៉េខាងត្បូង ក្នុងនោះមានស្ត្រី

១១,៧២០នាក់។ ពលករទាំងនោះ បញ្ជូនថវិកាមកកាន់គ្រួសារ នៅស្រុកកំណើត ក្នុងប្រទេសកម្ពុជា ក្នុង១ឆ្នាំៗ ប្រមាណ៥០០លានដុល្លារសហរដ្ឋអាមេរិក៕

## កិច្ចប្រជុំពិភាក្សារវាងខេត្តកោះកុងនិងខេត្តត្រាត

https://gdlf-kh.com/ 09/09/2019 Kao sophy ខេត្តកោះកុង

ខេត្តកោះកុង៖ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ លោកស្រី ឈុន រ៉ាវុធ អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាត្រៀមលក្ខណៈ ចូលរួមកិច្ចប្រជុំនៅខេត្តត្រាត ប្រទេសថៃ ដោយពិភាក្សាសំខាន់ទៅលើ ១-អនុស្សារណៈយោគយល់គ្នា រវាងខេត្តកោះកុង និងខេត្តត្រាត ២-ការទទួល និងប្រគល់ពលករ (ស្របច្បាប់និងមិនស្របច្បាប់) ៣-ផ្តល់ព័ត៌មានអំពីពលករដែលមានគ្រោះថ្នាក់ និងការជួយសង្គ្រោះ ៤-បញ្ហាផ្សេងៗ

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 09-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកទឹកជប់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## កម្លាំងសមត្ថកិច្ចចម្រុះថៃ ខេត្តស្រះកែវឃាត់ខ្លួន បានពលរដ្ឋខ្មែរ គ្មានឯកសារ ចំនួន ១០នាក់

https://www.facebook.com/Newslabourkhmer/ 09-09-2019

09/09/19 កម្លាំងសមត្ថកិច្ចចម្រុះថៃ ខេត្តស្រះកែវ ធ្វើយុទ្ធនាការ ចុះឆែកឆេរ បន្ទប់ជួលមួយកន្លែង ស្ថិតក្នុងឃុំបរ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ យោងតាមរបាយការណ៍ ឃាត់ខ្លួន បានពលរដ្ឋខ្មែរ គ្មានឯកសារ ចំនួន ១០នាក់ ។

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវា ជូនបងប្អូនពលករខ្មែរ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 09-09-2019

នាថ្ងៃច័ន្ទ ១១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានជួយសម្រួលផ្តល់សេវាដល់ជូនបងប្អូនពលករខ្មែរ ឱ្យទទួលបាននៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយពេលវេលា និងការចំណាយក្នុងការធ្វើដំណើររបស់បងប្អូនពលករ។ លើសពីនេះទៀត ស្ថានទូតក៏បានណែនាំអំពីសេវានៅស្ថានទូត អំពីច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃផងដែរ។

# ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៩

## សម្តេចតេជោ ហ៊ុន សែន នឹងអញ្ជើញបើកសន្និសីទ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ កិច្ចប្រជុំ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារប្រទេស CLMTV ចាប់ពីថ្ងៃទី១៦-១៧ ខែកញ្ញា នៅខេត្តសៀមរាប

https://www.chnchannel.com/article/ អត្ថបទដោយ Kongkea Leuk Last updated ថ្ងៃទី 11 ខែ កញ្ញា ឆ្នាំ 2019

**ភ្នំពេញ៖** ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ បានចេញសេចក្តីប្រកាសព័ត៌មានមួយ ស្តីអំពីការធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារ លើកទី៥ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ក្រោយប្រធានបទ

«ការផ្តោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍ នៅក្នុងប្រទេស CLMTV» នៅថ្ងៃទី១៦-១៧ ខែកញ្ញាខាងមុខនេះ នាខេត្តសៀមរាប-អង្គរ។

សេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការងារ ដែលទទួលបាននៅព្រឹកថ្ងៃទី១១ ខែកញ្ញានេះ បានបញ្ជាក់ថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នឹងអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកសន្និសីទ ថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។ គោលបំណងដ៏ចំបងរបស់សន្និសីទ គឺដើម្បីពិភាក្សាស្វែងរកក្របខ័ណ្ឌរួមមួយ ពាក់ព័ន្ធនឹងការធ្វើចល័តភាពរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងប្រទេស CLMTV ដូចជា៖

- លើកកម្ពស់បន្ថែមទៀត នៃកិច្ចសហប្រតិបត្តិការលើវិស័យការងារ ក្នុងប្រទេស CLMTV។
- ជំរុញឲ្យមានការបន្តការចែករំលែកបទពិសោធន៍ និងការអនុវត្តល្អៗ ក្នុងចំណោមប្រទេស CLMTV ពាក់ព័ន្ធនឹងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ ជាពិសេសចល័តភាព នៃរបបសន្តិសុខសង្គម។
- ពិភាក្សាឲ្យមានការឯកភាពគ្នាលើយន្តការរួមមួយ ដើម្បីឈានទៅកំណត់អំពីការអនុវត្តចល័តភាព នៃរបបសន្តិសុខសង្គមនាពេលអនាគត។
- ធ្វើការផ្តោះទៅកាន់ការរៀបចំក្របខ័ណ្ឌរួមមួយ សម្រាប់ប្រទេស CLMTV ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍៕

## កម្មវិធីដាក់បង្ហាញលើដំណើរការសាកល្បងគេហទំព័រ និងកម្មវិធីស្មាតហ្វូន

https://grandnewsasia.com/ 11-09-2019

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ លោកស្រី ប៊ន សុភី អភិបាលរងខេត្តកំពង់ឆ្នាំង អញ្ជើញចូលរួមកម្មវិធីដាក់បង្ហាញលើដំណើរការសាកល្បងគេហទំព័រ និងកម្មវិធីស្មាតហ្វូន "NCCT PARTNER RESOURCES AND SERVICE REFERRALS "។

កម្មវិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការសហការរវាង អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង អង្គការដៃគូ អភិវឌ្ឍនានា មាន CHAB DAI , ERIKS , USAID ,WINROCK ។

អញ្ជើញចូលរួមក្នុងកម្មវិធីនេះមាន លោក លោកស្រី តំណាងក្រសួង ស្ថាប័នគ.រ.ប.ជ / គ.ខ ប.ជ ទាំង២៥ រាជធានី-ខេត្ត និង អង្គការជាតិ អន្តរជាតិជាដៃគូ។

គោលបំណងចំបងនៃកម្មវិធីនេះគឺចង់បង្ខិតឲ្យកាន់តែជិតគ្នារវាងសេវាកម្មបំរើប្រជាពលរដ្ឋ និងសេវាកម្មទទួលបម្រើដល់ជនងាយរងគ្រោះ ឬរងគ្រោះបានឆាប់រហ័ស និងទាន់ពេលវេលា ៕

## កម្ពុជាទទួលបានការវាយតម្លៃល្អជាងគេ លើការផ្តល់សេវាបញ្ជូនពលករទៅធ្វើការនៅកូរ៉េ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 11 September 2019 | 09:30 ICT

ភ្នំពេញៈ កម្ពុជាទទួលបានការវាយតម្លៃល្អជាងគេបើប្រៀបធៀបជាមួយបណ្តាប្រទេសចំនួន ១៥ ផ្សេងទៀតដែលបញ្ជូនពលករឲ្យទៅធ្វើការនៅកូរ៉េលើការផ្តល់សេវាស្វែងរកទីផ្សារការងារនៅប្រទេសនេះ ដែលការវាយតម្លៃល្អនេះ ខណៈដែលកម្ពុជាបានបញ្ជូនពលករទៅធ្វើការនៅកូរ៉េប្រមាណជាង ៥ ម៉ឺន ៤ ពាន់នាក់គិតចាប់ពីឆ្នាំ ២០១៧។ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី ១៥ នៃសន្និសីទ EPS នៅសាធារណរដ្ឋកូរ៉េ ដោយមានការចូលរួមពីតំណាងភ្នាក់ងារបញ្ជូនពលករទៅធ្វើការនៅប្រទេសនេះ

ទាំង ១៦ ប្រទេសកាលពីថ្ងៃចន្ទ ខណៈលទ្ធផលនេះត្រូវបានវាយតម្លៃដោយអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងការងារនៃសាធារណរដ្ឋកូរ៉េ (HRD KOREA)។

លោក ហេង សួរ បានថ្លែងប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃអង្គារថា ជារៀងរាល់ឆ្នាំអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងការងារកូរ៉េតែងតែមានកិច្ចប្រជុំមួយជាមួយប្រទេសទាំង ១៦ ដែលជាប្រទេសទទួលបានការអនុញ្ញាតឲ្យបញ្ជូនពលករមកធ្វើការនៅប្រទេសកូរ៉េដើម្បីធ្វើការវាយតម្លៃពីការបញ្ជូន និងការផ្តល់សេវាគាំទ្រផ្សេងៗក្នុងអំឡុងពេលនាំពលករមកប្រទេសនេះ។ HRD KOREA បានពិនិត្យ និងវាយតម្លៃផ្តល់ពិន្ទុល្អដល់ប្រទេសកម្ពុជាចំនួន ៨ ចំណុចដូចជា នីតិវិធីនៃការបញ្ជូនពលករមានរយៈពេលតិច និងចំណាយទាបជាងបណ្តាប្រទេសផ្សេងទៀត មិនសូវមានពលករផ្លាស់ប្តូរថៅកែក្នុងរយៈពេល ៣ ខែដំបូង ខណៈពលកររស់នៅខុសច្បាប់ក្នុងប្រទេសនេះមានចំនួនតិចជាងមធ្យមភាគ។ បន្ថែមពីនេះកម្ពុជាក៏មានប្រព័ន្ធប្រឡងធ្វើតេស្តសមត្ថភាពភាសាកូរ៉េតាមកុំព្យូទ័រធំជាងគេ និងមានសេវាអមពលករហូតដល់និយោជកមកទទួលបានយ៉ាងល្អរួមទាំងសេវាថៃទាំផ្ទះស្នាក់នៅបណ្តោះអាសន្នមានលក្ខណៈល្អជាងគេ ហើយក៏មានការបង្កើតកម្មវិធីប្រពៃណីនានា។ ក្នុងនោះចំពោះអត្រាជោគជ័យក្នុងជីវិតខ្ពស់ក្នុងចំណោមពលករដែលចប់កិច្ចសន្យាការងារ ហើយវិលត្រឡប់ទៅដល់កម្ពុជាវិញក៏មានលក្ខណៈល្អប្រសើរជាងគេផងដែរ។ នេះបើតាមទំព័រហ្វេសប៊ុករបស់ក្រសួងការងារ។

លោក ហេង សួរ រំពឹងថា ការវាយតម្លៃនេះអាចនឹងជួយឲ្យកម្ពុជាទទួលបានកូតានាំពលករទៅធ្វើការនៅប្រទេសកូរ៉េបានកាន់តែច្រើនថែមទៀត។ លោកបានបញ្ជាក់ថា៖ «ស្របពេលដែលកាន់តែមានប្រទេសជាច្រើនបានបញ្ជូនពលរដ្ឋទៅប្រទេសកូរ៉េ ដូច្នេះការវាយតម្លៃពីលក្ខណៈល្អប្រសើររបស់កម្ពុជានេះ គឺជាកត្តាល្អមួយដែលនាំឲ្យកម្ពុជាទទួលបានការរក្សា និងបន្ថែមកូតាក្នុងការបញ្ជូនពលរដ្ឋរបស់ខ្លួនទៅប្រទេសនេះ»។

បើតាមក្រសួងការងារគិតចាប់ពីឆ្នាំ ២០១៧ បន្ទាប់ពីកម្ពុជាបានចុះ MOU ជាមួយសាធារណរដ្ឋកូរ៉េក្នុងការនាំពលករពីកម្ពុជាទៅប្រទេសនេះកម្ពុជាបានបញ្ជូនពលករជាង ៥ ៤៣០០ នាក់រួចមកហើយដោយពួកគេទាំងនោះភាគច្រើនបម្រើការងារក្នុងផ្នែកឧស្សាហកម្មដោយជាមធ្យមទទួលបានប្រាក់ឈ្នួលចន្លោះពី ១ ២០០ ដុល្លារ ទៅ ១ ៧០០ ដុល្លារក្នុង ១ ខែ។ សម្រាប់ឆ្នាំ ២០១៩ នេះរដ្ឋាភិបាលកូរ៉េបានសម្រេចទទួលពលរដ្ឋកម្ពុជាប្រមាណ ៤ ៤០០ នាក់បន្ថែមទៀត តែយ៉ាងណាចំនួនកូតាទទួលពលករសម្រាប់ឆ្នាំ ២០២០ នៅមិនទាន់បានប្រកាសនៅឡើយទេដោយការសម្រេចនេះអាចធ្វើឡើងនៅដើមឆ្នាំខាងមុខ។ នេះបើតាមលោក ហេង សួរ។

លោកបញ្ជាក់ថា៖ «បើទោះបីជាបងប្អូនមួយចំនួនគាត់អាចមានបញ្ហាដោយសារការរស់នៅខុសច្បាប់ ហើយត្រូវបានគេបញ្ជូនមកវិញខ្លះ ប៉ុន្តែអត្រាដែលជោគជ័យ គឺកម្ពុជាយើងមានខ្ពស់ជាងគេ។ តាមដែលតំណាងក្រសួងការងារកូរ៉េនៅកម្ពុជាបានរាយការណ៍ទៅអង្គភាពរបស់គាត់ ហើយដែលបានធ្វើការវាយតម្លៃរយៈពេល១ថ្ងៃកន្លះនេះ»។

កញ្ញា ឈឿន សម្ផស្ស ដែលកំពុងបម្រើការងារក្នុងរោងចក្រមួយកន្លែងនាប្រទេសកូរ៉េថ្លែងថាជាទូទៅការធ្វើការនៅប្រទេសនេះពិតជាមានលក្ខណៈល្អប្រសើរជាងបណ្តាប្រទេសដទៃ ប៉ុន្តែពលករនៅប្រឈមនឹងបញ្ហាសុខភាព និងការធ្វើការជាមួយថៅកែដែលមិនល្អ។ កញ្ញាបញ្ជាក់ថា៖ «បើនិយាយទៅប្រាក់ខែវាបានច្រើន និងងាយស្រួលមែនប៉ុន្តែដោយពលករខ្លះមកប៉ះចំថៅកែល្អ គឺស្រួលទៅ តែបើកន្លែងលំបាក គេប្រើយើងលើសម៉ោង។ សម្រាប់នីតិវិធីក្នុងការមកនេះគឺដូចជាពលករដទៃទៀតដែរ គឺទម្រាំខ្ញុំបានមកដល់ទីនេះ (ប្រទេសកូរ៉េ) ត្រូវចំណាយច្រើនដែរអស់ ៤ ០០០ ដុល្លារឯណោះ»។

លោក យុន ផារ៉ូ អ្នកសម្របសម្រួលមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សនៃអង្គការសង់ត្រាល់យល់ថា នេះគឺជាការប្រសើរស្របពេលដែលការបញ្ជូនពលករទៅធ្វើការនៅប្រទេសនេះមិនសូវជាមានភាពមិនប្រក្រតីច្រើននោះទេ បើប្រៀបធៀបជាមួយនឹងប្រទេសដទៃ។ ទន្ទឹមនឹងភាពល្អប្រសើរនេះ លោកក៏ចង់ឃើញមានវិធានការគាំពារមួយដែលជាក់លាក់ ដើម្បីធានាដល់វិជ្ជាជីវៈរបស់ពលករកម្ពុជាទាំងនោះនៅពេលត្រឡប់មកវិញ។ លោកបញ្ជាក់ថា៖

«សម្រាប់ការទទួលស្គាល់នូវជំនាញវិជ្ជាជីវៈតាមរយៈការធ្វើការងារណាមួយនៅប្រទេស កូរ៉េ ហ្នឹង ដើម្បីអាចទទួលស្គាល់ ឬក៏ការធ្វើសមាហរណកម្មណាមួយសម្រាប់ជានាពួកគេពេលចប់ការងារពីប្រទេសកូរ៉េ ងាយស្រួលរកការងារនៅប្រទេសកម្ពុជា។ នេះជាកត្តាចម្បង ព្រោះទៅថ្ងៃអនាគតយើងមិនអាចធ្វើជាប្រទេសដែលនាំពលករ ឬលក់កម្លាំងពលកម្មទេ។ គឺត្រូវតែបង្កើតធនធានមនុស្សក្នុងស្រុក និងបង្កើតទីផ្សារការងារបន្ថែមទៀត»៕

## ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៩

## ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការដៃគូ ដែលភាគីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://gdlf-kh.com/ 12/09/2019 Kim Sopha

រាជធានីភ្នំពេញ ៖ នារសៀលថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩នេះ នៅទីស្តីការក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រសួងមហាផ្ទៃ បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការដៃគូ ដែលភាគីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការចូលរួមពី គណៈប្រតិភូគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈប្រតិភូអង្គការដៃគូ ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូប។

ពិធីចុះហត្ថលេខានេះខាងលើក្នុងគោលបំណង ដើម្បីចូលរួមចំណែកការងារមនុស្សធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដើម្បីលើកកម្ពស់សុខមាលភាពសង្គម តាមរយៈការបង្កើត ទប់ស្កាត់ និងឆ្លើយតបឲ្យកាន់តែល្អ ប្រសើរឡើងលើសិទ្ធិកុមារ និងប្រាកដថាកុមារទទួលបាននូវការការពារ។ ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាពខ្ពស់ អង្គការដែនដីមនុស្ស-ហូឡង់ដ៍ ប្រចាំកម្ពុជា និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈយន្តការជាតិ និងថ្នាក់ក្រោមជាតិ និងធ្វើកិច្ចសហការរួមគ្នាលើសកម្មភាពជាក់ស្តែង ក្នុងការបង្ការ ទប់ស្កាត់ ការប្រឆាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្សេងៗ និងការរំលោភបំពានផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍។

## អគ្គស្នងការដ្ឋាននគរបាលជាតិនិងភ្នាក់ងារឧក្រិដ្ឋកម្ម NCA សហប្រតិបត្តិការយ៉ាងល្អប្រសើរ ក្នុងការប្រឆាំង និងទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ

http://www.cen.com.kh/ September 13, 2019

ភ្នំពេញ៖ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿនបានថ្លែងថា ភ្នាក់ងារឧក្រិដ្ឋកម្ម NCA និងអគ្គស្នងការដ្ឋាននគរបាលជាតិ ភាគីទាំងបានផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការបានយ៉ាងល្អប្រសើរ ក្នុងការប្រឆាំង និងទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរកុមារ និងអនីតិជន។

នៅរសៀលថ្ងៃព្រហស្បតិ៍ ទី១២ ខែកញ្ញា ឆ្នាំ២០១៩នេះលោក នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតឲ្យលោក Gerry McGowan មន្ត្រីទំនាក់ទំនងភ្នាក់ងារឧក្រិដ្ឋកម្ម NCA ចប់អាណត្តិ ចូលជួបជម្រាបលា និងណែនាំលោក Peter Vernon មន្ត្រីទំនាក់ទំនងភ្នាក់ងារឧក្រិដ្ឋកម្ម NCA ថ្មី ចូលជួបសម្តែងការគួរសម នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។ លោកនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានមានប្រសាសន៍ថា ឆ្លងតាមការធ្វើកិច្ចសហការកន្លងមករវាងស្ថាប័ន NCA និងអគ្គស្នងការដ្ឋាននគរបាលជាតិ ភាគីទាំងបានផ្លាស់ប្តូរកិច្ចសហប្រតិបត្តការណ៍បានយ៉ាងល្អប្រសើរ ក្នុងការប្រឆាំង និងទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសកិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរកុមារ និងអនីតិជន។ ជាក់ស្តែងនៅពេលថ្មីៗនេះ កម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន របស់អគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើការ

ចាប់ខ្លួនក៏ដូចជាបង្ក្រាបនូវជនល្មើសរំលោភផ្លូវភេទលើកុមារតាមសំណើររបស់ NCA ផងដែរ។ នៅក្នុងជំនួបពិភាក្សានេះផងដែរ លោក នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ក៏បានលើកទឹកចិត្តឲ្យ NCA បន្តជួយដល់កម្ពុជាលើការងារបណ្តុះបណ្តាល ជាពិសេសពាក់ព័ន្ធទៅនឹងជំនាញប្រឆាំងការជួញដូរមនុស្ស។

ជាការឆ្លើយតប ភាគី NCA បានប្តេជ្ញាថា នឹងជួយកម្ពុជាទៅលើវិស័យនេះ និងសន្យាផ្តល់ព័ត៌មាននានា ពាក់ព័ន្ធនឹងបទល្មើសលើកុមារមកអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីជាមូលដ្ឋានក្នុងការស៊ើបអង្កេតសហការធ្វើយ៉ាងណាការពារកុមារនៅក្នុងប្រទេសកម្ពុជាផងដែរ។ គួបញ្ជាក់ផងដែរថា ស្ថាប័ន NCA និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចុះអនុស្សរណៈ នៃការយោគយល់គ្នា MOU ដែលបានបង្ហាញពីកិច្ចសហប្រតិបត្តិការយ៉ាងល្អរវាងស្ថាប័នទាំងពីរផងដែរ៕ ដោយ ៖ កូឡាប

## មន្ត្រីចុះពិនិត្យសិប្បកម្មឡឥដ្ឋប្រមាណ ១០០ រកឃើញទីតាំង ១ ប្រើកម្លាំងក្មេង

https://www.postkhmer.com/ ឡុង គីមម៉ារីតា Publication date 12 September 2019 10:57 ICT

**ភ្នំពេញ:** មន្ត្រីក្រសួងការងារអះអាងថា ក្រុមការងារបានចុះត្រួតពិនិត្យសិប្បកម្មឡឥដ្ឋបានប្រមាណ ១០០ ទីតាំងក្នុងខេត្តចំនួន ៦ កាលពីខែមុន ដោយក្នុងនោះបានពិន័យម្ចាស់ឡឥដ្ឋ ១ កន្លែង ដែលប្រើប្រាស់កម្លាំងពលកម្មក្មេង ខណៈសិប្បកម្មឡឥដ្ឋដទៃទៀតត្រូវបានណែនាំ។ ការចុះពិនិត្យសិប្បកម្មឡឥដ្ឋទាំងនេះធ្វើឡើងក្នុងយុទ្ធនាការចុះទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ដែលចាប់ផ្តើមឡើងតាំងពីថ្ងៃទី ១២ សីហា ឆ្នាំ ២០១៩ ដើម្បីសម្រេចឲ្យបាននូវការលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការងារ និងយុទ្ធនាការសហគមន៍ផលិតឥដ្ឋគ្មានពលកម្មកុមារឆ្នាំ ២០២០។

លោក វ៉េង ហៀង ប្រធាននាយកដ្ឋានការងារកុមារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានដឹកនាំក្រុមការងារធ្វើយុទ្ធនាការនេះបានប្រាប់ភ្នំពេញប៉ុស្តិ៍ពីថ្ងៃទី ១០ កញ្ញា ថា ការចុះត្រួតពិនិត្យនេះនឹងត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីពិនិត្យជុំវិញលក្ខខណ្ឌការងារ និងទម្រង់ការងារជាទាសភាព ឬទម្រង់ការងារដោយបង្ខំពាក់ព័ន្ធបំណុលក្នុងសិប្បកម្មឡឥដ្ឋទាំងអស់។ លោកបន្តថា ការងារនេះក៏មានបំណងចង់ផ្សព្វផ្សាយ និងការហាមប្រាមការប្រើប្រាស់ពលកម្មកុមារនៅតាមឡឥដ្ឋ ដើម្បីឲ្យម្ចាស់សិប្បកម្មទាំងនោះត្រូវអនុវត្តឲ្យបានត្រឹមត្រូវផងដែរ ។ លោកនិយាយថា ហូតមកទល់ពេលនេះក្រុមការងារបានចុះត្រួតពិនិត្យសិប្បកម្មឡឥដ្ឋក្នុងខេត្ត-ក្រុងចំនួន ៦ ដូចជារាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងខេត្តព្រៃវែង។ ការចុះពិនិត្យខេត្តនីមួយៗបានធ្វើឡើងក្នុងចន្លោះពី ១០ ទៅ ២០ ទីតាំង។ ក្នុងនោះសិប្បកម្មជាលក្ខណៈគ្រួសារត្រូវបានរកឃើញថាមានភាពមិនប្រក្រតី និងអនុវត្តលក្ខខណ្ឌការងារមិនល្អដោយត្រូវបានណែនាំច្រើនជាងគេ។

លោក វ៉េង ហៀង បញ្ជាក់ថា៖ «ឥឡូវនេះ យើងចុះពិនិត្យប្រហែលជា ១០០ សិប្បកម្មផលិតឥដ្ឋតាមរយៈថ្នាក់ជាតិអ្នកចុះពិនិត្យផ្ទាល់។ ចំណែកថ្នាក់ខេត្ត នឹងចុះពិនិត្យបន្តទៀតនៅឡឥដ្ឋណាដែលយើងមិនទាន់បានចុះពិនិត្យ ហើយប្រធានមន្ទីរបន្តចុះពិនិត្យទាល់តែអស់ (ទីតាំងឡឥដ្ឋ)»។ លោកបន្តថា៖ «ការចុះនេះ ប្រសិនបើធ្ងន់ធ្ងរគឺផាកពិន័យកតែម្តង ហើយកន្លងមក យើងផាកពិន័យបាន ១ ទីតាំងហើយ។ យើងពិន័យប្រមាណ ៥ លានរៀល គឺ (សិប្បកម្ម) នៅខេត្តកណ្តាលដោយសារតែសិប្បកម្មនេះ មានប្រើប្រាស់ក្មេង។ នៅខេត្តផ្សេងទៀតអត់មានប្រើប្រាស់ក្មេងទេ ប៉ុន្តែយើងហាមឃាត់ការងារប្រកបដោយគ្រោះថ្នាក់» ។ បើតាមលោក វ៉េង ហៀង សិប្បកម្មឡឥដ្ឋសរុបទូទាំងប្រទេសមានប្រមាណ ៤០០ ទីតាំង ក្នុងនោះមានកម្មករបម្រើការងារចន្លោះពី ៥ ទៅ ៦ ពាន់នាក់ ខណៈសិប្បកម្មឡឥដ្ឋប្រមាណ ៣១ ភាគរយ បានប្រើប្រាស់បច្ចេកទេសទំនើប ភាគច្រើននៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ។

អ្នកស្រី សឿង រ៉ានី ម្ចាស់សិប្បកម្មឡឥដ្ឋ ១ កន្លែង ដែលមានកម្មករប្រមាណ ២០ នាក់ ស្ថិតក្នុងភូមិអូរឫស្សី ក្រុងសំរោង ខេត្តឧត្តរមានជ័យ និយាយថា អ្នកស្រីមិនបារម្ភពីការចុះត្រួតពិនិត្យរបស់ក្រុមការងារទាំងនេះនោះទេ។

ការអះអាងដូច្នេះព្រោះតែអ្នកស្រីយល់ថាសិប្បកម្មរបស់អ្នកស្រីបានគោរពតាមលក្ខណៈបច្ចេកទេស និងច្បាប់ត្រឹមត្រូវ ដោយក្នុងនោះក៏មិនមានការប្រើប្រាស់កម្លាំងពលកម្មកុមារដែរ។ ម្ចាស់សិប្បកម្មរូបនេះអះអាងថា៖ «គេចុះមកពិនិត្យជាប្រចាំដែរពេលខ្លះ ខ្ញុំអត់នៅក៏មានអ្នកចុះមកពិនិត្យដែរ។ ខ្ញុំអត់បញ្ហាទេ គាត់ចុះមកខ្ញុំអនុញ្ញាត ព្រោះខ្ញុំធ្វើត្រឹមត្រូវតាមច្បាប់ទាំងអស់ ហើយខ្ញុំនិយាយអ្វីដែលជាការពិត គាត់ចុះមកថ្មើរណាក៏បានដែរ»។ អ្នកស្រី សឿង រ៉ានី អះអាងថាសិប្បកម្មរបស់អ្នកស្រីមិនធ្លាប់ប្រើប្រាស់កុមារអាយុក្រោម ១៦ ឆ្នាំនោះទេ។ ប៉ុន្តែអ្នកស្រីក៏មិនហ៊ានសន្និដ្ឋានដែរថារាល់សិប្បកម្មទាំងអស់បានអនុវត្តត្រឹមត្រូវតាមច្បាប់ឬអត់នោះទេ ។

លោក អំ សំអាត ប្រធានផ្នែកស៊ើបអង្កេតអង្គការសិទ្ធិមនុស្ស (លីកាដូ) សាទរចំពោះយុទ្ធនាការនេះ ខណៈកន្លងទៅអង្គការលីកាដូក៏ធ្លាប់ស្នើឲ្យមានការចុះធ្វើអធិការកិច្ចលើសិប្បកម្មទាំងនេះផងដែរ។ លោកថា ការចុះត្រួតពិនិត្យនឹងធ្វើឲ្យបានទៀងទាត់ ដោយមិនគួរប្រកាសជូនដំណឹងទៅដល់ម្ចាស់សិប្បកម្មទាំងនោះឲ្យបានដឹងខ្លួនមុននោះទេ ព្រោះអាចឲ្យពួកគេមានពេលវេលាក្នុងការរៀបចំទុកជាមុន។ លោកបញ្ជាក់ថា៖ «ចុះជាប្រចាំ ដើម្បីធានាថាឡឥដ្ឋនីមួយៗ មិនមានការប្រើប្រាស់ពលកម្មកុមារទេ។ ការពិនិត្យទៅលើការជំពាក់បំណុលជារឿងចាំបាច់ដែរ ព្រោះគ្រួសារស្ទើរតែទាំងអស់ហើយនៅក្នុងឡឥដ្ឋមានការជំពាក់បំណុល។ ព្រោះការជំពាក់បំណុលពីថៅកែពីអីហ្នឹងគឺជាការបង្ខំមួយដែរ ដែលនាំឲ្យមានការប្រើប្រាស់ក្មេងដើម្បីបានលុយកាក់ច្រើន»។ ទោះយ៉ាងណាលោក អំ សំអាត ចង់ឲ្យក្រសួងការងារធានាទៅដល់កុមារដែលរស់នៅក្នុងសិប្បកម្មឡឥដ្ឋជាមួយឪពុកម្ដាយទាំងអស់បានទទួលការសិក្សាត្រឹមត្រូវពេញលេញគ្រប់ៗគ្នា៕

## **សិក្ខាសាលាណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន**

http://www.mlvt.gov.kh/ Thursday, 12 September 2019 17:41 Written by MLVT

នាថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំសិក្ខាសាលា ធ្វើការណែនាំតម្រង់ទិសដល់កម្មសិក្សាការី ដែលត្រូវចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន នៅសាល C នៃទីស្តីការក្រសួង សរុបកម្មសិក្សាការីចំនួន ៩៣នាក់ (ស្រី ១២នាក់) ក្រុមគ្រួសារកម្មសិក្សាការីចំនួន១២នាក់ និងតំណាងក្រុមហ៊ុនចំនួន ១០នាក់។ កម្មវិធីសិក្ខាសាលានេះរៀបចំឡើង ដើម្បីផ្តល់ចំណេះដឹងជំនាញទន់ និងព័ត៌មានចាំបាច់មុនចេញដំណើរដល់កម្មសិក្សាការី ឱ្យមានការយល់ដឹងដូចខាងក្រោម៖

១-ការរៀបចំខ្លួន ដើម្បីធ្វើការនៅប្រទេសជប៉ុន
២-ភូមិសាស្ត្រ បរិស្ថាន និងវប្បធម៌នៅប្រទេសជប៉ុន
៣-ការធ្វើដំណើរតាមផ្លូវ និងការមកដល់ប្រទេសជប៉ុន
៤-ការធ្វើការងារ និងការរស់នៅក្នុងប្រទេសជប៉ុន
៥-ការគ្រប់គ្រងប្រាក់
៦-សុខភាព និងអនាម័យ
៧-ការធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ
៨-សុវត្ថិភាព និងសេវាគាំទ្រ។

ក្រុមហ៊ុនដែលបានបញ្ជូនកម្មសិក្សាការី ទទួលការបណ្តុះបណ្តាលក្នុងសិក្ខាសាលានេះមានចំនួន ១០ គឺ

១. Ung Rithy Group Co., LTD
២. Asian Human Support (Cambodia) CO., LTD.
៣. Big Bi Imex Group CO., LTD.
៤. CJTT Trading CO., LTD.
៥. C A T M Asia Manpower Cooperation CO., LTD.
៦. GALA TOKYO Manpower CO., LTD.
៧. Global Employment Service (Cambodia) Co., LTD.
៨. Hirayama Co., LTD.
៩. Kei Kei (Cambodia) Human Resources Co., LTD.
១០. JNN International Economic and Technical Cooperation Co., LTD.

# ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៩

## កម្ពុជាធ្វើជាម្ចាស់ផ្ទះ ប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ការងារលើកទី៥ សម្រាប់កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម

https://www.dap-news.com/ ByID:112 Posted on 16 September 2019 | 10:54

ភ្នំពេញ ៖ កម្ពុជា បានរៀបចំធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ការងារលើកទី៥ សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV)ក្រោមប្រធានបទ "ការឆ្ពោះទៅកាន់កិច្ចគាំពារ ពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV លើកិច្ចសហប្រតិបត្តិការវិស័យ សន្តិសុខសង្គម" នៅសណ្ឋាគារ អប្សរាផាឡេស ព្រឹកថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៩ ។ នេះបើតាមការផ្សព្វផ្សាយ របស់ក្រសួងការងារ។

ក្នុងពិធីបើកកិច្ចប្រជុំ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ មានប្រសាសន៍ថា ប្រមុខរដ្ឋាភិបាល នៃបណ្តាប្រទេសអាស៊ាន បានប្តេជ្ញារួមគ្នាក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍តាមរយៈការចេញសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករ ទេសន្តរប្រវេសន៍ នៅទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន ឆ្នាំ២០០៧ និងបានចេញឯកច្ឆន្ទភាពអាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់ សិទ្ធិពលករទេសន្តរប្រវេសន៍ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាឆ្នាំ២០១៧។

តាមរយៈកិច្ចប្រជុំជាបន្តបន្ទាប់ក្នុងក្របខណ្ឌ នៃកិច្ចសហប្រតិបត្តិការនេះ ផ្អែកតាមសេចក្តីថ្លែងការណ៍នៃសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី២ កាលពីឆ្នាំ២០១៧ និងលទ្ធផលនៃកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៤ កាលពីឆ្នាំ២០១៨ នៅវៀតណាម បានឯកភាពគ្នាជំរុញឲ្យមានយន្តការ ក្នុងការផ្ទេរអត្ថប្រយោជន៍ នៃរបបសន្តិសុខសង្គមពីប្រទេស ទទួលមកប្រទេសបញ្ជូនពលករ ដោយបានផ្តួចផ្តើមគំនិតមួយចំនួន ។

ក្នុងនោះ (១)- សិក្សារៀបចំច្បាប់ និងគោលនយោបាយជាតិ មានសង្គតិភាពគ្នាជាមួយនឹងបទដ្ឋាន ឬលិខិតតូបករណ៍គតិយុត្តអន្តរជាតិ ពាក់ព័ន្ធនឹងចល័តភាព នៃរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ ,

(២)- ផ្តល់ និងផ្លាស់ប្តូរទិន្នន័យជាក់លាក់អំពីពលករទេសន្តរប្រវេសន៍ ដែលគ្របដណ្តប់ដោយរបបសន្តិសុខសង្គម នៅក្នុងប្រទេស CLMTV ,

(៣)-បង្កើនការចូលរួមរបស់កម្មករនិយោជិត និយោជក និងរដ្ឋាភិបាលនៅកម្រិតជាតិ ដើម្បីអភិវឌ្ឍ និងអនុវត្តគំនិតផ្តួចផ្តើមអំពីចល័តភាព នៃរបបសន្តិសុខសង្គមសម្រាប់ពលករ ទេសន្តរប្រវេសន៍នៃប្រទេស CLMTV ,

(៤) ធ្វើការងារឆ្ពោះទៅកាន់ការរៀបចំក្រប ខណ្ឌរួមសម្រាប់ប្រទេស CLMTV ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ ពលករទេសន្តរប្រវេសន៍ ,

(៥) ជំរុញការចុះកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ នៃប្រទេស CLMTV ចំពោះផ្នែកសេដ្ឋកិច្ចដែលពាក់ព័ន្ធ ,

(៦) ពង្រឹងយន្តការនៅក្នុងប្រទេស CLMTV អំពីរបៀបទទួលបាននូវអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម និង(៧)លើកកម្ពស់ការសម្របសម្រួល រវាងស្ថាប័នទទួលបន្ទុក របបសន្តិសុខសង្គមនៅក្នុងប្រទេស CLMTV ៕

## រដ្ឋមន្ត្រីការងារកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម ពិភាក្សាគ្នារឿងពលករនិងការងារ

https://thmeythmey.com/ 16, Sep 2019 , 10:26 am

កម្ពុជា ធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការងារលើកទី៣ នៃប្រទេសទាំង៥ ដែលហៅថាប្រទេស CLMTV រួមមាន កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម។ សន្និសីទលើកទី៣នេះ ប្រព្រឹត្តទៅពីថ្ងៃទី១៦

ដល់ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នៅលើទឹកដីខេត្តសៀមរាប។ ប្រធានបទនៃសន្និសីទនេះ គឺ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករនៅក្នុងប្រទេស CLMTV»។ ប្រធានបទនេះ នឹងផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការលើវិស័យការងារនៃប្រទេស CLMTV។

គេហទំព័ររបស់ក្រសួងការងារ ផ្សាយថា គោលបំណងចម្បងនៃសន្និសីទនេះ គឺដើម្បីពិភាក្សាស្វែងរកក្របខ័ណ្ឌរួមមួយ ពាក់ព័ន្ធនឹងការធ្វើចល័តភាពរបបសន្តិសុខសង្គមសម្រាប់ពលករ នៅក្នុងប្រទេសទាំង៥។ នៅថ្ងៃទី១៦នេះ គឺជាកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ក្រសួងការងារនៃប្រទេស CLMTV ហើយនៅព្រឹកថ្ងៃទី១៧ សន្និសីទថ្នាក់រដ្ឋមន្ត្រី នឹងចាប់ផ្តើមបើកជាផ្លូវការ។ ក្រសួងការងារ អះអាងថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងចូលរួមជាអធិបតីក្នុងពិធីបើកសន្និសីទនេះ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា ថ្លែងដូច្នេះថា៖«ទោះបីជាប្រទេសនីមួយៗមានក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្ថានភាពសង្គមសេដ្ឋកិច្ច មិនដូចគ្នាទាំងស្រុងក៏ដោយ ប៉ុន្តែក្នុងក្របខ័ណ្ឌអន្តរជាតិ និងក្របខ័ណ្ឌតំបន់ យើងពិតជាអាចស្វែងរកនូវចំណុចរួមមួយដើម្បីសម្រេចគោលដៅ និងផលប្រយោជន៍រួម ពោលគឺពលករគ្រប់រូបអាចទទួលបាននូវរបបសន្តិសុខសង្គម ទោះបីគេផ្លាស់ទីកន្លែងធ្វើការពីកន្លែងមួយទៅកន្លែងមួយ ឬពីប្រទេសមួយទៅប្រទេសមួយក៏ដោយ»៕

## អជ្ញាធរអន្តោប្រវេសន៍ ខេត្តភេតប៊ូន ប្រទេសថៃ ឃាត់ខ្លួន នារីពលករខ្មែរ ម្នាក់ ពីបតធ្វើការខុសពីប័ណ្ណការងារអនុញ្ញាត

https://www.facebook.com/Newslabourkhmer/ 15-09-2019

15/09/19 អជ្ញាធរអន្តោប្រវេសន៍ ខេត្តភេតប៊ូន ប្រទេសថៃ ឃាត់ខ្លួននារីពលករខ្មែរម្នាក់ ពីបតធ្វើការខុសពីប័ណ្ណការងារអនុញ្ញាត ការឃាត់ខ្លួននេះបានធ្វើឡើងនៅក្នុងផ្សារលក់ត្រីមួយកន្លែង ក្នុងខេត្តភេតប៊ូន កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ កន្លងទៅ ។

## កម្លាំងអជ្ញាធរអន្តោប្រវេសន៍ ខេត្តសាមុតប្រាកាន ប្រទេសថៃ បានឃាត់ខ្លួន ពលរដ្ឋខ្មែរខុសច្បាប់ ចំនួន ២នាក់

https://www.facebook.com/Newslabourkhmer/ 14-09-2019

14/09/19 កម្លាំងអជ្ញាធរអន្តោប្រវេសន៍ ខេត្តសាមុតប្រាកាន ប្រទេសថៃ បានឃាត់ខ្លួនពលរដ្ឋខ្មែរខុសច្បាប់ចំនួន ២នាក់៖

ទី១ ឈ្មោះ ថៃង ភេទប្រុស អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ គ្មានឯកសារស្នាក់នៅ

ទី២ ឈ្មោះ ឃឿម ភេទប្រុស អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ គ្មានឯកសារស្នាក់នៅ

ទាំងពីរនាក់ត្រូវកម្លាំងសមត្ថកិច្ចថៃ ធ្វើការឃាត់កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ កន្លងទៅ ក្នុងខេត្តសាមុតប្រាកាន ។

## កម្លាំងអជ្ញាធរអន្តោប្រវេសន៍ ខេត្តអយុធ្យា ប្រទេសថៃ ឃាត់ខ្លួន ពលរដ្ឋខ្មែរ ម្នាក់

https://www.facebook.com/Newslabourkhmer/ 12-09-2019

12/09/19 កម្លាំងអជ្ញាធរអន្តោប្រវេសន៍ ខេត្តអយុធ្យា ប្រទេសថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ឈ្មោះ សារ៉េ វ៉ាត់ អាយុ៣៧ឆ្នាំ សញ្ញាតិខ្មែរ ពីរបទស្នាក់នៅក្នុងប្រទេសថៃ ដោយគ្មានច្បាប់អនុញ្ញាត និងធ្វើការខុសច្បាប់ ។

## កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ ខេត្តស្រះកែវ ប្រទេសថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរ ប្រុសស្រី ខុសច្បាប់ ចំនួន ១០នាក់

https://www.facebook.com/Newslabourkhmer/ 16-09-2019

16/09/19 កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ ខេត្តស្រះកែវ ប្រទេសថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរ ប្រុស-ស្រីខុសច្បាប់ ចំនួន ១០នាក់ បន្ទាប់ពីពលរដ្ឋខ្មែរទាំងអស់នោះចំណាកស្រុកខុសច្បាប់ចូលប្រទេសថៃ ដោយគ្មានលិខិតឆ្លងដែន ។ ការឃាត់ខ្លួនពលរដ្ឋខ្មែរខុសច្បាប់ ខាងលើបានធ្វើឡើងកាលពីវេលាម៉ោង១១ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ នៅត្រង់ចំណុចបរិវេណផ្សាររោងគ្រឿ ជាប់ព្រំដែនថៃ-កម្ពុជា។

# ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៩

## សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារលើកទី៥ ក្នុងក្របខណ្ឌ CLMTV

http://bayontv.com.kh/ 17/09/2019

សៀមរាប៖ នៅព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩នេះ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដល់អាកាសយានដ្ឋានខេត្តសៀមរាបរួចហើយ ដើម្បីអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ការងារលើកទី៥ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV។

ក្រុមប្រទេស CLMTV រួមមាន៖ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម» ដែលកម្មវិធីនេះត្រូវបានរៀបចំនៅសណ្ឋាគារអប្សរាផាឡេស ខេត្តសៀមរាប៕

## នាយករដ្ឋមន្ត្រីកម្ពុជា៖ ពលករនៅបណ្ដា ប្រទេសអាស៊ានខ្លះ ចល័តធ្វើការដល់មជ្ឈឹមបូព៌ា

https://www.dap-news.com/ ByID:117 Posted on 17 September 2019 | 09:01

**ភ្នំពេញ ៖** សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានថ្លែងថា ការដោះស្រាយការងារ របស់ពលករគឺជារឿងសំខាន់ ដែលត្រូវរួមគ្នាដោះស្រាយ ខណៈការចល័តពលករខ្លះ បានទៅដល់មជ្ឈឹមបូព៌ា ដោយពលករនៅប្រទេសអាស៊ាន ធ្វើការនៅទីនោះ៕

## សម្ដេច ហ៊ុន សែន៖ ការបញ្ជូនពលករទៅក្រៅប្រទេស មិនមែនដើម្បីទៅឲ្យធ្វើខ្ញុំគេឡើយ

https://thmeythmey.com/ 17, Sep 2019 , 8:52 am ដោយ: ថ្មីៗ

សម្ដេច ហ៊ុន សែន បានលើកឡើងថា ការបញ្ជូនពលករឲ្យបម្រើការនៅក្រៅប្រទេសជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល និងបណ្ដាប្រទេសដៃគូទាំងអស់ មិនមែនជាការបញ្ជូនឲ្យទៅធ្វើខ្ញុំគេ ដូចជាការចោទប្រកាន់មួយចំនួននោះឡើយ។ ប្រមុខរដ្ឋាភិបាលបានថ្លែងយ៉ាងដូច្នេះ នាពិធីបើកកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ការងារលើកទី៥ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV ( កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម )។

ក្នុងកិច្ចប្រជុំក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម» នៅខេត្តសៀមរាប នាព្រឹកថ្ងៃអង្គារ ទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នេះ សម្ដេចបានបញ្ជាក់ថា រដ្ឋាភិបាលបន្តពិភាក្សាជាមួយប្រទេសដៃគូទាំងអស់ដើម្បីផ្ដល់ភាពស្របច្បាប់សម្រាប់ពលករ។ ជាមួយគ្នានេះ សម្ដេច បានបន្ថែមថា ការយកចិត្តទុកដាក់ចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរ

ប្រវេសន៍ ជារឿងសំខាន់បំផុតមួយ ដើម្បីឲ្យពលករខ្មែរនៅក្រៅប្រទេស ឬពលករបរទេសនៅកម្ពុជា ទទួលបានការគាំពារ និងអត្ថប្រយោជន៍ផ្សេងៗពីសង្គមដូចៗគ្នា។

ការចល័តពលករ ត្រូវបានប្រមុខរដ្ឋាភិបាលអះអាងថា មិនមែនជារឿងថ្មីនោះឡើយ ពោលគឺមានការពិភាក្សាគ្នាជាយូរណាស់មកហើយ ជាពិសេសក្នុងក្របខណ្ឌអាស៊ាន នៅ Cebu និង ម៉ានីល ជាដើម។ នៅតំបន់អាស៊ាន ព្រុយណេ សិង្ហបុរី និងម៉ាឡេស៊ី ជាប្រទេសដែលខ្វះកម្លាំងពលករ ហើយសម្តេច ហ៊ុន សែន បានកត់សម្គាល់ថា ក្នុងក្របខណ្ឌប្រទេស CLMTV ( កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) ថៃជាប្រទេសដែលទទួលពលករពីកម្ពុជាច្រើនជាងគេ ប៉ុន្តែថៃក៏បញ្ជូនពលកររបស់ខ្លួនទៅក្រៅប្រទេសផងដែរ៕

## បើថៃបណ្តេញពលករកម្ពុជា-មីយ៉ាន់ម៉ា និងឡាវចេញ នោះសេដ្ឋកិច្ចនឹងធ្លាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩ ម៉ោង ១១:១៦ អ៊ាង ប៊ុនរិទ្ធ

រាជធានីភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីបានអះអាងថា ប្រសិនបើប្រទេសថៃបណ្តេញពលករដែលទទួលយកទៅធ្វើការចេញពីប្រទេសនោះ សេចដ្ឋកិច្ចប្រទេសនេះនឹងធ្លាក់ចុះជាគំហុក ។ ថ្លែងក្នុងពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលេីកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលេីវិស័យការងារ ស្របពេលនៃកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី៥ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV ( កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) នាព្រឹកថ្ងៃទី១៧ កញ្ញា នៅខេត្តសៀមរាប ក្រោមប្រធានបទ«ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យ សន្តិសុខសង្គម»។

សម្តេចតេជោបានបញ្ជាក់ថា «មូលហេតុដែលថៃយកពលកម្មច្រើនពីបណ្តាប្រទេសនានានេះ ដោយសារ តែនៅប្រទេសមានការងារច្រើន ។ ផ្ទុយទៅវិញ ប្រសិនបើថៃ បណ្តេញពលករប្រទេសទាំងបីចេញនោះសេដ្ឋកិច្ចថៃ និងធ្លាក់ចុះតែម្តង ដោយសារតែគ្មានកំលាំងពលកម្មគ្រប់គ្រាន់ន»។ សម្តេចបន្តថា ចំពោះកំលាំងពលកម្មនេះ ភាគីទាំងអស់តែងតែធ្វើការសហការគ្នា ក្នុងនោះ មិនថាកម្ពុជានោះទេ ទាំងប្រទេសឡាវ មីយ៉ាន់ម៉ា សុទ្ធតែធ្វើសហប្រតិបត្តិការជាមួយថៃ ពីស្ថានភាពពលករមិនស្របច្បាប់ឲ្យទៅជាពលករស្របច្បាប់ ។

សម្តេចគូសបញ្ជាក់ថា៖ «ចំណុចនេះ ខ្ញុំគួរតែនិយាយឲ្យច្បាស់លាស់ សព្វថ្ងៃនេះ ខ្ញុំមិនដឹងថា តើប្រទេសរបស់អស់លោក ឯកឧត្តម លោក ជំទាវ មាននិន្នាការបែបណាទេ? ក៏ប៉ុន្តែនៅកម្ពុជា កាលដែលយើងខិតខំស្វែងរកឱកាសការងារធ្វើនៅក្រៅប្រទេស ដូចជានៅកូរ៉េ ខាង ត្បូង ជប៉ុន ម៉ាឡេស៊ី ថៃ និងសាំងហ្គាពួរ បែរជាចាត់ទុកថាហើយ បញ្ជូនមនុស្សឱ្យទៅស៊ីឈ្នួលគេ នៅធ្វើខ្ញុំ? ក៏ប៉ុន្តែសុំយើងដាក់សំណួរសួរមើលថាបើមិនធ្វើការទេ តើអ្នកណារសបានទៅនោះ?»។ សម្តេចក៏បានលើកឡើងថា ក្រុមប្រឆាំងបានធ្វើការប្រែក្លាយការធ្វើចំណាក់ស្រុកទៅក្រៅប្រទេសទៅជារឿងរាជរដ្ឋាភិបាលមិនអាចដោះស្រាយបញ្ហាឲ្យប្រជាពលរដ្ឋខ្លួនឯងបាន ហើយឲ្យពលរដ្ឋធ្វើចំណាកស្រុករកការងារធ្វើ ។

ផ្ទុយទៅវិញ ការរកការងារធ្វើនេះ គឺជាក្របខណ្ឌនៃកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ដែលមុនដំបូងក្នុងក្របខណ្ឌ គឺប្រទេសហ្វីលីពីនជាប្រទេសដែល មានពលករច្រើនចេញទៅធ្វើការនៅក្រៅប្រទេសដូច្នេះ អស់លោក លោកស្រី អាចឃើញ ថាសេចក្តីសម្រេចទាំងពីលើកទាក់ទងនិងពលករគឺសម្រេចនៅក្នុងប្រទេសហ្វីលីពីនទាំងអស់២០០៧នៅទីក្រុងសេប៊ូ និង២០១៧នៅទីក្រុងម៉ានីឡា ខ្ញុំមានវត្តមានទាំងអស់។ (សម្រួល៖ ស្រីណា)

## សម្តេចតេជោ ហ៊ុន សែន ផ្តល់អនុសាសន៍សំខាន់ៗដល់រដ្ឋមន្ត្រីការងារ CLMTV

http://www.rasmeinews.com/ September 17, 2019, 9:27 AM

*ដោយៈតារារិទ្ធ-សៀមរាបៈ* សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដល់រដ្ឋមន្ត្រីការងារនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃនិងវៀតណាម ដើម្បីសម្រេចបាននូវសេចក្តីថ្លែងការណ៍ស្តីពីផែនទីបង្ហាញផ្លូវឆ្ពោះស្តីពីចល័តភាពនៃរបបសន្តិសុខ សង្គមសម្រាប់ពលករទេសន្តប្រវេសន៍នៃប្រទេស CLMTV ។ សម្តេចបានផ្តល់អនុសាសន៍នេះនៅព្រឹកថ្ងៃទី១៧ ខែកញ្ញាឆ្នាំ២០១៩ ក្នុងការអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV)ដែលប្រារព្ធធ្វើនៅសណ្ឋាគារអប្សរា ផាឡេសខេត្តសៀមរាប។ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់អនុសាសន៍ដូចខាងក្រោម៖

១. អង្គសន្និសីទទាំងមូល សូមធ្វើការពិភាក្សាដោយឈរលើគោលនយោបាយជាតិ ច្បាប់ជាតិ ច្បាប់អន្តរជាតិ និងភាពបត់បែនតាមបរិបទនៃប្រទេសនីមួយៗ ក្នុងគោលដៅឈានទៅដល់ការដាក់ចេញនូវផែនទីបង្ហាញផ្លូវដើម្បីឆ្ពោះទៅកាន់ការចេញសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការងារស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលកទេសន្តរប្រវេសន៍ នៃប្រទេស CLMTV។

២. អង្គសន្និសីទ សូមប្រើប្រាស់គ្រប់យន្តការនៃកិច្ចពិភាក្សាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគីដើម្បីសម្រេចឱ្យបាននូវសេចក្តីថ្លែងការណ៍រួមរបស់រដ្ឋមន្ត្រីការងារស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍នៃ ប្រទេស CLMTV តាមផែនការដែលបានគ្រោងទុក។

៣. សូមបន្តពង្រឹង និងពង្រីកការអនុវត្តកិច្ចសហប្រតិបត្តិការលើវិស័យការងារឱ្យកាន់តែស៊ីជម្រៅចំណោមប្រទេស CLMTV និងជាមួយដៃគូពាក់ព័ន្ធ ដើម្បីធានាពីការការពារសិទ្ធិ និងអត្ថប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍។

សម្តេចតេជោ ហ៊ុន សែន សង្ឃឹមថា ការបន្តកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត និងអង្គការជាដៃគូអភិវឌ្ឍន៍នានានឹងកាន់តែជិតស្និទ្ធថែមទៀត ដើម្បីរួមគ្នាសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ និងដើម្បីវឌ្ឍនភាពរួមរបស់ប្រទេសទាំង៥៕Ha

## ប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន អញ្ជើញបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខ័ណ្ឌ CLMTV នៅខេត្តសៀមរាប

http://www.freshnewsasia.com/ 2019-09-17

(សៀមរាប)៖ នៅព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV រួមមាន៖ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម» ដែលកម្មវិធីនេះត្រូវបានរៀបចំ នៅសណ្ឋាគារអប្សរាផាឡេស ខេត្តសៀមរាប។

ខាងក្រោមជាប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន៖

* សម្តេចតេជោ ហ៊ុន សែន ចាប់ផ្តើមថ្លែងសុន្ទរកថា បើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខ័ណ្ឌ CLMTV

* សម្តេចតេជោ ហ៊ុន សែន លើកឡើងថា កាលមុនយើងមានតែ CLMV តែពេលនេះ យើងមិនអាចបោះបង់ចោលថៃទេ ហើយបានក្លាយទៅជា CLMTV។

* សម្តេចតេជោ កោតសរសើរក្រសួងការងារកម្ពុជា ដែលបានធ្វើការយ៉ាងល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ការងារលើកទី៣ និងរដ្ឋមន្ត្រីការងារលើកទី៥។

* សម្តេចតេជោ បានអបអរសាទរ ដល់វឌ្ឍនភាព នៃវិស័យការងារ នៅក្នុងប្រទេស CLMTV។

* សម្តេចតេជោ បញ្ជាក់ថា កាលមុនការធ្វើទេសន្តរប្រវេសន៍សម្រាប់ធ្វើការងារ នៅតែប្រទេសជាប់ព្រំដែនប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្ន ដោយសារតែមធ្យោបាយកាន់តែច្រើន ធ្វើឱ្យប្រជាជនងាយស្រួលរកការងារធ្វើនៅតាមបណ្តាប្រទេស។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា នៅក្នុងក្របខណ្ឌ CLMTV ក៏គិតគូរអំពីរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ ដែលគាត់ផ្លាស់ប្តូរការងារពីកន្លែងមួយទៅកន្លែងមួយ។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា កម្ពុជាគាំទ្រចំពោះការដាក់ចេញបទដ្ឋានគតិយុត្តទាំងឡាយ ដែលគាំទ្រដល់ពលករទេសន្តរប្រវេស។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ដំណាក់កាលមុន ការឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយមិនស្រួលទេ ជាពិសេស ដំណាក់កាលសង្គ្រាមត្រជាក់។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ពេលសង្គ្រាមត្រជាក់ វៀតណាមបានបញ្ជូនពលករ ទៅសូវៀត និងអឺរ៉ុប។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា សមាហរណកម្ម បានធ្វើឱ្យពលករខ្មែរមានឱកាសធ្វើការងារនៅក្រៅប្រទេស។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា បច្ចុប្បន្ននេះប្រទេសជប៉ុន កំពុងបង្កលក្ខណៈងាយស្រួលសម្រាប់ពលករទៅធ្វើការហើយ ខណៈដែលប្រទេសកូរ៉េខាងត្បូង ទទួលពលករច្រើន។

* សម្តេចនាយករដ្ឋមន្ត្រី អះអាងថា សម្រាប់ប្រទេសអាស៊ាន ដែលខ្វះកម្លាំងពលកម្មពិតប្រាកដគឺ ប្រ៊ុយណេ សាំងហ្គាពួ និងម៉ាឡេស៊ី។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ថៃជាប្រទេសទទួលពលករច្រើនចេញពីកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ប្រសិនបើថៃបណ្តេញពលករប្រទេសទាំងនេះចេញ នោះ សេដ្ឋកិច្ចថៃនឹងធ្លាក់ចុះធ្ងន់តែម្តង។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា មិនដឹងចង្រៃអ្វីនៅកម្ពុជា ពេលយើងខិតខំរកឱកាសការងារជូនពលរដ្ឋនៅក្រៅប្រទេស បែរជាមានគេចាត់ទុកថា យើងបញ្ជូនពលរដ្ឋខ្លួនឯង ឲ្យទៅស៊ីឈ្នួលគេទៅវិញ បើមិនធ្វើការទេធ្វើម្តេចយើងរស់បាន ធ្វើការមានក្នុង និងក្រៅប្រទេស។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ការមានការងារធ្វើ វាជាការខិតខំប្រឹងប្រែងក្នុងក្របខណ្ឌអាស៊ាន ខណៈដែល ហ្វីលីពីនមានពលករច្រើនជាងគេបង្អស់ ក្នុងការបញ្ជូនពលករទៅក្រៅប្រទេស។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ចុងឆ្នាំ២០១៧ និង២០១៨ សម្តេចបានជួបជាមួយពលករខ្មែរ១លាននាក់។

* សម្តេចតេជោ ថ្លែងថា កម្ពុជាកំពុងពិភាក្សាជាមួយភាគីថៃ ដើម្បីរៀបចំរក្សាទុកអតីតភាពការងារជូនពលករកម្ពុជា ដែលធ្វើការនៅទីនោះ ពេលមកធ្វើការនៅប្រទេសកម្ពុជាវិញ។

* សម្តេចតេជោ ថ្លែងថា CLMTV អាចពិភាក្សាគ្នា ដើម្បីសម្រួលដល់ពលករដែលកំពុងធ្វើការនៅបរទេស ហើយផ្លាស់ប្តូរទៅប្រទេសផ្សេងក្នុងក្របខណ្ឌនេះ ឬចូលមកកម្ពុជា អាចរក្សាទុកនៅអតីតភាពការងារដដែល។

* សម្តេច ហ៊ុន សែន រំលឹករឿងចាស់ ពេលអ្នកស្រី អោង សាន ស៊ូជី អំពាវនាវឱ្យពលករខ្លួនចេញពីថៃទៅស្រុកវិញ តើរហូតមកដល់ពេលនេះ មានពលករមីយ៉ាន់ម៉ាប៉ុន្មាន បានត្រឡប់ទៅប្រទេសខ្លួនវិញ? រឿងនេះបក្សប្រឆាំងកម្ពុជាបែរជាវាយប្រហារសម្តេច។

* សម្តេចថ្លែងថា ទីបំផុតពលករមីយ៉ាន់ម៉ា មិនបានទៅផ្ទះតាមការអំពាវនាវរបស់ អ្នកស្រី អោង សានស៊ូជីទេ មានតែទៅធ្វើការនៅប្រទេសថៃ កាន់តែច្រើន ដោយសារតែតម្លៃពលកម្មនៅមីយ៉ាន់ម៉ាតិចតួច។

* សម្តេចតេជោ ហ៊ុន សែន ជំរុញឱ្យ CLMTV សិក្សាធ្វើយ៉ាងណាឱ្យពលករនៅក្រៅប្រទេស ទទួលបានរបបសន្តិសុខសង្គម ដែលពួកគេនៅតែបន្តទទួលបាន អតីតភាពការងារ ពេលផ្លាស់ប្តូរទៅប្រទេសផ្សេង។

* សម្តេចតេជោ ថ្លែងថា ឥឡូវនេះ ការចល័តពលករ មិនមែនធ្វើត្រឹមអាស៊ានទេ ពលករខ្លះ បានទៅធ្វើការដល់ប្រទេសនៅមជ្ឈបូព៌ាឯណោះ។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា នៅប្រទេសណាក៏ត្រូវធ្វើការដែរ នៅខ្មែរក៏ត្រូវធ្វើការដែរ ទើបមានបាយហូប។

* សម្តេចតេជោ បញ្ជាក់ថា កម្ពុជាពិតជាមានកិត្តិយសដែលបានធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំ CLMTV ស្របពេលដែលរាជរដ្ឋាភិបាល ដាក់ចេញគោលនយោបាយទេសន្តរប្រវេស៍ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ក្នុងក្របខណ្ឌជាតិគាំពារសង្គម កម្ពុជាបានដោះស្រាយលើកម្មការិនី គឺសម្រាប់ស្ត្រីសម្រាលកូន នៅកម្ពុជាឱ្យសម្រាក៣ខែ ទទួលបៀវត្ស១២០ភាគរយ ហើយរដ្ឋជួយឧបត្ថម្ភបើកើតកូន១ គឺ ១០០ដុល្លារ កូន២ គឺ២០០ដុល្លារ។

* សម្តេចប្រាប់ឲ្យពិនិត្យពលករបរទេស ដែលមកធ្វើការនៅកម្ពុជា ទទួលបាននូវការព្យាបាលដោយឥតគិតថ្លៃ ហើយកម្ពុជា ក៏ចង់ឱ្យប្រទេសដទៃ ធ្វើបែបនេះចំពោះពលករខ្មែរដូចគ្នា។

* សម្តេចតេជោ ហ៊ុន សែន ដាក់ចេញគោលការណ៍៣ចំណុចសំខាន់ៗ ដល់ប្រទេសសមាជិក CLMTV ដើម្បីសម្រេចបានសេចក្តីថ្លែងការណ៍រួម។

* សម្តេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសុន្ទរកថា នៅវេលាម៉ោង ០៩៖១០នាទីព្រឹក៕

## ក្រសួងមហាផ្ទៃចុះ MOU ជាមួយអង្គការចំនួន ៥ ដើម្បីជួយកុមារ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 16 September 2019 | 16:27 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) ជាមួយអង្គការសង្គមស៊ីវិលចំនួន ៥ ដែលធ្វើការប្រឆាំងការជួញដូរមនុស្ស ជាពិសេសផ្តោតលើការការពារកុមារ ក្នុងគោលដៅរួមគ្នាការពារ និងប្រឆាំងបទល្មើសទៅលើកុមារជាពិសេសអំពើជួញដូរមនុស្សនៅកម្ពុជា។ ការចុះកិច្ចព្រមព្រៀងដាច់ដោយឡែកពីគ្នាជាមួយអង្គការទាំង ៥ នេះ បានធ្វើឡើងកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន នៅទីស្តីការក្រសួងដឹកនាំដោយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជា។

លោកស្រី ជូ ប៊ុនអេង បានប្រាប់ភ្នំពេញប៉ុស្ដិ៍ ពីថ្ងៃព្រហស្បតិ៍ថា កិច្ចព្រមព្រៀងចំនួន ៣ ត្រូវបានធ្វើឡើងរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជា ជាមួយអង្គការសម្ព័ន្ធចាប់ដៃ(CHAB DAI COALITION) អង្គការដែនដីមនុស្សហូឡង់ប្រចាំកម្ពុជា(Terre Des Hommes "Stops Child Explotation")រួមនឹងអង្គការការីតាស។ ចំណែកកិច្ចព្រមព្រៀង ២ ទៀត បានធ្វើឡើងរវាងក្រសួងមហាផ្ទៃនិងអង្គការសកម្មភាពដើម្បីកុមារ (APLE) និងអង្គភាពការពារកុមារ CPU។ លោកស្រី ជូ ប៊ុនអេង បានបន្ថែមថា ការសហការគ្នានេះ គឺដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ខណៈសកម្មភាពខ្លះ គឺរួមគ្នាលើកកម្ពស់សុខុមាលភាពសង្គមក្នុងការទប់ស្កាត់ និងឆ្លើយតបឲ្យកាន់តែល្អប្រសើរលើសិទ្ធិកុមារ និងឲ្យប្រាកដថាកុមារទទួលបាននូវការការពារ តាមរយៈសកម្មភាពរបស់អង្គការទាំងនេះ។ លោកស្រីបន្តថា៖ «អង្គការទាំងនេះ មានខ្លះមិនមែនជាលើកទី ១ ទេ (MOU) ព្រោះខ្លះបន្ត MOU ដល់ទៅ ៣ ដងជាប់គ្នា ដើម្បីជួយការងាររដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស និងការអនុវត្តច្បាប់សម្រាប់ផ្តន្ទាទោសជាដើម។ អង្គការខ្លះរហូតដល់មានការជួយដល់ការធ្វើមាតុភូមិវត្តន៍នីតិសម្បទានៅតាមសហគមន៍»។ លោកស្រី ជូ ប៊ុនអេង បានបន្តថា៖ «តាម

គោលនយោបាយរបស់រដ្ឋាភិបាលបើកទូលាយសម្រាប់កិច្ចសហប្រតិបត្តិការដោយសារមានអង្គការជាច្រើនកំពុងធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយអង្គការមួយចំនួនធ្វើការជាមួយកុមារ និងមួយចំនួនទៀតកំពុងធ្វើការពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកជាដើម។ ដូច្នេះអង្គការទាំងនោះគួរចូលរួមចំណែកប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សជាមួយរដ្ឋាភិបាល។

លោក សំ លៀង សីលា នាយកប្រតិបត្តិអង្គការ APLE ក្នុងចំណោមអង្គការ ៥ ដែលបានចុះកិច្ចព្រមព្រៀងនេះបានថ្លែងថា នេះជាមោទនភាពមួយរបស់អង្គការសង្គមស៊ីវិល បន្ទាប់ពីបានចុះហត្ថលេខាលើអនុស្សរណៈនេះ ដែលជាការឆ្លុះបញ្ចាំងពីការចូលរួមចំណែកក្នុងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូដ៏រឹងមាំ។

ចំណែក លោក James McCabe នាយកប្រតិបត្តិអង្គភាព CPU ប្រាប់ភ្នំពេញប៉ុស្តិ៍ថា សម្រាប់កិច្ចព្រមព្រៀងថ្មីដែលបន្ត ៣ ឆ្នាំទៀតនេះ លោកនឹងបន្តគាំទ្រ និងធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា និងនគរបាលជាតិកម្ពុជាក្នុងការស៊ើបអង្កេតអំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ជាពិសេសឧក្រិដ្ឋកម្មដែលកើតមានលើកុមារកម្ពុជា។ លោកបានបញ្ជាក់ថា៖ « អាជ្ញាធរកម្ពុជា ក៏ប្រយុទ្ធប្រឆាំងនឹងបទល្មើសទាំងនេះ បានយ៉ាងល្អតាមរយៈរបាយការណ៍ និងនីតិវិធីរបស់សមត្ថកិច្ច ហើយរដ្ឋាភិបាលកម្ពុជាពិតជាបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ពួកគេ និងឆាប់រហ័សក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មប្រឆាំងកុមារ ស្របពេលដែលនគរបាលជាតិកម្ពុជាកំពុងស៊ើបអង្កេតលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលបានប្រព្រឹត្តនៅទូទាំងប្រទេស ហើយនឹងស៊ើបអង្កេតផងដែរ លើឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតប្រឆាំងនឹងកុមារ» ។ លោកបានបន្តថា សមត្ថកិច្ចបានបង្ក្រាប និងចាប់ខ្លួនបានរហូតដល់ ៨៦ ភាគរយ នៃបទល្មើសលើកុមារអាយុក្រោម ១៥ ឆ្នាំ ដែលនេះជាសមិទ្ធផលមិនធម្មតាមួយ សូម្បីតែនៅប្រទេសលោកខាងលិចក៏មិនអាចធ្វើបានដូច្នេះដែរ។

យោងតាមរបាយការណ៍ក្រសួងមហាផ្ទៃ នៅក្នុងរយៈពេល ៦ ខែដើមឆ្នាំនេះ សមត្ថកិច្ចបានជួយសង្គ្រោះជនរងគ្រោះពីការរំលោភបំពានផ្លូវភេទបានចំនួន ២៦៣ នាក់ ដែលមានការកើនឡើងរហូតដល់ជិត ១៥០ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ក្នុងនោះជនរងគ្រោះជាកុមារ ដែលមានអាយុក្រោម ១៥ ឆ្នាំ មានរហូតដល់ចំនួន ៧០ នាក់ និងចន្លោះពី ១៥ ទៅ ១៨ ឆ្នាំ មានចំនួន ៣១ នាក់ដែលស្មើនឹងជិតពាក់កណ្តាលនៃចំនួនជនរងគ្រោះសរុបទាំងអស់៕

## នគរបាលប្រឆាំងការជួញដូរមនុស្ស បង្ក្រាបទីតាំងហាងម៉ាស្សាអ័រគីដេ ដែលបង្កប់បំរើសេវាផ្លូវភេទ

http://www.freshnewsasia.com/ 2019-09-17

**(ភ្នំពេញ)៖** កម្លាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចុះប្រតិបត្តិការស្រាវជ្រាវ សហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌសែនសុខ បានឃាត់ខ្លួនមនុស្សចំនួន៣៧នាក់ ពាក់ព័ន្ធករណីប្រព្រឹត្តិអំពើសញ្ចារកម្ម ក្នុងនោះមាន៖ អ្នកគ្រប់គ្រង៣នាក់, បុគ្គលិកធម្មតា៤នាក់, សន្តិសុខម្នាក់, នារីម៉ាស្សា២៣នាក់ (សង្ស័យជាអនីតិជនចំនួន២នាក់) និងភ្ញៀវ៦នាក់។

ដោយនៅក្នុងប្រតិបត្តិការនេះ ធ្វើឡើងនៅម៉ោង៩៖៣០នាទីយប់ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ នៅចំណុចហាងម៉ាស្សា យីហោអ័រគីដេ ផ្ទះលេខC១៤ ផ្លូវលេខ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ប្រតិបត្តិការនេះ ដោយមានការចង្អុលបង្ហាញពីឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរង និងជាស្នងការនគរបាលរាជធានីភ្នំពេញ សម្របសម្រួលពីលោកស្រី ស៊ី វណ្ណនី ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ និងដឹកនាំផ្ទាល់ដោយលោកឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

យោងតាមនគរបាលជំនាញបានឲ្យភ្នាក់ងារ Fresh News ដឹងថា ហាងម៉ាស្សានេះបើកដំណើរការ២៤ម៉ោង ហើយមាននារីបម្រើសេវាម៉ាស្សាចំនួន២៣នាក់ ជាជនជាតិខ្មែរ ក្នុងនោះមាន០២នាក់ ត្រូវបានសង្ស័យថា ជាអនីតិជន ដែលមានអាយុចន្លោះពី១៦ឆ្នាំទៅ១៧ឆ្នាំ។ សូមបញ្ជាក់ផងដែរថា ទីតាំងហាងម៉ាស្សាមានបន្ទប់សម្រាប់ម៉ាស្សាសរុប ចំនួន២៧បន្ទប់ ចំពោះតម្លៃសេវារួមភេទដោយប្រើដៃ មានចាប់ពី៣០ដុល្លារឡើងទៅ និងរួមភេទចាប់ពី៥០ដុល្លារ ឡើងទៅ។ លុយដែលទទួលបានពីភ្ញៀវនោះ មួយចំនួនត្រូវបានចែកទៅឲ្យមេការ ភេទប្រុស០៣នាក់ ដែលជាជនជាតិខ្មែរ។

សមត្ថកិច្ចជំនាញបានបន្តទៀតថា មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យខាងលើ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការស្រាវជ្រាវ ស៊ើបអង្កេតជាច្រើនថ្ងៃ រហូតដល់ស៊ីជំរៅ បានចុះប្រតិបត្តិការទៅឃាត់ខ្លួនមេការគ្រប់គ្រងចំនួន០៣នាក់ និងនារីម៉ាស្សាចំនួន២៣នាក់ ភ្លាមៗតែម្តង និងដកហូតវត្ថុតាងស្រោមអនាម័យមួយចំនួន នាំមកការិយាល័យជំនាញ។ ក្រោយបញ្ចប់ការសាកសួរ ចំពោះអ្នកដែលពុំពាក់ព័ន្ធ សមត្ថកិច្ចជំនាញអនុញ្ញាត ឲ្យត្រឡប់ទៅវិញជាធម្មតា។

បច្ចុប្បន្នសមត្ថកិច្ចបានឃាត់ខ្លួន បុរសមេការចំនួន០៣នាក់ជាបន្តអាសន្ន ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី។ ចំណែកឯនារីបំរើសេវាម៉ាស្សា ត្រូវបានសមត្ថកិច្ចប្រគល់ជូន មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## រដ្ឋមន្ត្រីការងារកម្ពុជា-ថៃ ប្តេជ្ញាខិតខំដោះស្រាយបញ្ហាថ្មីៗ ដែលកើតមានចំពោះពលករប្រទេសទាំងពីរ

http://www.freshnewsasia.com/ 2019-09-17

**(សៀមរាប)៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា រួមជាមួយលោក ឆាធុមង្គល សុណាគុល (Chatumongol Sonakul) រដ្ឋមន្ត្រីក្រសួងការងារថៃ បានប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការដែលបានព្រមព្រៀងជាមួយគ្នារួចហើយ នាពេលកន្លងមក និងខិតខំដោះស្រាយបញ្ហាថ្មីៗ ដែលកើតមានលើពលករនៃប្រទេសទាំងពីរ។

ការប្តេជ្ញាខាងលើនេះ ត្រូវបានធ្វើឡើងនាឱកាសដែលថ្នាក់ដឹកនាំទាំងពីរជួបពិភាក្សាគ្នា នាល្ងាចថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ពេលគឺនៅកំលុងពេលចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃស្អែកនេះ នៅខេត្តសៀមរាប។

ភាគីទាំងពីរបានសម្តែងការពេញចិត្ត ចំពោះលទ្ធផលកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារ នៃប្រទេស CLMTV លើកទី៣នេះ ដែលបានសម្រេចការឯកភាពគ្នាលើសេចក្តីព្រាងផែនទីបង្ហាញផ្លូវសៀមរាប ដើម្បីឆ្ពោះទៅកាន់សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីការងារ ស្តីពីចល័តភាពនៃរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងប្រទេស CLMTV។

លោក អ៊ិត សំហេង បានថ្លែងអំណរគុណចំពោះរដ្ឋមន្ត្រីក្រសួងការងារថៃ ដែលបានសម្របសម្រួលការដំណើរការ ផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលធ្វើការនៅប្រទេសថៃ នាពេលកន្លងមក ហើយពលករទាំងនោះក៏ទទួលបានការគាំពារពេញលេញ ស្របតាមច្បាប់នៃប្រទេសថៃផងដែរ។

ជាមួយគ្នានេះ លោករដ្ឋមន្ត្រីថៃក៏បានសន្យាថា នឹងពង្រឹងកិច្ចសហប្រតិបត្តិការលើពលករខ្មែរ ដែលនឹងផុតសុពលភាពធ្វើការនៅប្រទេសថៃ ដោយរៀបចំយន្តការបន្ថែមទៀត មិនចាំបាច់តម្រូវឱ្យពួកគេមានការចំណាយច្រើន ក្នុងពេលត្រឡប់មកប្រទេសកម្ពុជាវិញឡើយ។

រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា និងថៃ ក៏ថែមទាំងបានប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការលើអ្វី ដែលបានព្រមព្រៀងគ្នាហើយ និងខិតខំដោះស្រាយបញ្ហាថ្មីៗ ដែលកើតឡើងនាពេលខាងមុខបន្ទាប់ទៀត ដើម្បីពង្រឹងសុខុមាលភាពរបស់ពលករនៃប្រទេសទាំងពីរ ជាពិសេសពលករនេសាទ៕

## បច្ចុប្បន្នពលករមីយ៉ាន់ម៉ាធ្វើការនៅកម្ពុជាមានលើសពី ១ពាន់នាក់ ខណៈរដ្ឋមន្ត្រីកម្ពុជាក៏ចង់ឱ្យចំនួននេះកើនថែមទៀត

http://www.freshnewsasia.com/ 2019-09-17

**(សៀមរាប)៖** បច្ចុប្បន្នពលករមីយ៉ាន់ម៉ាដែលបម្រើការងារនៅកម្ពុជាមានជាង ១,៣០០នាក់ ដោយទទួលបានបណ្ណការងារជនបរទេសពីក្រសួងការងារកម្ពុជា ក្នុងនោះមានប្រមាណ ១៨០នាក់ ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ខណៈរដ្ឋមន្ត្រីក្រសួងការងារកម្ពុជាក៏បង្ហាញការរំពឹងទុកថា ចំនួននេះនឹងមានការកើនឡើងបន្ថែមទៀត។

ការបញ្ជាក់យ៉ាងដូច្នេះ ត្រូវបានធ្វើឡើងនាឱកាសលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលជួបពិភាក្សាជាមួយលោក យូ ធានស្វេ (U Thein Swe) រដ្ឋមន្ត្រីក្រសួងការងារ អន្តោប្រវេសន៍ និងប្រជាជនមីយ៉ាន់ម៉ា នាល្ងាចថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ពេលគឺនៅកំលុងពេលលោករដ្ឋមន្ត្រីមីយ៉ាន់ម៉ា ដឹកនាំគណៈប្រតិភូចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ នៃកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៧ ខែកញ្ញា ស្អែកនេះ។ ក្នុងជំនួបនោះភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះលទ្ធផលកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារ នៃប្រទេស CLMTV ដែលបានធ្វើឡើងនៅថ្ងៃនេះ ដោយបានសម្រេចការឯកភាពគ្នាលើសេចក្តីព្រាងផែនទីបង្ហាញផ្លូវសៀមរាប ដើម្បីឆ្ពោះទៅកាន់សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីការងារស្តីពី ចល័តភាពនៃរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តរប្រវេសន៍ ក្នុងប្រទេស CLMTV។

លោករដ្ឋមន្ត្រី អ៊ិត សំហេង បានជម្រាបរដ្ឋមន្ត្រីមីយ៉ាន់ម៉ាថា «ពលករមីយ៉ាន់ម៉ាប្រមាណជាង ១,៣០០នាក់ ទទួលបានបណ្ណការងារជនបរទេសនៅកម្ពុជា ហើយមានប្រមាណ ១៨០នាក់ ជាសមាជិក ប.ស.ស»។ លោក អ៊ិត សំហេង ក៏បានបង្ហាញការរំពឹងថា ចំនួននេះនឹងកើនឡើងបន្តទៀត ខណៈបច្ចុប្បន្ននេះពលករមីយ៉ាន់ម៉ាដែលកំពុងធ្វើការនៅកម្ពុជា ក៏ទទួលបានការការពារសិទ្ធិ និងអត្ថប្រយោជន៍ ដូចកម្មករនិយោជិតកម្ពុជាដែរ។

ភាគីទាំងពីរបានបង្ហាញឆន្ទៈពង្រឹងចំណងមិត្តភាពឱ្យកាន់តែជិតស្និទ្ធ ក៏ដូចជាបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀត ជាពិសេសក្នុងការការពារពលករ និងការផ្លាស់ប្តូរបទពិសោធន៍ ដើម្បីការពង្រឹងជំនាញរបស់ពលករទៅវិញទៅមក៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 16-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកចាក់ព្រៃង ខេត្តព្រះវិហារ៕

# ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៩

## នាយករដ្ឋមន្ត្រីកម្ពុជា៖ និន្នាការកំណើនមនុស្សចាស់ ធ្វើឲ្យជប៉ុនចាប់ផ្តើមបង្កភាពងាយស្រួល សម្រាប់ទទួលយកពលករ ខណៈប្រទេសកូរ៉េខាងត្បូង ទទួលយកពលករយ៉ាងច្រើន

http://www.freshnewsasia.com/ 2019-09-17

**(សៀមរាប)៖** ថ្លែងក្នុងពិធីបើកសន្និសីទ ថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV រួមមាន៖ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារ ពលករទេសន្តរប្រវេសន៍ នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម» នាខេត្តសៀមរាប នៅព្រឹកថ្ងៃទី១៧ ខែកញ្ញានេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជាបានលើកឡើងថា ដោយសារតែនិន្នាការ នៃកំណើនមនុស្សចាស់ ធ្វើឲ្យប្រទេសជប៉ុន បង្កភាពងាយស្រួល សម្រាប់ការទទួលយកពលករពីប្រទេស ដែលមានកម្លាំងពលកម្មវ័យក្មេង។ ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានមើលឃើញថា កូរ៉េខាងត្បូងបានក្លាយជាប្រទេសដែលទទួលយកពលករច្រើនជាងគេផងដែរ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងយ៉ាងដូច្នេះថា **«យើងឃើញថានិន្នាការ នៃមនុស្សចាស់ នៅក្នុងប្រទេសមួយចំនួន ក៏បានកើតទៅជាស្ថានភាព ដែលអាចផ្តល់ការងារឲ្យប្រទេសមួយចំនួន ដែលមានកម្លាំងពលកម្មវ័យក្មេង ឧទាហរណ៍នៅប្រទេសជប៉ុន ចាប់ផ្តើមបង្កើតភាពងាយស្រួល សម្រាប់ការបញ្ជូនពលករ ទៅកាន់ប្រទេសជប៉ុនហើយ ទន្ទឹមនឹងកូរ៉េខាងត្បូង បានយកពលករយ៉ាងច្រើន ទៅកាន់ទីនោះ»**។ ដោយសារមានទំនាក់ទំនង កិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា និងកូរ៉េខាងត្បូង ក្នុងការបញ្ជូនពលករនោះ គិតត្រឹមខែសីហា ឆ្នាំនេះពលករកម្ពុជានៅប្រទេសកូរ៉េមានចំនួនជាង៦ម៉ឺននាក់ ក្នុងចំណោមពលរដ្ឋកម្ពុជា ដែលរស់នៅប្រទេសកូរ៉េជាង៦ម៉ឺននាក់។ កូរ៉េបានផ្តល់កូតាក្នុងការនាំពលករដល់កម្ពុជា ពី៤ពាន់ទៅ៤ពាន់៥រយនាក់ ក្នុងឆ្នាំ២០១៩នេះ។ នេះបើតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែកគិតត្រឹមខែកក្កដា ឆ្នាំ២០១៩ កម្មសិក្សាការី និងពលករកម្ពុជាទៅធ្វើការនៅប្រទេសជប៉ុនមានចំនួនជាង៨ពាន់នាក់។

ថ្លែងក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ដោយធ្វើសមាហរណកម្មកាន់តែប្រសើរ នៅក្នុងក្របខ័ណ្ឌតំបន់ អនុតំបន់ និងនៅក្នុងក្របខ័ណ្ឌដៃគូដទៃទៀត ជាមួយនឹងការទទួលព័ត៌មានអំពីទីផ្សារកាងារ និងមធ្យោបាយដឹកជញ្ជូនកាន់តែប្រសើរ និងកាន់តែលឿនជាងមុន ដូច្នេះធ្វើឲ្យប្រជាពលរដ្ឋរបស់យើង មានឱកាសដើម្បីស្វែងរកការងារធ្វើ។ សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ផងដែរថា ប្រទេសដែលខ្វះកម្លាំងពលកម្មពិតប្រាកដ មានត្រឹមតែ៣ប្រទេសប៉ុណ្ណោះ គឺមានព្រុយណេ សិង្ហបុរី និងម៉ាឡេស៊ី ប៉ុន្តែសម្រាប់ប្រទេសក្រៅពីនោះ គឺមានកម្លាំងពលកម្ម សូម្បីប្រទេសថៃ ដែលទទួលកម្លាំងពលកម្មពីកម្ពុជា មីយ៉ានម៉ា និងឡាវ ប៉ុន្តែប្រទេសថៃបានបញ្ជូនពលករ ទៅកាន់ប្រទេសដទៃទៀត ដែលទទួលបានប្រាក់ឈ្នួលបានខ្ពស់ជាង ដែលនេះជាចរន្តការងារធម្មតា៕

## កម្ពុជាប្រកាសគាំទ្រគំនិតផ្តួចផ្តើមរបស់ CLMTV ក្នុងការរៀបចំរបបសន្តិសុខសង្គម សម្រាប់ពលករក្រៅប្រទេស

http://www.freshnewsasia.com/ 2019-09-17

**(ភ្នំពេញ)៖** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានប្រកាសគាំទ្រចំពោះគំនិតផ្តួចផ្តើមរបស់ CLMTV ដែលគិតគូរអំពីចល័តភាព នៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ដើម្បីបង្កលទ្ធភាពឱ្យពលករទាំងនោះ នៅតែទទួលបានអត្ថប្រយោជន៍ពី របបសន្តិសុខសង្គម ទោះបីពួកគេផ្លាស់ទីកន្លែងធ្វើការពីកន្លែងមួយទៅកន្លែងមួយ ឬពីប្រទេសមួយទៅប្រទេសមួយក៏ដោយ។ គំនិតផ្តួចផ្តើមប្រទេសទាំង៥ ដែលរួមមានកម្ពុជា ឡាវ មីយ៉ាន់

ម៉ា ថៃ និងវៀតណាម នេះ នឹងផ្តល់សារប្រយោជន៍ដល់ពលករក្រៅប្រទេស ឱ្យទទួលបានការបន្តអតីតភាពការងារ ទោះបីជាពួកគេត្រូវផ្លាស់ប្តូរប្រទេសធ្វើការយ៉ាងណាក៏ដោយ។

ថ្លែងក្នុងពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខ័ណ្ឌ CLMTV នៅខេត្តសៀមរាប នាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩នេះ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា «**ចំណុចនេះមិនមែនជាគោលបំណងដោយឡែករបស់កម្ពុជានោះទេ ប៉ុន្តែជាគោលបំណងរួមគ្នានៃបណ្តាប្រទេស CLMTV ក៏ដូចជាសហគមន៍អាស៊ាន និងបណ្តាប្រទេសនានាលើសកលលោកផងដែរ**»។ សម្តេចបានបន្តថា ក្នុងនាមជាសមាជិកនៃកិច្ចសហប្រតិបត្តិការលើវិស័យការងារនៃប្រទេស CLMTV កម្ពុជាសូមសម្តែងនូវការគាំទ្រយ៉ាងមុតមាំចំពោះគំនិតផ្តួចផ្តើមនេះ។ កម្ពុជាបានដាក់ចេញនូវគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីគាំពារសិទ្ធិ និងអត្ថប្រយោជន៍ទាំងពលករទេសន្តរប្រវេសន៍កម្ពុជាដែលទៅធ្វើការនៅបរទេស ទាំងពលករទេសន្តរប្រវេសន៍បរទេសដែលមកធ្វើការនៅកម្ពុជា។ ទន្ទឹមនឹងបទប្បញ្ញត្តិជាតិនេះ កម្ពុជាបានធ្វើ និងកំពុងអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារជាមួយប្រទេសមួយចំនួនក្នុងចំណោមប្រទេសទាំង៤ផងដែរ។ ទាំងនេះគឺជាការចូលរួមចំណែកអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នូវសេចក្តីថ្លែងការណ៍អាស៊ានទីក្រុងសេប៊ូ និងឯកច្ឆ័ន្ទភាពស៊ានទីក្រុងម៉ានីល និងជាការជំរុញឱ្យគោលបំណងនៃប្រទេស CLMTV ដែលបានឯកភាពគ្នាពាក់ព័ន្ធនឹងចល័តភាពនៃរបបសន្តិសុខសង្គម ទទួលបានជោគជ័យ។

ក្នុងចំណោមប្រទេសអាស៊ានទាំង១០ ប្រទេសហ្វីលីពីនគឺជាអ្នកបញ្ជូនពលករទៅធ្វើការងារក្រៅប្រទេសច្រើនជាងគេបង្អស់ ខណៈដែលកម្ពុជាមានពលករប្រមាណ១,២លាននាក់ កំពុងធ្វើការនៅក្រៅប្រទេស ក្នុងនោះមានប្រទេសថៃច្រើនជាងគេ បន្ទាប់មកគឺនៅកូរ៉េខាងត្បូង។ ចំណែកប្រទេសអាស៊ាន ដែលកំពុងខ្វះខាតកម្លាំងពលកម្មមានដូចជាប្រទេសប្រ៊ុយណេ សិង្ហបុរី និងម៉ាឡេស៊ីជាដើម។ សម្តេចតេជោ ហ៊ុន សែន បានបន្តថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញគោលនយោបាយច្បាស់លាស់ទាក់ទងនឹងទេសន្តរប្រវេសន៍ការងារ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដែលបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើកំណែទម្រង់គ្រប់វិស័យ។ សម្តេចបានគូសបញ្ជាក់ថា ក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម រាជរដ្ឋាភិបាលកម្ពុជាបានអភិវឌ្ឍរបបសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម។ សម្រាប់របបសន្តិសុខសង្គម ក្របខណ្ឌគោលនយោបាយនេះបានគិតគូរដល់មន្ត្រីរាជការសាធារណៈ កម្មករនិយោជិតវិស័យឯកជន ដោយបង្កើតឱ្យមានរបបធានារ៉ាប់រងសង្គមផ្នែកសុខុមាលភាព ជរាភាព ទុព្វលភាព មរណភាព និងហានិភ័យការងារ ដើម្បីធានាបាននូវសន្តិសុខប្រាក់ចំណូល បង្កើនផលិតភាពការងារ និងយុត្តិធម៌សង្គម។

សម្តេចបន្ថែមថា ជាលទ្ធផល កម្ពុជាបានដាក់ឱ្យដំណើរការនូវរបបហានិភ័យការងារ ថែទាំសុខភាព និងសោធននិវត្តន៍ដែលគ្របដណ្តប់លើសហគ្រាស គ្រឹះស្ថាន ផ្នែកផលិតកម្ម ផ្នែកសេវាកម្ម និងផ្នែកសាធារណៈ ស្ទើរតែ១០០%នៃកម្មករនិយោជិត និងមន្ត្រីសាធារណៈ។ ទន្ទឹមនឹងនេះ កម្ពុជាកំពុងរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមនៅឆ្នាំ២០១៨នេះ ដើម្បីពង្រីកវិសាលភាពបន្ថែមដល់ប្រជាពលរដ្ឋដែលប្រកបរបរស្វ័យនិយោជន៍និងពលករទេសន្តរប្រវេសន៍ផងដែរ។ តាមរយៈរបបសន្តិសុខសង្គមកម្ពុជានឹងមានប្រព័ន្ធគាំពារសង្គមមួយកាន់តែប្រសើរឡើង ដែលជួយដល់ការអភិវឌ្ឍ សុខុមាលភាពសង្គមជូនដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ និងធ្វើឱ្យសង្គមកាន់តែមានសមធម៌៕

## នាយករដ្ឋមន្ត្រីកម្ពុជា៖ កិច្ចប្រជុំ CLMTV ជាកិត្តិយសដ៏ធំសម្រាប់កម្ពុជា ស្របពេលដែលរដ្ឋាភិបាលដាក់ចេញគោលនយោបាយទេសន្តរប្រវេសន៍ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

http://www.freshnewsasia.com/ 2019-09-17

**(សៀមរាប)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានបញ្ជាក់ថា ការដែលប្រទេសកម្ពុជា បានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ច CLMTV នៅថ្ងៃនេះ គឺជាកិត្តិយសខ្លាំងណាស់របស់កម្ពុជា ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយទេសន្តរប្រវេស៍ ស្របតាមយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤។ ការមាន

ប្រសាសន៍បញ្ជាក់បែបនេះ របស់សម្ដេចតេជោ ហ៊ុន សែន បានធ្វើឡើងនៅព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩នេះ នៅក្នុងឱកាសដែលសម្ដេចតេជោ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV រួមមាន៖ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម» ដែលបានរៀបចំ នៅសណ្ឋាគារអប្សរាផាឡេស ខេត្តសៀមរាប។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍យ៉ាងដូច្នេះថា៖ **«កម្ពុជាពិតជាមានកិត្តិយសដ៏ឧត្តុង្គឧត្ដមក្នុងការធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំ ដ៏មានសារៈខាន់នេះ «CLMTV» ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយទេសន្តរប្រវេស៍ការងារ ស្របតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព ដែលផ្ដល់អត្ថិភាពលើការកែតម្រង់គ្រប់វិស័យ និងបានដាក់ចេញនូវគោលនយោបាយថ្មីមួយចំនួនដោយផ្ដោតការយកចិត្តទុកដាក់លើក្របខណ្ឌគោនយោបាយជាតិគាំពារសង្គម និងការគាំពារពលករទេសន្តរប្រវេស៍»**។ នាយករដ្ឋមន្ត្រីមួយរូប ដែលហ៊ានលះបង់អ្វីៗ គ្រប់យ៉ាងជូនមាតុភូមិកម្ពុជា សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍បន្តថា នៅក្នុងការអនុវត្តន៍ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមរាជរដ្ឋាភិបាលកម្ពុជា បានអភិវឌ្ឍន៍របបសន្តិសុខសង្គម និងប្រព័ន្ធជំនួយសង្គម ហើយសម្រាប់ របបសន្តិសុខសង្គម រាជរដ្ឋាភិបាលបានគិតគូរដល់មន្ត្រីរាជការសាធារណៈ កម្មករ កម្មការិនី និយោជិក វិស័យឯកជន ដោយបង្កើត ឱ្យមានរបបធានារ៉ាប់រងផ្នែក សុខមាលភាព ជរាភាព ទុព្វលភាព មរណភាព និងហានិភ័យការងារ ដើម្បីធានាបាននូវសន្តិសុខ ប្រាក់ចំណូល បង្កើនផលិតភាពការងារ និងយុត្តិធម៌សង្គមជាតិផងដែរ។

សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍បន្ថែមទៀតថា បន្ទាប់ពីកសាងជាតិឱ្យកាន់រីកចម្រើនជាលំដាប់នោះ ជាលទ្ធផលកម្ពុជាបានដាក់ ឱ្យដំណើរការនូវរបបហានិភ័យការងារ ថែទាំសុខភាព និងសោធននិវត្តន៍ដែលគ្របដណ្ដប់លើសហគ្រាស គ្រឹះស្ថាន ផ្នែកផលិតកម្ម ផ្នែកសេវាកម្ម និងផ្នែកសាធារណៈ ស្ទើរតែ១០០% នៃកម្មករនិយោជិត និងមន្ត្រីសាធារណៈ។ ទន្ទឹមនឹងនេះ កម្ពុជាកំពុងរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្ដីពី របបសន្តិសុខសង្គម នៅឆ្នាំ២០១៩នេះ ដើម្បីពង្រីកវិសាលភាពបន្ថែមដល់ប្រជាពលរដ្ឋដែលប្រកបរបរស្វ័យនិយោជន៍ និងពលករទេសន្តរប្រវេសន៍ ផងដែរ។ ប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ថា ស្របតាមរយៈរបបសន្តិសុខសង្គមកម្ពុជា បានបង្កើតប្រព័ន្ធគាំពារសង្គមមួយកាន់តែប្រសើរឡើង ដើម្បីជួយដល់ការអភិវឌ្ឍសុខុមាលភាពសង្គមជូនដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ធ្វើឱ្យសង្គមកាន់តែមានសមធម៌។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់បន្ថែមទៀតថា ក្នុងក្របខណ្ឌជាតិគាំពារសង្គម កម្ពុជាបានដោះស្រាយលើកម្មការិនី គឺសម្រាប់ស្ដ្រីសម្រាលកូន នៅកម្ពុជាឱ្យសម្រាក៣ខែ ទទួលបៀវត្ស១២០ភាគរយ ហើយរដ្ឋជួយឧបត្ថម្ភបើកើតកូន១ គឺ១០០ដុល្លារ កូន២ គឺ២០០ដុល្លារ។ ជាមួយគ្នានេះដែរ សម្ដេចតេជោ ក៏បានប្រាប់ម្ចាស់ក្រុមហ៊ុន ឱ្យពិនិត្យពលករបរទេស ដែលមកធ្វើការនៅកម្ពុជា ទទួលបាននូវការព្យាបាល ដោយឥតគិតថ្លៃ ហើយកម្ពុជា ក៏ចង់ឱ្យប្រទេសដទៃ ធ្វើបែបនេះចំពោះពលករខ្មែរដូចគ្នា៕

## មេដឹកនាំកម្ពុជា ស្នើឱ្យមេដឹកនាំថៃ ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ពិចារណា លើអត្ថប្រយោជន៍ នៃសោធនិវត្តពលករ

https://thmeythmey.com/ 17, Sep 2019 , 10:59 pm ដោយ: ធឿន បញ្ញាឬទ្ធិ

ភ្នំពេញ៖ ពីកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ការងារលើកទី៥ ក្នុងក្របខណ្ឌក្រុមប្រទេស CLMTV ( កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើឱ្យមេដឹកនាំប្រទេសទាំងនោះ ពិចារណាលើការរៀបចំអត្ថប្រយោជន៍នៃសោធនិវត្តពលករ។ ថ្លែងចំពោះមុខមេដឹកនាំCLMTV សម្ដេច ហ៊ុន សែន បានលើកពីបំណងរៀបចំផលប្រយោជន៍សម្រាប់ពលករ នៅពេលដែលពួកគេចាស់ទៅ ហើយត្រូវចូលនិវត្ត។ ក្នុងន័យនេះប្រមុខរ

ដ្ឋាភិបាលកម្ពុជា បានពន្យល់ថា ក្នុងករណីមានពលករខ្មែរម្នាក់ គាត់បានទៅធ្វើការនៅប្រទេសថៃ រយៈពេល១០ឆ្នាំ ហើយគាត់ត្រឡប់មកធ្វើការងារនៅកម្ពុជាវិញនោះ គឺក្រុមហ៊ុន ឬសហគ្រាស ត្រូវគិតថ្ងៃចូលធ្វើការងាររបស់គាត់ចាប់ពី ១០ឆ្នាំឡើងទៅ (រាប់ចាប់ពីធ្វើការនៅថៃ រយៈពេល១០ឆ្នាំ) ពោលគឺរាប់១០ឆ្នាំ ១ថ្ងៃ នៃចាប់ពីថ្ងៃផ្តើមការងារថ្មីនៅកម្ពុជាឡើយ។

ត្រង់ចំណុចនេះសម្តេច ហ៊ុន សែន បានបញ្ជាក់ក្នុងកិច្ចប្រជុំក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តរប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យសន្តិសុខសង្គម» នៅខេត្តសៀមរាប នាព្រឹកថ្ងៃអង្គារ ទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នេះ យ៉ាងដូច្នេះថា៖«ឥឡូវគេ(ពលករ) ធ្វើការនៅថៃប្រមាណ១០ឆ្នាំ អ៊ីចឹងគេត្រឡប់ទៅធ្វើការក្នុងប្រទេស តាមពេងចក្រតាមប្រទេស គឺមិនគិតពី១ថ្ងៃទេ គឺគិតពី១០ឆ្នាំឡើងទៅ។ ប៉ុន្តែការផ្ទេរអត្ថប្រយោជន៍ ផ្ទេរធនធានមកចិញ្ចឹមនោះ វាសុទ្ធតែជាបញ្ហា។ បើយើងធ្វើ(រៀបចំការផ្ទេរ) បែបនេះបាន ពាក្យថាដោគវាសនាអាស៊ានរួមគ្នាតែមួយ នឹងទទួលផលប្រយោជន៍ដល់ប្រជាជន»។

ដោយសារមើលឃើញពីបញ្ហានេះ ទើបលោកនាយករដ្ឋមន្ត្រីកម្ពុជា ស្នើឱ្យមេដឹកនាំឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ពិចារណាលើការរៀបចំអត្ថប្រយោជន៍សោធនិវត្តដល់ពលករនេះ មុននឹងដាក់ស្នើទៅអាស៊ានពិនិត្យនឹងសម្រេចរួមគ្នា។«បើយើងមានជំហររួមគ្នា ក្នុងក្របខណ្ឌប្រទេសទាំង៥នេះ យើងអាចយកបញ្ហានេះ ទៅជជែកគ្នាទៀតនៅអាស៊ាន ដើម្បីបង្កើតឡើងនៅស្ថានភាពតំណ តភ្ជាប់គ្នា ដែលអាចធ្វើការនៅប្រទេសមួយ ប៉ុន្តែមកចូលនិវត្តនៅក្នុងប្រទេសមួយ ប៉ុន្តែទទួលបាននូវប្រាក់កម្រៃ»។ នេះជាការបញ្ជាក់របស់សម្តេច ហ៊ុន សែន ដែលបានបន្ថែមថា កម្ពុជាកំពុងរៀបចំឯកសារបែបបទ ពិភាក្សាទ្វេរភាគីជាមួយថៃ លើបញ្ហាសោធនិវត្តពលករនេះហើយ។

បើតាមប្រមុខរដ្ឋាភិបាល ការយកចិត្តទុកដាក់ចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ ជារឿងសំខាន់បំផុតមួយ ដើម្បីឲ្យពលករខ្មែរនៅក្រៅប្រទេស ឬពលករបរទេសនៅកម្ពុជា ទទួលបានការគាំពារនិងអត្ថប្រយោជន៍ផ្សេងៗពីសង្គមដូចៗគ្នា។

ការចល័តពលករ ត្រូវបានប្រមុខរដ្ឋាភិបាលអះអាងថា មិនមែនជារឿងថ្មីនោះឡើយ ពោលគឺមានការពិភាក្សាគ្នាជាយូរណាស់មកហើយ ជាពិសេសក្នុងក្របខណ្ឌអាស៊ាន នៅ Cebu និង ម៉ានីល ជាដើម។ នៅតំបន់អាស៊ាន ព្រុយណេ សិង្ហបុរី និងម៉ាឡេស៊ី ជាប្រទេសដែលខ្វះកម្លាំងពលករ ហើយសម្តេច ហ៊ុន សែន បានកត់សម្គាល់ថា ក្នុងក្របខណ្ឌប្រទេស CLMTV ( កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) ថៃជាប្រទេសដែលទទួលពលករពីកម្ពុជាច្រើនជាងគេ ប៉ុន្តែថៃក៏បញ្ជូនពលកររបស់ខ្លួនទៅក្រៅប្រទេសផងដែរ៕

## នាយករដ្ឋមន្ត្រីកម្ពុជា ពន្យល់ពីការបញ្ជូនពលករខ្មែរទៅក្រៅប្រទេស

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 18 September, 2019

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានច្រានចោលចំពោះការរិះគន់របស់សកម្មគណបក្សប្រឆាំងដែលថា កម្ពុជាមិនមានលទ្ធភាពបង្កើតការងារក្នុងស្រុក ទើបបញ្ជូនពលករចំណាកស្រុកទៅប្រទេសដទៃ។ តាមរយៈការពលករចំណាកស្រុកនោះហើយ ដែលពលករអាចរកចំណូលជាង២ពាន់ដុល្លារអាមេរិក ផ្ញើមកក្នុងស្រុក និងបានធ្វើឲ្យកំរិតជីវភាពពលរដ្ឋល្អប្រសើរ។ ការបញ្ជូនពលករកម្ពុជា ទៅក្រៅប្រទេស ដូចជាប្រទេសថៃ កូរ៉េខាងត្បូង និងបណ្តាប្រទេសដទៃទៀត បានផ្តល់ចំណូលជាច្រើនសម្រាប់លើកកំពស់ជីវភាពពលរដ្ឋនៅក្នុងស្រុក តាមរយៈការផ្ញើប្រាក់ពីក្រៅប្រទេសមកក្រុមគ្រួសារ។ ក្នុងមួយឆ្នាំៗ ពលករចំណាកស្រុកបានផ្ញើរប្រាក់មកក្រុមគ្រួសារក្នុងស្រុក មិនតិចជាង២ពាន់ពាររយលានដុល្លារអាមេរិកនោះទេ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានច្រាលចោលការរិះគន់ថា រាជរដ្ឋាភិបាលមិនមានលទ្ធភាពដើម្បីបង្កើត ការងារនៅក្នុងស្រុកបាន ទើបបញ្ជូនពលករនៅក្រៅប្រទេសធ្វើជាអ្នកបំរើគេ។ យ៉ាងណាសម្តេចតេជោបានអះអាងថា ទីផ្សារការងារនៅកម្ពុជាបច្ចុប្បន្នកាន់តែមានច្រើន ឯអត្រាការងារធ្វើរបស់ប្រជាពលរដ្ឋខ្មែរជាង

៩៩,៣% និងអត្រាអត់ការងារធ្វើមានតែ០,៧%ប៉ុណ្ណោះ នៃកម្លាំងពលកម្មសរុបជិត១០លាននាក់។ នៅកម្ពុជាកាលដែលរាជរដ្ឋាភិបាល ស្វែងរកឱកាសការងារធ្វើ ដូចជានៅកូរ៉េខាងត្បូង ថា បញ្ជូនទៅពលរដ្ឋទៅធ្វើខ្ញុំគេ។ យើងដាក់ជាសំណួរ ថា តើបើមិនធ្វើការទេ តើយើងបានលុយពីណាអាចរស់បាន។ ប៉ុន្តែពួកគេបាន ប្រែក្លាយបញ្ហា ការធ្វើចំណាកស្រុកទៅរកការងារធ្វើក្រៅប្រទេស វាទៅជាយើងមិនអាចដោះស្រាយបញ្ហាការងារឲ្យពលរដ្ឋខ្លួនឯងបាន ឲ្យពលរដ្ឋខ្លួនឯងធ្វើចំណាកស្រុកទៅរកការងារធ្វើក្រៅប្រទេស។ ការរកការងារធ្វើក្រៅប្រទេស ជាក្របខណ្ឌនៃកិច្ចខិតខំរបស់អាស៊ាន ដូចជាហ្វីលីពីន ដែលមានពលករច្រើនជាងគេនៅទៅខាងក្រៅ។

គួរកត់សំគាល់ដែរថា កាលពី៤ រឺ៥ឆ្នាំមុន លោកស្រី អង់សាន ស៊ូជី ពេលជួបពលកររបស់ខ្លួននៅប្រទេសថៃបានធ្វើការអំពាវនាវឲ្យពលករមីយ៉ាន់ម៉ា វិលត្រលប់ទៅធ្វើការងារនៅប្រទេសរបស់ខ្លួនវិញ គ្រាដែលរដ្ឋបាលលោកស្រីនឹងបង្កើតការងារធ្វើជាច្រើនកន្លែងសម្រាប់ទទួលពលករចំណាកស្រុក។ ប៉ុន្តែការអំពាវនាវនោះបានបរាជ័យ មិនត្រឹមតែកាត់បន្ថយចំណាកស្រុកទៅថៃ ទេ ។

បើតាមសម្តេច កម្ពុជាកំពុងយកចិត្តទុកដាក់ចំពោះសិទ្ធិពលករក្នុងស្រុក និងក្រៅស្រុកកាន់ប្រសើរឡើង។ ក្រសួងការងារ បានដាក់ឲ្យដំណើរការប្រព័ន្ធ សុវត្ថិភាពសង្គម តាមរយៈការពិនិត្យ ព្យាបាលសម្រាប់ពលករពីក្រៅប្រទេស ដោយឥតបង់ប្រាក់ថែមទៀតផង។ កម្ពុជា បានដាក់ឱ្យដំណើរការនូវរបបហានិភ័យការងារ ថែទាំសុខភាព និងសោធននិវត្តន៍ ដែលគ្របដណ្តប់លើសហគ្រាស គ្រឹះស្ថាន ផ្នែកផលិតកម្ម ផ្នែកសេវាកម្ម និងផ្នែកសាធារណៈ ស្ទើរតែ១០០% នៃកម្មករនិយោជិត និងមន្ត្រីសាធារណៈ។ ទន្ទឹមនឹងនេះ កម្ពុជាកំពុងរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមនៅឆ្នាំ២០១៩នេះ ដើម្បីពង្រីកវិសាលភាពបន្ថែមដល់ប្រជាពលរដ្ឋដែលប្រកបរបរស្វ័យនិយោជន៍ និងពលករទេសន្តប្រវេសន៍ផងដែរ៕

## ក្រសួងការងារកម្ពុជា ប្រកាសលទ្ធផលសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ CLMTV នៅខេត្តសៀមរាប

http://www.freshnewsasia.com/ 2019-09-17

**(សៀមរាប)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីប្រកាសព័ត៌មានមួយ បង្ហាញលទ្ធផលនៃការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ សម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) ក្រោមប្រធានបទ «ការឆ្ពោះទៅកាន់កិច្ចគាំពារពលករទេសន្តប្រវេសន៍នៅក្នុងប្រទេស CLMTV៖ កិច្ចសហប្រតិបត្តិការវិស័យរបបសន្តិសុខសង្គម»។ សន្និសីទថ្នាក់រដ្ឋមន្ត្រីការងារនេះ បានប្រព្រឹត្តទៅនាព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នៅសណ្ឋាគារអប្សរាផាឡេស ខេត្តសៀមរាប ដែលត្រូវបានបើកជាផ្លូវការក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា។

លោក អិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ បានដឹកនាំកិច្ចពិភាក្សានៃអង្គសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣នេះ ដែលត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការលើវិស័យការងារ និងការឯកភាពគ្នាលើយន្តការរួមមួយ ឆ្ពោះទៅកាន់ការរៀបចំក្របខណ្ឌរួមស្តីពី ចល័តភាពរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តប្រវេសន៍នៅក្នុងប្រទេស CLMTV។

**អង្គសន្និសីទសម្រេចបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖**

* បានឯកភាពគ្នាលើ «ផែនទីបង្ហាញផ្លូវទីក្រុងសៀមរាប ដើម្បីឆ្ពោះទៅកាន់ការចេញសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីការងារ ស្តីពីចល័តភាពរបបសន្តិសុខសង្គម សម្រាប់ពលករទេសន្តប្រវេសន៍នៃប្រទេស CLMTV ក្របខ័ណ្ឌរួម

មួយដើម្បីជានាថា ពលករទេសន្តរប្រវេសន៍ នឹងទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម នៅពេលធ្វើមាតុភូមិនិវត្តន៍ ឬផ្លាស់ទីកន្លែងធ្វើការនៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

* បានចេញសេចក្តីថ្លែងការណ៍រួមស្តីពី លទ្ធផលនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣នេះ ដោយសង្កត់ធ្ងន់លើការពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រសើរឡើង ដើម្បីឈានទៅសម្រេចឱ្យបាននូវកិច្ចគាំពារពលករទេសន្តរប្រវេសន៍ក្នុងប្រទេស CLMTV តាមរយៈការដាក់ចេញនូវយន្តការចល័តភាពរបបសន្តិសុខសង្គម។

លទ្ធផលខាងលើនេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌតំបន់ ដើម្បីការពារ និងលើកកម្ពស់សុខុមាលភាព និងផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ ដែលកំពុងធ្វើការនៅបរទេសបន្ថែមលើកិច្ចគាំពារសង្គម និងការលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិតនៅក្នុងប្រទេស ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ (២០១៥-២០២៥) និងគោលនយោបាយស្តីពី ទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា (២០១៩-២០២៣)៕

## កម្ពុជា-វៀតណាម មានបំណងផ្លាស់ប្តូរកម្លាំងពលកម្មទៅវិញទៅមក លើវិស័យដែលខ្វះកម្លាំងពលកម្មពិសេសនៅតំបន់ព្រំដែន

http://www.freshnewsasia.com/ 2019-09-17

**(សៀមរាប)៖** បន្ទាប់ពីបញ្ចប់សន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ នៃកិច្ចសហប្រតិបត្តិការលើវិស័យការងារសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម (CLMTV) នាថ្ងៃទី១៧ ខែកញ្ញានេះ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជួបពិភាក្សាការងារជាមួយលោកស្រី Nguyen Thi Ha អនុរដ្ឋមន្ត្រីក្រសួងការងារ ជនពិការ និងសង្គមកិច្ច នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

ក្នុងជំនួបនោះ ភាគីទាំងពីរបានលើកឡើងពីការចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យការងារ កាលពីឆ្នាំ២០១៧ និងបន្តពិភាក្សាគ្នា ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយនឹងចាត់មន្ត្រីបច្ចេកទេស ធ្វើការប្រជុំពិភាក្សាកំណត់នីតិវិធី ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នានេះ និងបង្ហាញនូវគោលបំណង ក្នុងការផ្លាស់ប្តូរកម្លាំងពលកម្មទៅវិញទៅមក លើវិស័យនានាដែលមានកង្វះខាតកម្លាំងពលកម្ម ជាពិសេសនៅតំបន់ព្រំដែន។

ភាគីជំនួបបានប្តេជ្ញាចិត្ត សហការគ្នាក្នុងការផ្លាស់ប្តូរព័ត៌មាន និងទិន្នន័យក៏ដូចជាការពារ និងលើកកម្ពស់សិទ្ធិពលករនៃប្រទេសទាំងពីរ ព្រមទាំងកិច្ចសហប្រតិបត្តិការលើវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈទៀតផង។ ភាគីទាំងពីរបានរំលឹកឡើងវិញ អំពីចំណងមិត្តភាពជាប្រវត្តិសាស្ត្ររវាងកម្ពុជា វៀតណាម និងឡាវ ក្នុងការសាមគ្គីតស៊ូដើម្បីសន្តិភាព ព្រមទាំងបានសម្តែងការពេញចិត្តលទ្ធផល ចំពោះកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ការងារលើកទី៥ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ នៃប្រទេស CLMTV និងបានប្តេជ្ញាចិត្តក្នុងការខិតខំអនុវត្តប្រកបដោយប្រសិទ្ធភាព៕

## មេការហោងម៉ាស្សាបង្កប់សេវាផ្លូវភេទ ៣ នាក់ កំពុងត្រូវបានសួរចម្លើយ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 18 September 2019 | 08:56 ICT

**ភ្នំពេញៈ** សមត្ថកិច្ចនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញកំពុងបន្តការសាកសួរជនសង្ស័យចំនួន ៣ នាក់ ជាមេការហោងម៉ាស្សាអ័រគីដេ ដែលបង្កប់សេវាផ្លូវភេទ ក្រោយប្រតិបត្តិការបង្ក្រាបឃាត់ខ្លួនបានជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតសរុប ៣៧ នាក់ កាលពីយប់ថ្ងៃទី ១៦ កញ្ញា នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

លោក កែវ ជា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃម្សិលមិញថា កម្លាំងសមត្ថកិច្ចបានចុះប្រតិបត្តិការស្រាវជ្រាវ សហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌសែនសុខឃាត់ខ្លួនមនុស្សចំនួន ៣៧ នាក់ ពាក់ព័ន្ធករណីប្រព្រឹត្តអំពើសញ្ជារកម្ម។ ក្នុងនោះមានអ្នកគ្រប់គ្រងជាមេការចំនួន ៣ នាក់ បុគ្គលិកធម្មតា ៤ នាក់ សន្តិសុខម្នាក់ នារីម៉ាស្សា ២៣ នាក់ (សង្ស័យជាអនីតិជនចំនួន ២ នាក់) និងភ្ញៀវ ៦ នាក់។ លោក កែវ ជា ថ្លែងថា៖ «យើងកំពុងបន្តនីតិវិធីសាកសួរជនសង្ស័យជាមេការទាំង ៣ ករណីនេះយើងមិនទាន់បញ្ចប់ទេ។ យើងមិនទាន់អាចប្រាប់លម្អិតចំពោះរឿងនេះបានទេព្រោះកំពុងបន្តធ្វើការនៅឡើយ»។

របាយការណ៍ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានឲ្យដឹងថា ហាងម៉ាស្សានេះបើកដំណើរការ ២៤ ម៉ោង ហើយមាននារីបម្រើសេវាម៉ាស្សាចំនួន ២៣ នាក់ ជាជនជាតិខ្មែរក្នុងនោះមាន ២ នាក់ ត្រូវបានសង្ស័យថា ជាអនីតិជនដែលមានអាយុចន្លោះពី ១៦ ឆ្នាំ ទៅ ១៧ ឆ្នាំ។ របាយការណ៍បង្ហាញថា ទីតាំងហាងម៉ាស្សានេះមានបន្ទប់ម៉ាស្សាចំនួន ២៧ បន្ទប់ តម្លៃសេវារួមភេទដោយប្រើដៃមានចាប់ពី ៣០ ដុល្លារ ឡើងទៅ និងរួមភេទចាប់ពី ៥០ ដុល្លារឡើងទៅ។ លុយទទួលបានពីភ្ញៀវនោះមួយចំនួនត្រូវបានចែកទៅឲ្យមេការភេទប្រុសទាំង ៣ នាក់ ដែលជាជនជាតិខ្មែរ។

លោក កែវ ជា បញ្ជាក់ថាមុនឈានដល់ការឃាត់ខ្លួនជនសង្ស័យខាងលើ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានធ្វើការស្រាវជ្រាវ ស៊ើបអង្កេតជាច្រើនថ្ងៃរហូតឈានដល់ការចុះប្រតិបត្តិការឃាត់ខ្លួនតែម្តង ដោយដកហូតវត្ថុតាង ស្រោមអនាម័យមួយចំនួននាំមកការិយាល័យជំនាញ។ ក្រោយបញ្ចប់ការសួរចម្លើយចំពោះអ្នកដែលពុំពាក់ព័ន្ធ សមត្ថកិច្ចអនុញ្ញាតឲ្យត្រឡប់ទៅគេហដ្ឋានវិញ។ បច្ចុប្បន្នសមត្ថកិច្ចបានឃាត់ខ្លួនបុរសមេការទាំង ៣ នាក់ ជាបណ្តោះអាសន្ន ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី។ ចំណែកនារីបម្រើសេវាម៉ាស្សាត្រូវបានសមត្ថកិច្ចប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញចាត់ការតាមនីតិវិធី។

លោក ជាវ ផល្លី អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្លែងថា ករណីបង្ក្រាបកន្លែងម៉ាស្សាផ្តកសេវាផ្លូវភេទនេះ សមត្ថកិច្ចនគរបាលរាជធានីភ្នំពេញជាអ្នកចុះប្រតិបត្តិការបង្ក្រាប និងកំពុងបន្តនីតិវិធីលើករណីនេះ។ លោក ផល្លី បានថ្លែងថា៖ «ការរាយការណ៍បឋមមកខ្ញុំនេះ មិនទាន់មានរបាយការណ៍ទេ គ្រាន់តែរាយការណ៍ថា មានការចុះបង្ក្រាបហាងម៉ាស្សាផ្តកសេវាផ្លូវភេទប៉ុណ្ណោះ។ រឿងនេះកំពុងតែស្ថិតនៅក្នុងនីតិវិធីរបស់សមត្ថកិច្ចនៃស្នងការដ្ឋានរាជធានីភ្នំពេញ»៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 17-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៣នាក់ នាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣ នាក់នេះ មានស្រុកកំណើតនៅ ខេត្តពោធិ៍សាត់ ០១នាក់, ខេត្តកំពង់ធំ ០១នាក់ និងខេត្តព្រៃវែង ០១នាក់៕

# ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៩

## កម្ពុជាបារម្ភអំពីការរីករាលដាលការរំលោភផ្លូវភេទលើកុមារ

https://www.rfa.org/khmer/news/ ដោយ សេក បណ្ឌិត 2019-09-18

មន្ត្រីជាន់ខ្ពស់ប្រឆាំងការជួញដូរមនុស្សឱ្យដឹងថា កំណើននៃការប្រើប្រាស់ អ៊ីនធឺណិត និងទូរស័ព្ទ បណ្តាលឱ្យកុមារ ត្រូវបានជនល្មើសកេងចំណេញ រំលោភបំពានផ្លូវភេទ និងរំលោភសេពសន្ថវៈ។ បញ្ហានេះហើយ ទើបជំរុញឱ្យរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលបានចាប់ដៃគ្នាដើម្បីប្រយុទ្ធនឹងការរំលោភបំពានផ្លូវភេទនេះ។ អនុប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ឱ្យដឹងថា ក្រសួងមហាផ្ទៃ កំពុងចាត់វិធានការទៅលើបទឧក្រិដ្ឋបច្ចេកវិទ្យានេះ ព្រោះវាមានការផ្សព្វផ្សាយ អូសទាញធ្វើឱ្យមនុស្ស ធ្លាក់ទៅក្នុងការចាញ់បោកការ

រំលោភផ្លូវភេទ។ អ្នកស្រីបន្ថែមទៀតថា កុមារខ្មែរកំពុងទទួលរងឥទ្ធិពល នៃការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ដោយសារតែអាជ្ញាធរប្រទេសជិតខាងកម្ពុជាដូចជាប្រទេសថៃ កំពុងតែបង្ក្រាបករណីនេះទើបបណ្ដាលឱ្យជនល្មើសមករកទីផ្សារកម្ពុជាវិញ។

អ្នកស្រីបន្តទៀតថា ដើម្បីបទស្កាត់បញ្ហានេះ កាលពីថ្ងៃទី១៣ សីហា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស បានចុះ អនុស្សរណៈជាមួយអង្គការដៃគូចំនួន៦ ដែលមានសមាជិករហូតដល់ជិត ១០០ដៃគូ ដើម្បីធ្វើការការពារ និងទប់ស្កាត់ការរីករាលដាលនៃការរំលោភផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនេះ៖ «អ៊ីចឹងរឿងផ្លូវភេទនេះ យើងកំពុងតែបានជជែកគ្នាខ្លាំងណាស់ ព្រោះថា យើងចង់រកឱ្យឃើញច្បាស់ថា ឥទ្ធិពលអីខ្លះដែលវាធ្វើឱ្យមានការប្រែប្រួល នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាហ្នឹង ហើយបើតាមយើងដឹង វាមិនមែនតែនៅកម្ពុជាទេ រឿងហ្នឹងនោះ ហើយអ្នកដែលមកជួញដូរ ឬអ្នកដែលបំពានហ្នឹង មានមួយចំនួនក៏ជាជនបរទេសដែរ ហើយយើងក៏បានបង្ក្រាប យើងចាប់កាត់ទោស យើងបញ្ជូនត្រឡប់ជាបន្តបន្ទាប់»។ អ្នកស្រី ជូ ប៊ុនអេង និយាយថា ជនជាតិចិនមួយចំនួន ក៏មានការពាក់ព័ន្ធទៅនឹងរឿងការរំលោភផ្លូវភេទលើកុមារកម្ពុជា។ អាជ្ញាធរកម្ពុជា កំពុងធ្វើការតាមដានករណីនេះ៖ «ខ្ញុំគិតថា បច្ចេកវិទ្យាហ្នឹង ខ្មែរដឹងក្រោយគេទេ ហើយរឿងដែលសំខាន់ វាចូលតាមគេហៅថា តាមរយៈភ្ញៀវទេសចរ ដែលយើងមិនចាត់ទុកថា ភ្ញៀវទេសចរទាំងអស់ជាមនុស្សអាក្រក់ទេ ប៉ុន្តែ វាបានដោយរោយមក ហើយយើងបានដឹងហើយថា អ្នកដែលជាជនជាតិខាងយើងហ្នឹង គឺមានប្រទេសថៃ មានសេវាកម្មហ្នឹង ប៉ុន្តែឥឡូវគាត់រឹតបន្តឹងជាងមុន អ៊ីចឹងវាបែកខ្ញែក ហើយយើងទទួលឥទ្ធិពលហ្នឹង»។

អ្នកនាំពាក្យសមាគមអាដហុក (Adhoc) លោក ស៊ឹង សែនករុណា មានប្រសាសន៍ថា ដើម្បីបំបាត់ឧក្រិដ្ឋកម្មនេះ អាជ្ញាធរខ្មែរត្រូវមានសមត្ថភាពគ្រប់គ្រាន់ ព្រោះជនប្រព្រឹត្តបទល្មើសតាមប្រព័ន្ធអ៊ីនធឺណិតនេះ មានជំនាញនិងចំណេះបច្ចេកវិទ្យាកម្រិតខ្ពស់៖ «យើងសង្ឃឹមថា បើសិនជាក្រុមការងារនេះ ពិតជាបង្កើតឡើង ហើយមានសមត្ថភាពគ្រប់គ្រាន់មែន អាចធ្វើការទប់ស្កាត់ និងចាត់វិធានការទៅលើជនប្រព្រឹត្តទាំងអស់ហ្នឹងបានហើយ ប៉ុន្តែផ្ទុយមកវិញ បើមិនមានសមត្ថភាព ឬចំណេះដឹងជំនាញគ្រប់គ្រាន់ទេ ខ្ញុំគិតថាពិបាកក្នុងការចាត់វិធានការណាស់ ព្រោះបច្ចេកវិទ្យាទាំងនេះ ទាមទារអ្នកមានសមត្ថភាពខ្ពស់»។

របាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក្រសួងមហាផ្ទៃកម្ពុជាបានឱ្យដឹងថា ក្នុងរយៈពេល ៦ ខែដើមឆ្នាំ២០១៩ នេះប៉ូលិសបានជួយសង្គ្រោះជនរងគ្រោះ ២៦៣ នាក់ពីការរំលោភផ្លូវភេទ ដែលមានការកើនឡើងជិត ១៥០ ភាគរយបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ របាយការណ៍បានបញ្ជាក់ថា ក្នុងចំណោមករណីទាំងនោះមានកុមារចំនួន ៧០នាក់ ដែលមានអាយុក្រោម ១៥ឆ្នាំ មានជនរងគ្រោះចំនួន ៣១នាក់ ដែលមានអាយុចន្លោះពី ១៥ ទៅ ១៨ ឆ្នាំចំនួន ៣១ នាក់។ កាលពីឆ្នាំ២០១៨ ប៉ូលិសបានបង្ក្រាបបទល្មើសជួញដូរមនុស្សចំនួន ១៣៤ករណី និងការធ្វើអាជីវកម្មផ្លូវភេទ ១៥៩ករណី ព្រមទាំងបានឃាត់ខ្លួនចំនួន ២០៣នាក់៕

## កម្ពុជា-ថៃ ចរចាលើកិច្ចព្រមព្រៀងផ្ទេរអត្ថប្រយោជន៍ដល់ពលករចំណាកស្រុក

https://www.postkhmer.com/ វី សុចាន់ | Publication date 18 September 2019 | 10:13 ICT

**សៀមរាប:** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងពីម្សិលមិញថា កម្ពុជាកំពុងចរចាជាមួយភាគីថៃលើកិច្ចព្រមព្រៀងក្នុងការផ្ទេរអត្ថប្រយោជន៍គាំពារសង្គមដល់ពលករចំណាកស្រុកដែលធ្វើការនៅប្រទេស ថៃ ជាប្រយោជន៍សម្រាប់ពួកគេនៅពេលបញ្ចប់ពីការងារ ហើយត្រឡប់មកបម្រើការនៅប្រទេសកម្ពុជាវិញ។ ការថ្លែងបែបនេះរបស់លោក ហ៊ុន សែន ធ្វើឡើងកាលពីថ្ងៃអង្គារនៅខេត្តសៀមរាបក្នុងពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី ៣ ស្របពេលជាមួយនឹងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ការងារលើកទី ៥ នៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាមផងដែរ (CLMTV)។ លោក ហ៊ុន សែន ថ្លែងថា៖ «ការផ្ទេរអត្ថប្រយោជន៍ ផ្ទេរធនធានមកដើម្បីចិញ្ចឹមនោះ វាសុទ្ធតែជាបញ្ហា។ បើយើងធ្វើដូចនេះបានពាក្យដែលថា ជោគវាសនារួមអាស៊ានមួយ ជាសហគមន៍ដែលមានជោគវាសនារួម គឺ

នឹងទទួលបានផលប្រយោជន៍ដល់ប្រជាជន។ ឧទាហរណ៍ថា គ្នាធ្វើការនៅប្រទេសថៃ ប៉ុន្តែត្រឡប់មកប្រទេសវិញ បែរជាអត់បានទទួលអត្ថប្រយោជន៍អីបន្ត»។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងបន្តថាបើប្រទេសទាំង ៥ មានជំហររួមគ្នា ប្រទេសទាំង ៥ នេះអាចយកបញ្ហាទៅជជែកក្នុងអាស៊ានបន្តទៀតដើម្បីបង្កើតឱ្យមានស្ថានភាពបន្តគឺថាពលករចំណាកស្រុកអាចធ្វើការនៅប្រទេសមួយ ប៉ុន្តែអាចចូលនិវត្តន៍នៅប្រទេសមួយហើយអាចទទួលបាននូវប្រាក់កម្រៃទៀត។ នេះជាអ្វីដែលលោកហៅថាជាការធានា។ លោក ហ៊ុន សែន បន្ថែមថា៖ «យើងត្រូវរកវិធីដើម្បីធ្វើសមាហរណកម្ម និងបន្តគេហៅថា ចល័តភាពនៃរបបសន្តិសុខសង្គមដែលនៅក្នុងប្រទេសនោះទទួលបាន ប៉ុន្តែមកឯណេះតគ្នាយ៉ាងម៉េច ដើម្បីពួកគេចូលនិវត្តន៍។ ពួកគេអាចទទួលបាននូវរបៀវត្សរ៍។ ប៉ុន្តែនេះគ្រាន់តែអ្នកធ្វើការក្នុងស្រុក ប៉ុន្តែយើងត្រូវគិតដល់អ្នកដែលកំពុងធ្វើការនៅក្រៅស្រុកផងដែរ»។ ប្រទេស CLMTV បានឯកភាពគ្នាលើសេចក្តីព្រាងផែនទីបង្ហាញផ្លូវសៀមរាបដើម្បីឆ្ពោះទៅកាន់សេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីការងារស្តីពីចល័តភាពនៃរបបសន្តិសុខសង្គមសម្រាប់ពលករទេសន្តរប្រវេសន៍ក្នុងប្រទេស CLMTV។ នេះបើតាមហ្វេសប៊ុកក្រសួងការងារកាលពីថ្ងៃចន្ទ។

លោក យុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅថា (Central) ប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃអង្គារថា ក្របខ័ណ្ឌរបស់ប្រទេសទាំង ៥ នេះប្រហែលមានការពិបាក ពីព្រោះក្របខ័ណ្ឌ និងរបបគាំពារសង្គមនៃប្រទេសនីមួយៗនេះមានភាពផ្សេងពីគ្នា។ ប៉ុន្តែរឿងដែលសំខាន់ រាជរដ្ឋាភិបាលកម្ពុជាត្រូវគិតពិចារណាទៅលើយន្តការរវាងប្រទេសកម្ពុជា ដែលបញ្ជូនពលករទៅធ្វើការនៅប្រទេសដែលទទួល។ លោក យុន ថារ៉ូ ថ្លែងថា៖ «អ៊ីចឹង យើងត្រូវសិក្សាឡើងវិញនូវប្រទេសណាដែលជាប្រទេសអាទិភាព ហើយប្រទេសដែលមានប្រព័ន្ធគាំពារសង្គម។ ឥឡូវយើងឧទាហរណ៍នៅប្រទេសថៃ រឿងដែលសំខាន់ថា តើការចុះបញ្ជីពលករខ្មែរដែលស្របច្បាប់ ដែលគាត់ត្រូវតែមានកាតព្វកិច្ចនៅក្នុងការបង់បញ្ចូលទៅក្នុងប្រព័ន្ធគាំពារសង្គមនៅប្រទេសថៃហ្នឹង វាមានការចុះបញ្ជីហ្នឹងត្រឹមត្រូវ ហើយនិងការគ្រប់គ្រងតាមប្រព័ន្ធត្រឹមត្រូវរបស់ប្រទេសថៃ ហើយប្រទេសកម្ពុជាហ្នឹងយ៉ាងម៉េច?»។ លោក ថារ៉ូ បញ្ជាក់ថា វាចៀសមិនផុតនោះទេដែលត្រូវតែមានកិច្ចព្រមព្រៀង ឬក្របខ័ណ្ឌច្បាប់រវាងប្រទេសនីមួយៗដើម្បីធានាដល់ការផ្ទេរ ការវេរ ឬក៏ការធ្វើសមាហរណកម្មពលករដែលចប់ពីការងារនៅប្រទេសដែលទទួល។ អំឡុងពេលដែលពលករធ្វើការងារគឺត្រូវមានការកត់ទុកជាប្រព័ន្ធឱ្យបានត្រឹមត្រូវ។ នៅពេលដែលពលករចប់ពីបម្រើការងារនៅប្រទេសដែលទទួល ពួកគាត់ត្រូវតែត្រូវបានធានាថា ទទួលបានអត្ថប្រយោជន៍អ្វីខ្លះ នៅពេលត្រឡប់មកប្រទេសកំណើតវិញ។

ក្នុងជំនួបជាមួយលោក យូ ធាន ស្វេ (U Thein Swe) រដ្ឋមន្ត្រីការងារមីយ៉ាន់ម៉ា លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ បានថ្លែងថា ពលករមីយ៉ាន់ម៉ាប្រមាណជាង ១ ៣០០ នាក់ទទួលបានបណ្ណការងារជនបរទេសនៅកម្ពុជា ហើយមានប្រមាណ ១៨០ នាក់ជាសមាជិក បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.)។ ចំនួននេះរំពឹងថានឹងកើនឡើងបន្តទៀត។ ពលករមីយ៉ាន់ម៉ាដែលកំពុងធ្វើការនៅកម្ពុជាទទួលបានការការពារសិទ្ធិ និងអត្ថប្រយោជន៍ដូចកម្មករនិយោជិតកម្ពុជាដែរ។ នេះបើតាមហ្វេសប៊ុកក្រសួងការងារកាលពីថ្ងៃចន្ទ។

យោងតាមហ្វេសប៊ុកក្រសួងការងារលោក ចាទុមង្គល សូណាគុល (Chatumongol Sonakul) រដ្ឋមន្ត្រីការងារថៃថ្លែងក្នុងជំនួបជាមួយ លោក អ៊ិត សំហេង ថាភាគីថៃនឹងពង្រឹងកិច្ចសហប្រតិបត្តិការលើពលករកម្ពុជាដែលនឹងផុតសុពលភាពធ្វើការងារក្នុងប្រទេសថៃ ដោយរៀបចំយន្តការបន្ថែមទៀត មិនចាំបាច់តម្រូវឱ្យពលករធ្វើការចំណាយច្រើនត្រឡប់មកប្រទេសរបស់ខ្លួន។

ហ្វេសប៊ុកដដែលបញ្ជាក់ថា ក្នុងជំនួបរវាងលោក អ៊ិត សំហេង និងលោក ខាំផែង សាយស៊ុមផេង (Khampheng Saysompheng) រដ្ឋមន្ត្រីការងារឡាវ ភាគីទាំង ២ ប្តេជ្ញាអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារកាលពីថ្ងៃទី ១២ ខែកញ្ញាក៏ដូចជាកិច្ចសហប្រតិបត្តិការផ្សេងទៀតឱ្យមានប្រសិទ្ធភាព៕

## បញ្ជូនខ្លួនមេការហាងម៉ាស្សា "អ័រគីដេ" ៣នាក់ ឡើងតុលាការ នៅភ្នំពេញ

http://www.arey-news.com/ (ថ្ងៃទី 19 September 2019 ម៉ោង 1:53 pm)

**ភ្នំពេញ:** នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ នេះ កម្លាំងនគរបាលការិយាល័យ ប្រឆាំង ការជួញដូរមនុស្ស និងការពារអនីតិជន បានកសាងសំណុំរឿងបញ្ជូន ខ្លួនជនសង្ស័យ ប្រុសចំនួន៣នាក់ ពាក់ព័ន្ធករណីប្រព្រឹត្តអំពើសញ្ញារកម្ម យោងតាមមាត្រា២៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ជនសង្ស័យទាំង៣ ទី១-ឈ្មោះ ធៀង ចាន់ថេន ភេទ ប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ជាអ្នកគ្រប់គ្រង។ ទី២-ឈ្មោះ វ៉ន សារុំ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ ជាអ្នកគ្រប់គ្រង។ ទី៣-ឈ្មោះ សឿង ថៃន ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ជាអ្នកគ្រប់គ្រង។ គួរំឭកផងដែរថា កាលពីវេលាម៉ោង៩និង៣០នាទីយប់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ កម្លាំងនគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចុះប្រតិបត្តិការស្រាវជ្រាវសហការជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌសែនសុខ បានឃាត់ខ្លួនមនុស្សចំនួន៣៧នាក់ ពាក់ព័ន្ធករណីប្រព្រឹត្តិអំពើសញ្ជារកម្ម ក្នុងនោះមាន ៖ អ្នកគ្រប់គ្រង៣នាក់, បុគ្គលិកធម្មតា៤នាក់, សន្តិសុខ១នាក់, នារីម៉ាស្សា២៣នាក់ (សង្ស័យជាអនីតិជនចំនួន២នាក់) និងភ្ញៀវ ០៦នាក់។

ក្នុងប្រតិបត្តិការនេះ ធ្វើឡើងនៅចំណុចហាងម៉ាស្សា យីហោ អ័រគីដេ ផ្ទះលេខC១៤ ផ្លូវលេខ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ប្រតិបត្តិការនេះដែរ ដោយមានការចង្អុលបង្ហាញពីឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ សម្របសម្រួលពីលោកស្រី ស៊ី វណ្ណនី ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ និងដឹកនាំផ្ទាល់ដោយលោកឧត្តមសេនីយ៍ទោ ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជាធានីភ្នំពេញ។

យោងតាមនគរបាលជំនាញ បានអោយដឹងថា ហាងម៉ាស្សានេះ បើកដំណើរការ ២៤ម៉ោង ហើយមាននារីបម្រើសេវាម៉ាស្សា ចំនួន២៣នាក់ ជាជនជាតិខ្មែរ ក្នុងនោះមាន២នាក់ ត្រូវបានសង្ស័យថា ជាអនីតិជនដែលមានអាយុចន្លោះពី១៦ឆ្នាំទៅ១៧ ឆ្នាំ។

សូមបញ្ជាក់ផងដែរថា ទីតាំងហាងម៉ាស្សាមានបន្ទប់សម្រាប់ម៉ាស្សា និងរួមភេទសរុបចំនួន២៧បន្ទប់។ ចំពោះតម្លៃសេវាមានចាប់ពី ៣០ដុល្លារទៅ៥០ដុល្លារឡើង។ មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យ កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការស្រាវជ្រាវស៊ើបអង្កេតជាច្រើនថ្ងៃ រហូតដល់ស៊ីជម្រៅ បានចុះប្រតិបត្តិការទៅឃាត់ខ្លួនមេការគ្រប់គ្រងចំនួន ៣នាក់ និងនារីម៉ាស្សាចំនួន២៣នាក់ ភ្លាមៗតែម្តង និងដកហូតវត្ថុតាងស្រោមអនាម័យមួយចំនួន នាំមកការិយាល័យជំនាញ ដើម្បីធ្វើការសាកសួរ។

ក្រោយបញ្ចប់ការសាកសួរចំពោះអ្នកដែលពុំពាក់ព័ន្ធ នគរបាលជំនាញអនុញ្ញាត អោយត្រឡប់ទៅវិញជាធម្មតា។ ចំណែកនារីបម្រើម៉ាស្សា ត្រូវបាននគរបាលប្រគល់ជូន មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕

## ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៩

## បញ្ឈប់ពិធីរៀបអាពាហ៍ពិពាហ៍ រវាងជនជាតិចិនម្នាក់ មករៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីខ្មែរ ដោយខុសច្បាប់ នៅព្រះវិហារ

https://www.facebook.com/VD7news/ September 21 at 7:11 PM

ព្រះវិហារ ៖ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ សមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ខេត្ត ព្រះវិហារ បានចុះត្រួតពិនិត្យនិងឃាត់បញ្ឈប់ពិធីរៀបអាពាហ៍ពិពាហ៍រវាងជនជាតិចិនម្នាក់ ដែលបានមករៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រី

ខ្មែរដោយខុសច្បាប់។ពិធីឃាត់ពិធីរៀបអាពាហ៍ពិពាហ៍ ស្ថិតភូមិស្រយង់ជើង ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ។ ករណីជនជាតិចិនបានមករៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីខ្មែរដោយខុសច្បាប់ គឺត្រូវបានកំលាំងនគរបាលអន្តោប្រវេសន៍ខេត្តព្រះវិហារ ចុះត្រួតពិនិត្យដោយគ្មានលិខិតអនុញ្ញាត ហើយត្រូវបានកំលាំងជំនាញចុះទៅបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍។

ជនជាតិចិនបានមករៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីខ្មែរ គឺមានឈ្មោះ LIANG YANBING ភេទប្រុស អាយុ ៣៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ EC៣៥៩៦៧៣៥ ផុតកំណត់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៨ និងទិដ្ឋាការលេខEI ០១៩៨៦២៤៣ ផុតកំណត់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩ ស្នាក់នៅក្រុងព្រះសីហនុ។រីឯស្ត្រីខ្មែរគឺមានឈ្មោះ ស៊ឹម ស្រីស្តើង អាយុ ២៧ឆ្នាំ មានទីលំនៅស្ថិតក្នុងភូមិស្រយង់ជើង ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ៕ដោយៈ ម៉ែន សុគន្ធា

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់

https://www.facebook.com/GDIOfficial/ **September 18 12:39 PM**

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៦នាក់ នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៦នាក់នេះ មានស្រុកកំណើតនៅខេត្តបាត់ដំបង ០២នាក់ ស្រី ០១នាក់, ខេត្តកំពង់ធំ ០២នាក់ ស្រី ០១នាក់, ខេត្តបន្ទាយមានជ័យ ០១នាក់ ស្រី០១នាក់ និងខេត្តព្រៃវែង ០១នាក់ ស្រី ០១នាក់៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៨នាក់

https://www.facebook.com/GDIOfficial/ September 23 2019 12:39 PM

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៨នាក់ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៨នាក់នេះ មានស្រុកកំណើតនខេត្តបាត់ដំបង ០៤នាក់ ស្រី ០២នាក់, ខេត្តកំពង់ធំ ០១នាក់ ស្រី ០១នាក់, ខេត្តបន្ទាយមានជ័យ ០១នាក់ និងខេត្តព្រៃវែង ០២នាក់ ស្រី ០២នាក់៕

## ត្រាក់ទ័រ ក្រឡាប់សង្កត់ពលករខ្មែរ ម្នាក់ ស្លាប់ នៅខេត្តអយុធ្យា

https://www.facebook.com/khmerlabourofficial/ ពលករខ្មែរ-News **22/09/19**

យោងតាមរបាយការណ៍ ខេត្តអយុធ្យា ប្រទេសថៃ បានឲ្យដឹងថា មានករណីគ្រោះថ្នាក់ក្រឡាប់ត្រាក់ទ័រ មួយ បានកើតឡើងបណ្តាលឲ្យមានបុរសជនជាតិខ្មែរ ឈ្មោះ วิเชียร พรหม អាយុ ៤០ឆ្នាំ ស្លាប់បាត់បង់ជីវិតភ្លាមៗនៅកន្លែងកើតហេតុ ។ ករណីនេះបានកើតឡើងកាលវេលាម៉ោង០៥ល្ងាច ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ នៅត្រង់ចំណុចខាងក្រោយក្រុមហ៊ុនមួយ ស្ថិតនៅសង្កាត់បប៉ោង ស្រុកខ្លងលួង ខេត្តអយុធ្យាប្រទេសថៃ ។ តាមប្រភពព័ត៌មាន បានឲ្យដឹងថា នៅមុនពេលកើតហេតុប្រហែលជាអ្នកស្លាប់ បើកត្រាក់ទ័រទៅលៀងទឹក ប៉ុន្តែអាចជាបើកខុសស្ពាន ទើបបណ្តាលឲ្យត្រាក់ទ័រក្រឡាប់សង្កត់ស្លាប់បែបនេះ បច្ចុប្បន្នសាកសពត្រូវសមត្ថកិច្ចយកទៅរក្សាទុកនៅមន្ទីរពេទ្យថាមសាធធាក់លើមប្រាគៀតខេត្តអយុធ្យា ។

# ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៩

## ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការចូលរួមទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ

http://www.freshnewsasia.com/ 2019-09-25

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩នេះ បានចេញសារគាំទ្រ ស្តីពីការចូលរួមទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ។ ក្នុងសារគាំទ្រនោះ សម្តេចតេជោ ហ៊ុន សែន បានថ្លែងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់នូវអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងយ៉ាងដូច្នេះថា«**ក្នុងនាមជាវង្វង់ភាពជាអ្នកដឹកនាំ ខ្ញុំអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគាំទ្រយ៉ាងខ្លាំងក្លា និងការអនុវត្តនូវគោលនយោបាយ គ្មានការអត់ឱនចំពោះអំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ នៅក្នុងប្រតិបត្តិការថែរក្សាសន្តិភាព អង្គការសហប្រជាជាតិ ព្រមទាំងចូលរួមជាមួយសមាជិកដទៃទៀត ដើម្បីទប់ស្កាត់នូវអំពើបែបនេះ**»។

សម្តេចតេជោនាយករដ្ឋមន្ត្រីបានថ្លែងទៀតថា ដោយទទួលស្គាល់ថាអ្នកថែរក្សាសន្តិភាព ត្រូវតែទទួលខុសត្រូវចំពោះមុខប្រជាជន កងទ័ពមួកខៀវកម្ពុជា ដែលកំពុងបំពេញបេសកកម្មនានា នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ស៊ូដង់ខាងត្បូង, ស៊ូដង់, Cyprus, លីបង់ និងម៉ាលី បានប្រកាន់ភ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយ គ្មានការអត់ឱនចំពោះអំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ប្រកបដោយការទទួលខុសត្រូវ សេចក្តីថ្លៃថ្នូរ និងសីលធម៌ខ្ពស់ ក៏ដូចជាវិន័យដ៏តឹងតែង។ សម្តេចតេជោបានបន្ថែមថា ទោះបីជាបទល្មើសរបស់ពួកគេ ជាការទទួលខុសត្រូវរួមរបស់អង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកក៏ដោយ ជនល្មើសដែលបានប្រព្រឹត្តអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ត្រូវតែទទួលខុសត្រូវដោយផ្ទាល់ ចំពោះមុខច្បាប់ ចំពោះទង្វើរបស់ពួកគេ៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរពីភាគីថៃចំនួន ០៨នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration – GDI 23-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៨នាក់ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ពាក់ព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៨នាក់នេះ មានស្រុកកំណើតនខេត្តបាត់ដំបង ០៤នាក់ ស្រី ០២នាក់, ខេត្តកំពង់ធំ ០១នាក់ ស្រី ០១នាក់, ខេត្តបន្ទាយមានជ័យ ០១នាក់ និងខេត្តព្រៃវែង ០២នាក់ ស្រី ០២នាក់៕

## អាមេរិកគ្រោងចាប់ពលរដ្ឋខ្មែរ-អាមេរិកាំងបន្ថែមទៀត បញ្ជូនមកកម្ពុជាវិញ

https://www.postkhmer.com/ នៀម ឆេង | Publication date 25 September 2019 | 10:04 ICT

**ភ្នំពេញៈ** នាយកដ្ឋានអន្តោប្រវេសន៍ និងគយសហរដ្ឋអាមេរិកគ្រោងនឹងចាប់ខ្លួនពលរដ្ឋខ្មែរ-អាមេរិកាំងបន្ថែមទៀត នៅប៉ុន្មានសប្តាហ៍ខាងមុខនេះ ដើម្បីបញ្ជូនបន្តមកកម្ពុជា។ នេះបើយោងតាមការប្រកាសរបស់អង្គការធ្វើការផ្នែកច្បាប់ និងសិទ្ធិមនុស្សឈ្មោះថា Asian Ameri- cans Advancing Justice (AAJC)។

អង្គការ AAJC មានមូលដ្ឋាននៅទីក្រុងសានហ្វ្រានស៊ីស្កូ រដ្ឋកាលីហ្វ័រនីញ៉ា សហរដ្ឋអាមេរិក បានចេញសេចក្តីណែនាំក្រើនរំឭកដល់ពលរដ្ឋខ្មែរនៅទីនោះឲ្យមានការប្រុងប្រយ័ត្ន និងបានប្រកាសថាពលរដ្ឋនៃសហគមន៍ខ្មែរដែលធ្លាប់ទទួលបានដីកាសម្រេចបណ្តេញចេញ ឬត្រូវចូលបំភ្លឺនៅអាជ្ញាធរអន្តោប្រវេសន៍ និងគយសូមទាក់ទងអង្គការនេះដើម្បីទទួលបានជំនួយផ្នែកច្បាប់។ សេចក្តីណែនាំបានសរសេរថា៖ «បើសិនជាអ្នកត្រូវចូលបំភ្លឺ សូមនាំអ្នកណាម្នាក់

ទៅជាមួយ។ ប្រគល់កូនសោរបស់អ្នក ឬកាបូបលុយ និងទូរស័ព្ទឲ្យអ្នកទៅជាមួយមុនពេលចូលបំភ្លឺ។ សូមសរសេរ ឬត្រូវទន្ទេញឲ្យចាំនូវលេខទូរស័ព្ទសំខាន់ៗ។ បើសិនជាអ្នកមិនអាចចេញមកវិញបានទេ សូមឲ្យអ្នកទៅជាមួយទូរស័ព្ទមកពួកយើងភ្លាម»។ អង្គការ AAJC ឲ្យដឹងថា មន្ត្រីអនុវត្តច្បាប់ពីនាយកដ្ឋានអន្តោប្រវេសន៍ និងគយអាចប្រើប្រាស់ឡានណាមួយដែលមិនមានសញ្ញាច្បាស់លាស់ ឬអាចគោះទ្វារ ឬពេលខ្លះពួកគេរង់ចាំនៅកន្លែងណាមួយរង់ចាំចាប់ខ្លួនអ្នកដែលគេកំណត់គោលដៅបន្ទាប់ពីអ្នកទាំងនោះចេញពីធ្វើការ។ ទោះយ៉ាងណាអង្គការនេះបានបញ្ជាក់ថា៖ «បើទោះបីជាឥឡូវនេះជាពេលវេលាគួរឲ្យខ្វល់ខ្វាយក៏ដោយ យើងត្រូវដឹងថា សហគមន៍នឹងគាំទ្រអ្នក។ វាអាចទៅរួចក្នុងការប្រឆាំងនឹងការបណ្ដេញចេញ»។

កាលពីខែកក្កដាពលរដ្ឋខ្មែរ-អាមេរិកាំង ៣៧ នាក់ ត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញដោយចាកចេញពីទីក្រុងដាឡាស រដ្ឋតិចសាស់ សហរដ្ឋអាមេរិក។ នាយកដ្ឋានអន្តោប្រវេសន៍ និងគយសហរដ្ឋអាមេរិកបានបញ្ជាក់នាពេលនោះថា ការបណ្ដេញចេញពលរដ្ឋកម្ពុជាបានកើនឡើង ២៧៩ ភាគរយ នៅឆ្នាំ ២០១៨ ប្រៀបធៀបទៅនឹងឆ្នាំ ២០១៧។ ប៉ុន្តែមិនបានបញ្ជាក់អំពីតួលេខប៉ុន្មានភាគរយក្នុងឆ្នាំ ២០១៧ នោះទេ។ នាយកដ្ឋានដដែលបញ្ជាក់ថាមានពលរដ្ឋខ្មែរប្រមាណ ១ ៩០០ នាក់ ដែលមានដីកាបណ្ដេញចេញ ហើយកំពុងរស់នៅសហរដ្ឋអាមេរិក។ ក្នុងចំនួននេះមាន ១ ៤០០ នាក់ គឺជាឧក្រិដ្ឋជនដែលកាត់ទោសរួចហើយ។

យោងតាម AAJC ចាប់ពីឆ្នាំ ២០០២ បន្ទាប់ពីមានកិច្ចព្រមព្រៀងរវាងកម្ពុជា-អាមេរិក រួចមកពលរដ្ឋខ្មែរ-អាមេរិកាំងប្រមាណ ៨០០ នាក់ ត្រូវបានចាប់បញ្ជូនមកកម្ពុជាវិញហើយរហូតមកដល់ឆ្នាំ ២០១៩ នេះ។

លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌បានថ្លែងថា ការបណ្ដេញចេញពលរដ្ឋទាំងនោះមកកម្ពុជាវិញគឺធ្វើឡើងតាមកិច្ចព្រមព្រៀងរវាងសហរដ្ឋអាមេរិក និងកម្ពុជាហើយក៏អាស្រ័យលើច្បាប់ និងតុលាការរបស់អាមេរិកដែរ។ ទោះយ៉ាងណាលោកថា ការបណ្ដេញចេញដោយបង្ខំ រំលោភទៅលើគោលការណ៍មនុស្សធម៌ និងសិទ្ធិមនុស្ស ជាពិសេសនៅពេលអ្នកដែលត្រូវបានបណ្ដេញចេញនោះមិនអាចធ្វើសមាហរណកម្មទៅក្នុងប្រទេស ដែលជាទីកន្លែងថ្មីសម្រាប់ពួកគេបាន។ លោកថ្លែងថា៖ «អ្នកខ្លះកើតនៅអាមេរិក ពួកគេមិនទាំងចេះនិយាយខ្មែរ មិនស្គាល់វប្បធម៌ខ្មែរ ហើយមិនមានក្រុមគ្រួសារនៅទីនេះទៀត។ ដូច្នេះការបណ្ដេញពួកគេមកនេះគឺដូចបញ្ជូនពួកគេឲ្យមករងទុក្ខនៅកន្លែងផ្សេងបន្ថែមទៀត»។ លោកបន្ថែមថារដ្ឋដែលធ្វើការបណ្ដេញចេញនេះគួរតែទទួលរ៉ាប់រងការចំណាយលើសេវាសម្រាប់ការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គម។

លោកស្រី ចក់ សុភាព ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាយល់ឃើញថា ខ្មែរ-អាមេរិកាំងដែលបានអនុវត្តទោសជាប់ពន្ធនាគារនៅអាមេរិករួចហើយនោះត្រូវបានគេដាក់ទោសម្តងទៀតដោយការបណ្ដេញចេញមកស្រុកខ្មែរ។ លោកស្រីថ្លែងថា៖ «នៅពេលពលរដ្ឋខ្មែរអាមេរិកាំងទាំងនោះត្រូវបានបណ្ដេញចេញ ឋានៈជាជនភៀសខ្លួនរបស់ពួកគេមិនគួរត្រូវបានបំភ្លេចចោលនោះទេ។ សិទ្ធិមនុស្សសម្រាប់ជនភៀសខ្លួនត្រូវតែជាកត្តាចម្បង និងសំខាន់ក្នុងការកំណត់ជោគវាសនារបស់ពួកគេ»៕

## ពលករខ្មែរ៤នាក់ បានស្លាប់ និងរបួស ដោយសារបាក់កន្លែងស្នាក់នៅពីជាន់ទី៣ មកដី

http://kampucheathmey.com/ សោ និយមរ័ត្ន 25/9/2019 10:48 Am

ប្រទេសថៃ ៖ យ៉ាងហោចណាស់ក៏មានពលករខ្មែរម្នាក់ដែរ ដែលបានស្លាប់នៅក្នុងចំណោមពលករខ្មែរ ចំនួន ៤នាក់ នៅក្នុងហេតុការណ៍ នៃការបាក់កន្លែងស្នាក់នៅរបស់ពួកគេ ពីអគារកម្ពស់៨ជាន់ ខណៈដែលពួកគេទាំងអស់គ្នាកំពុងឈរសម្រាកនៅកន្លែងស្នាក់នៅនោះ។

យោងតាមរបាយការណ៍របស់ក្រុមហ៊ុនមូលនិធិ ស្វាងបរិបូរណ៍ ប្រចាំខេត្តឈុនបុរីបានបញ្ជាក់ថា ការបាក់ធ្លាក់កន្លែងស្នាក់នៅរបស់ពលករខ្មែរនេះ បានកើតឡើងកាលពីវេលាម៉ោង១០ព្រឹក ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៩ នៅ

ចំណុចផ្លូវ ១៤/១ ផាត់តាយ៉ា ណាក្លឿ ក្នុងឃុំណាក្លឿ ស្រុកបាងលៈមុង ខេត្តឈុនបុរី។ របាយការណ៍បានបន្តថា នៅពេលនោះដែរ ក្រុមតម្រួតថៃបានចុះពិនិត្យដល់ទីតាំងកើតហេតុ ដែលជាការដ្ឋាន កំពុងសាងសង់ខនដូ កម្ពស់៨ជាន់។ ជាក់ស្តែងនៅលើផ្ទៃដី គឺមានពលករខ្មែរចំនួន៤ នាក់ កំពុងរងរបួសដែលក្នុងនោះមានម្នាក់របួសយ៉ាងធ្ងន់ធ្ងរ ទើបត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យ ក្រុងទេព ផាត់តាយ៉ា ចំណែក៣នាក់ទៀត ត្រូវបញ្ជូនទៅមន្ទីរពេទ្យ បាងលៈមុង ដើម្បីសង្គ្រោះ។ ក្រោយពីសមត្ថកិច្ចត្រួតពិនិត្យរួចមក គេបានសន្និដ្ឋានថា ពួកគេ ( ពលករ ) បានផ្សា.តដែកមកខាងក្រៅអគារប្រមាណ២ម៉ែត្រ គឺនៅជាន់ទី៣ ដោយក្រាលក្តារកុងផ្លាកេ ហើយនៅពេលនោះគឺពួកគេបានឈរលេងនៅជុំគ្នាទើបបណ្តាលអោយបាក់កន្លែងស្នាក់នៅនោះមកដីតែម្តង ដែលសមត្ថកិច្ចបានកំណត់ថា វាអាចលើសទម្ងន់ ដែលដែកនោះមិនអាចទ្រទ្របាន។

ក្រោយមកទើបដឹងថា ជនរងគ្រោះដែលធ្ងន់ជាងគេ ហើយបានស្លាប់នៅក្នុងមន្ទីរពេទ្យ ក្រុងទេព ផាត់តាយ៉ា នោះមានឈ្មោះ ថន ភេទប្រុស អាយុ២០ឆ្នាំ ដោយឡែក ពលករខ្មែរ៣នាក់ទៀត មានឈ្មោះ ១. ឆាន់ ឌី ភេទប្រុស អាយុ១៨ឆ្នាំ ២. ឈ្មោះ រិន ភេទប្រុស អាយុ១៨ឆ្នាំ និង ៣.ឈ្មោះ តាន់ មឿន ភេទស្រី អាយុ១៩ឆ្នាំ។ បច្ចុប្បន្ន សពត្រូវបានកម្លាំងជំនាញរៀបចំដើម្បីបញ្ជូនទៅកាន់ស្រុកកំណើត ហើយក្រុមតម្រួតថៃក៏បានអះអាងបន្ថែមថា គេនឹងស្រាវជ្រាវលម្អិតអំពីបញ្ហា នៃការបាក់ធ្លាក់នេះ ហើយគេនឹងហៅពលករខ្មែរទាំងអស់ ដែលធ្វើការនៅក្នុងខនដូនេះ ដើម្បីពិនិត្យរកអ្នកមានច្បាប់ត្រឹមត្រូវ និងអ្នកដែលគ្មានច្បាប់៕

## កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៧នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration - GDI 25-09-2019

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០៧នាក់ នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ពាកព័ន្ធនឹងករណីស្នាក់នៅខុសច្បាប់។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៧នាក់នេះ មានស្រុកកណើតនៅខេត្តបាត់ដំបង ០៤នាក់ ស្រី ០២នាក់ កុមារ ០១នាក់, ខេត្តកំពង់ធំ ០២នាក់ ស្រី ០១ នាក់ និងខេត្តបន្ទាយមានជ័យ ០១នាក់៕

# ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៩

## លោក ហ៊ុន សែន៖ គ្មានការអត់ឱនចំពោះអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 26 September 2019 | 10:00 ICT

**ភ្នំពេញៈ** លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហាញការប្តេជ្ញាចិត្តជាថ្មីរបស់កម្ពុជាចូលរួមគាំទ្រទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទក្នុងកិច្ចប្រតិបត្តិការថែរក្សាសន្តិភាពអង្គការសហប្រជាជាតិស្របពេលកម្ពុជានៅតែរក្សាតួនាទីជាប្រទេសមួយក្នុងចំណោម ១៤ ប្រទេសផ្សេងទៀតលើ ២២២ ប្រទេស ដែលមិនជាប់ពាក់ព័ន្ធនឹងអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទនៅតំបន់បេសកកម្ម។

ការថ្លែងពីការប្តេជ្ញាជាថ្មីនេះបានធ្វើឡើងនៅក្នុងវីដេអូខ្លីមួយប្រមាណជា ២ នាទីដែលបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់លោកកាលពីម្សិលមិញ ដោយបានលើកឡើងថា៖ «ក្នុងនាមជាសមាជិកនៃរង្វង់ភាពជាអ្នកដឹកនាំ ខ្ញុំអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រយ៉ាងខ្លាំងក្លា និងការអនុវត្តនូវគោលនយោបាយគ្មានការអត់ឱនចំពោះអំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទនៅក្នុងប្រតិបត្តិការថែរក្សាសន្តិភាព អង្គការសហប្រជាជាតិ ព្រមទាំងចូលរួមជាមួយសមាជិកដទៃទៀត ដើម្បីទប់ស្កាត់នូវអំពើបែបនេះ»។ លោក ហ៊ុន សែន ថ្លែង

ដោយទទួលស្គាល់ថា អ្នកថែរក្សាសន្តិភាពត្រូវតែទទួលខុសត្រូវចំពោះមុខប្រជាជន កងទ័ពមួកខៀវកម្ពុជាដែលកំពុងបំពេញបេសកកម្មនានា នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ស៊ូដង់ខាងត្បូង, ស៊ូដង់, ស៊ីប, លីបង់ និងម៉ាលី បានប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយ គ្មានការអត់ឱនចំពោះអំពើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ប្រកបដោយការទទួលខុសត្រូវ សេចក្តីថ្លៃថ្នូរ និងសីលធម៌ខ្ពស់ក៏ដូចជាវិន័យដ៏តឹងតែង។ លោកបញ្ជាក់បន្តថា៖ «នេះគឺជាភាពចាំបាច់នៃសីលធម៌ និងភាពចាំបាច់នៃប្រតិបត្តិការដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពដែលអាចជឿទុកចិត្តបានរបស់អង្គការសហប្រជាជាតិ។ ទោះបីជាបទល្មើសរបស់ពួកគេជាការទទួលខុសត្រូវរួមរបស់អង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកក៏ដោយ ជនល្មើស ដែលបានប្រព្រឹត្តអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទត្រូវតែទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខច្បាប់ ចំពោះទង្វើរបស់ពួកគេ»។

លោកស្រី កុសល ម៉ាលីដា អ្នកនាំពាក្យមជ្ឈមណ្ឌលជាតិរក្សាសន្តិភាពនៃក្រសួងការពារជាតិបានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា តាមច្បាប់អង្គការសហប្រជាជាតិរាល់ប្រទេសដែលស្ថិតក្នុងការបរិច្ចាគកងកម្លាំងរបស់ខ្លួនទៅបំពេញបេសកកម្មថែរក្សាសន្តិភាពអង្គការសហប្រជាជាតិត្រូវគោរពឲ្យបាន និងចូលរួមលុបបំបាត់អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទនៅក្នុងតំបន់បេសកកម្មដែលខ្លួនបានបំពេញ។ លោកស្រីបន្តថា៖ «ជារួមករណីនេះមានប្រទេសគេផ្សេង (ប្រព្រឹត្ត) ហើយបានកើតឡើងនៅប្រទេសបេសកកម្ម។ ប៉ុន្តែគ្រាន់តែថា បើយើងនិយាយពាក់ព័ន្ធនឹងប្រទេសកម្ពុជាយើងគឺជាប្រទេសមួយក្នុងចំណោម ១៤ ប្រទេសដែលមិនជាប់ពាក់ព័ន្ធនឹងរឿងរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទហ្នឹង។ ច្បាស់ជាសម្តេចលើកឡើងរឿងហ្នឹងហើយ ដែលកម្ពុជាមិនពាក់ព័ន្ធ និងបង្ហាញការប្តេជ្ញាចិត្តជាថ្មីទៀត»។ លោកស្រី ម៉ាលីដា ថ្លែងថាក្នុងរយៈពេល ១៣ ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៦ មក ប្រទេសកម្ពុជាបានបញ្ជូនកងទ័ពមួកខៀវទៅក្រៅប្រទេសបាន ១០ បេសកកម្ម ដោយមានចំនួន ៦ ៣៥២ នាក់ ក្នុងនោះមានស្ត្រី ៣២៨ នាក់ ទៅកាន់ប្រទេសចំនួន ៨ រួមមានស៊ូដង់ ស៊ូដង់ខាងត្បូង លីបង់ អាហ្វ្រិកកណ្តាល ស៊ីរី ស៊ីប ម៉ាលី និងប្រទេសឆាដ។ លោកស្រីបន្តថា កងទ័ពមួកខៀវរបស់កម្ពុជាដែលបញ្ជូនទៅជាកម្លាំងជំនាញ ផ្នែកវិស្វកម្ម កម្លាំងពេទ្យកម្រិត ២ កម្លាំងបោសសម្អាតមីន កម្លាំងអាវុធហត្ថ និងកម្លាំងកម្មេចយុទ្ធភណ្ឌមិនទាន់ផ្ទុះ ខណៈដែលកម្ពុជាបានត្រៀមរួចជាស្រេចនូវកងទ័ពមួកខៀវទាំងនេះសម្រាប់បម្រុងទុកនៅពេលមានការស្នើឡើងបន្ថែមទៀតពីអង្គការសហប្រជាជាតិក្នុងពេលខាងមុខ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សកម្ពុជា បាននិយាយថា ក្នុងពេលនេះការដែលលោកនាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងសារបែបនេះគឺចង់បង្ហាញពីការចូលរួមគាំទ្រទៅលើការប្រឆាំងនឹងអំពើជួញដូរ និងរំលោភបំពានផ្លូវភេទ។ លោកស្រីថា «លោកមានប្រសាសន៍នេះគឺក្នុងពេលដែលមានប្រតិបត្តិការរបស់អង្គការសហប្រជាជាតិហ្នឹង អ៊ីចឹងមានន័យថាគោលការណ៍នេះគឺរដ្ឋាភិបាលខ្មែរ ប្រកាន់ជំហរហ្នឹង និងប្រឆាំងដាច់ខាតអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ»៕

## ក្រសួងសង្គមកិច្ច និងអង្គការជាតិ-អន្តរជាតិ កំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស

http://www.freshnewsasia.com/ 2019-09-26

**(ភ្នំពេញ)៖** ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមទាំងដៃគូពាក់ព័ន្ធអង្គការជាតិ អន្តរជាតិជាច្រើនរួមគ្នា រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានអត្ថប្រយោជន៍នានា មុននឹងធ្វើសមាហរណកម្មពួកគេទៅកាន់សហគមន៍វិញ។ ជុំវិញការរៀបចំច្បាប់ ស្តីពីការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រសួងសង្គមកិច្ច ក៏បានបានរៀបចំសិក្ខាសាលាមួយ នាថ្ងៃទី២៥ កញ្ញា ឆ្នាំ២០១៩ ដោយមានការអញ្ជើញចូលរួមពីបណ្តាអង្គការជាតិ អន្តជាតិ

និងមន្ត្រីពីស្ថាប័នពាក់ព័ន្ធជាច្រើន មកជជែកពិភាក្សា ដើម្បីប្រមូលធាតុចូលបន្ថែម ដែលមានសារៈសំខាន់សម្រាប់ការរៀបចំច្បាប់នេះ។

ក្នុងឱកាសបិទសិក្ខាសាលា លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច តំណាងលោក វង សូត អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ថា ការព្យាយាមបង្កើតច្បាប់នេះ ជារឿងចាំបាច់ដើម្បីការពារថែទាំ និងផ្តល់អត្ថប្រយោជន៍ជាការបណ្តុះបណ្តាលជំនាញ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មុននឹងធ្វើសមាហរណកម្មពួកគេទៅសហគមន៍វិញ ដោយមានភាពប្រសើរ។ លោកបានបន្ថែមថា ច្បាប់នេះ ពុំទាន់អាចបញ្ជាក់ពេលវេលាអនុម័តជាក់លាក់នៅឡើយនោះទេ ដោយសារបច្ចុប្បន្នវាស្ថិតក្នុងដំណាក់កាល សេចក្តីព្រាងដំបូង ដែលទាមទារការប្រមូលធាតុចូលពីស្ថាប័ន និងបណ្តាអង្គការពាក់ព័ន្ធទាំងអស់។ លោក ញឹក វណ្ណារ៉ា បានបញ្ជាក់ថា បច្ចុប្បន្ននេះ ក្រសួងសង្គមកិច្ច កំពុងធ្វើការយ៉ាងសកម្ម ជួយដល់ជនរងគ្រោះ នៅពេលពួកគេត្រូវបានបញ្ជូនមកដល់កម្ពុជាវិញ ទោះបីជាពុំទាន់មានមណ្ឌលសុំចតគ្រប់ច្រកព្រំដែនក្តី។

ក្រសួងបានប្រើប្រាស់មន្ទីរសង្គមកិច្ច និងបណ្តាអង្គការដៃគូមួយចំនួន ជាមណ្ឌលសំចតបណ្តោះអាសន្ន សម្រាប់ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយទទួលបានការថែទាំ ការស្នាក់នៅ អត្ថប្រយោជន៍នឹង ការផ្តល់ជូនការបណ្តុះបណ្តាលជំនាញមួយចំនួនផងដែរ។ លោក បានបញ្ជាក់ថា សព្វថ្ងៃនេះ កម្ពុជាមានមណ្ឌលសំចតធំមួយនៅ ប៉ោយប៉ែត ហើយភាគីថៃ ក៏នឹងជួយសាងសង់មណ្ឌលសំចតបណ្តោះអាសន្នមួយទៀតនៅ ប៉ោយប៉ែត ក្នុងចុងឆ្នាំ ២០១៩នេះ ហើយកម្ពុជាក៏បានសាងសង់ មណ្ឌលសំចតបណ្តោះអាសន្នមួយនៅ ច្រកដូង សម្រាប់ការជួយដល់ ជនរងគ្រោះដែលបញ្ជូនមកតាមច្រកមួយនេះ៕

## ពលករវិលត្រឡប់មកចូលរួមពិធីបុណ្យភ្ជុំបិណ្ឌមានចំនួនតិចជាងឆ្នាំមុនៗ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៩ ម៉ោង ១៦:២៥ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ មកទល់នឹងថ្ងៃទី២៥ កញ្ញា ឆ្នាំ២០១៩ ទៅហើយគឺនៅសល់តែ៤ថ្ងៃទៀតតែប៉ុណ្ណោះនឹងដល់ថ្ងៃកាន់បិណ្ឌវេនទី១៥ ត្រូវជាថ្ងៃភ្ជុំធំ ប៉ុន្តែគេសង្កេតឃើញចំនួនពលករវិលត្រឡប់ពីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួនតិចតួចជាងឆ្នាំមុនៗ ។ នៅមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតក៏ដូចជាតាមបណ្តាទីតាំងលក់សំបុត្ររថយន្តក្រុងតាមដងផ្លូវជាតិលេខ៥ និងនៅចំណុចចំណតរថយន្តពុំសូវមានពលករពេញពក់ពពូនដូចមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិទេ។ ពេលជួបផ្ទាល់ជាមួយអ្នកលក់សំបុត្ររថយន្តក្រុង ក៏ដូចជាអ្នករត់តាក់ស៊ីនៅក្រុងប៉ោយប៉ែតបានប្រាប់ឱ្យដឹងថា មុនពិធីបុណ្យភ្ជុំបិណ្ឌឆ្នាំនេះពុំសូវមានពលកររកជិះរថយន្តច្រើនដូចមុនពិធីបុណ្យចូលឆ្នាំជារៀងរាល់ឆ្នាំឡើយ ។

ពួកគាត់បានបន្តថា ប្រទេសថៃមិនមានពិធីកាន់បិណ្ឌ១៥ថ្ងៃដូចកម្ពុជាឡើយ ពោលគឺប្រទេសថៃមានតែថ្ងៃភ្ជុំធំតែមួយថ្ងៃប៉ុណ្ណោះគឺចំថ្ងៃបុណ្យភ្ជុំធំដូចកម្ពុជាដែរ។ ចំណែករថយន្តក្រុងក៏ដូចជារថយន្តតាក់ស៊ីដែរពុំសូវមានអ្នកជិះនោះទេ ហើយពេលនេះរថយន្តក្រុងខ្លះងាកទៅដឹកទំនិញរួមជាមួយអ្នកដំណើរ និងរថយន្តខ្លះទៀតដឹកផ្លែឈើផងដែរ ។ ចំណែកទីតាំងបំពេញបែបបទចូលប្រទេស (Arrival) នៅមាត់ច្រកទ្វារអន្តរជាតិប៉ោយប៉ែតក៏ដូចជាទីតាំងបំពេញបែបបទប័ណ្ណព្រំដែនមានពលករដែលកាន់លិខិតឆ្លងដែន (Pass port) និងប័ណ្ណព្រំដែន (Border Pass) មានពលករវិលត្រឡប់តិចតួចហើយពេលខ្លះហាក់ស្ងាត់ទៀតផង។

ជុំវិញករណីខាងលើនេះ លោក សេម មករា ប្រធានសេនាធិការនគរបាលអន្តោប្រវេសន្តច្រកទ្វារអន្តរជាតិប៉ោយប៉ែត បានប្រាប់តាមទូរស័ព្ទនៅរសៀលថ្ងៃទី២៥ កញ្ញា ឆ្នាំ២០១៩នេះថា ចំនួនពលករវិលត្រឡប់ពីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតពិតជាមានចំនួនតិចតួចប្រាកដមែន ។ ប៉ុន្តែតាមប្រភពខ្លះថា ពលករអាចវិលតាមច្រកទ្វារអន្តរ

ជាតិដូងក្នុងស្រុកកំរៀង ខេត្តបាត់ដំបង មានចំនួនច្រើន។ លោកបានកត់សម្គាល់ថា ពលករវិលត្រឡប់ពីថៃតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីចូលរួមពិធីបុណ្យភ្ជុំបិណ្ឌឆ្នាំនេះមានចំនួនតិចជាងបណ្ដាឆ្នាំមុនៗ៕ (ម្រួល ៖ ធីតា)

## ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៩

### កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration **September- 27 -2019**

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៣នាក់ នាវេលាម៉ោង ១៧និង០០នាទី ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំរួច អនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

### កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់

https://www.facebook.com/GDIOfficial/ General Department of Immigration **September 27 at 8:11 PM •**

កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលករខ្មែរ ពីភាគីថៃចំនួន ០១នាក់ នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

### ពលករមីយ៉ាន់ម៉ា ប្រមាណជាង១០០នាក់ ត្រូវបានបញ្ជូនចេញពីប្រទេសថៃឡង់ដ៍ មកកាន់ស្រុកកំណើតវិញ

https://www.dap-news.com/ ByID:030 Posted on 28 September 2019 | 09:25

ទីភ្នាក់ងារព័ត៌មានចិនស៊ិនហួ បានចុះផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ថា ក្រុមអាជ្ញាធរអន្តោប្រវេសន៍មីយ៉ាន់ម៉ា បានឲ្យដឹងនៅថ្ងៃព្រហស្បតិ៍នេះថា ពលកររបស់ប្រទេសមីយ៉ាន់ម៉ា តិចបំផុត១០៩នាក់ ត្រូវបានបញ្ជូនចេញពីប្រទេសថៃឡង់ដ៍ មកកាន់ស្រុកកំណើតវិញ ។ ក្រុមពលករដែលជាជនអន្តោប្រវេសន៍ខុសច្បាប់ ក្នុងនោះរាប់បញ្ចូលទាំងស្ត្រីចំនួន៩នាក់ ត្រូវបានប្រគល់ ដោយ នាយកដ្ឋានជនអន្តោប្រវេសន៍ រ៉ាណង របស់ប្រទេសថៃឡង់ដ៍តាមច្រកព្រំដែន Kawthoung ជាប់ព្រំដែន តំបន់ ភាគខាងត្បូង Tanintharyi កាលពីថ្ងៃពុធ ។ ក្រុមកម្មករ ដែលជាអ្នកត្រូវបាននិរទេសខ្លួនដោយក្រុមអាជ្ញាធរថៃ ដែលបានរកឃើញថា ទិដ្ឋការ អស់សុពលភាព និងមិនមានឯកសារបញ្ជាក់ច្បាស់លាស់ ត្រូវបានធ្វើមាតុភូមិនិវត្តន៍ ក្រោយពីបានបង់ ប្រាក់ពិន័យស្ថិតក្រោមច្បាប់របស់ប្រទេសថៃ ៕ c ប្រែសម្រួលដោយ៖ ម៉ៅ បុប្ផាមករា